Australian Aid

World Vision

# ឧបករណ៍
# សម្តែងមតិដើម្បីឲ្យមាន
# ការផ្លាស់ប្តូរ



The Vanguard Series

អង្គការទស្សនៈពិភពលោកគឺជាអង្គការគ្រីស្ទសាសនាដែលធ្វើការ លើការផ្តល់ជំនួយសង្គ្រោះ បន្ទាន់ ការអភិវឌ្ឍន៍ការតស៊ូមតិ និងធ្វើការជួយដល់កុមារ ក្រុមគ្រួសារនិងសហគមន៍ដើម្បីយកឈ្នះ លើភាពក្រីក្រនិង ភាពអយុត្តិធម៌។ ភាពជាគ្រីស្ទបរិស័ទ្ធ បានលើកទឹកចិត្តពួកយើង ធ្វើការដើម្បីជួយដល់មនុស្សដែលងាយរងគ្រោះបំផុត។ ពួកយើងធ្វើការបំរើដល់អ្នកដែលងាយរងគ្រោះទាំងនោះដោយមិនប្រកាន់ សាសនាពូជសាសន៍ សញ្ជាតិ និង សមភាពយេនឌ័រ។

**កម្រងសៀវភៅត្រួសត្រាយផ្លូវ** (The Vanguard Series) ៖ មធ្យោបាយប្រកបដោយភាពច្នៃប្រឌិតថ្មី ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរនិងការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព។

© អង្គការទស្សនៈពិភពលោក អន្តរជាតិ ឆ្នាំ ២០១៥

ISBN ៖ ៩៧៨-0-៩១៨២៦១-៩៩-៦

អ្នកនិពន្ធ និងសហការីនិពន្ធ៖ Camilla Jordanwood, John Whan Yoon, Stefan Stoyanov, Amy Collins, Steve Gourley, AbidGulzar និង Camilla Sahlin ។

សូមរក្សាសិទ្ធិគ្រប់យ៉ាងដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ ដោយគ្មានផ្នែកណាមួយ ដែលបានបោះពុម្ពផ្សាយក្នុងសៀវភៅនេះ អាចនឹងត្រូវបានបោះពុម្ពផ្សាយឡើងវិញក្នុងទម្រង់ណាមួយ ដោយពុំមានការអនុញ្ញាតពីអ្នកបោះពុម្ពផ្សាយជាមុនឡើយ លើកលែងតែការដកស្រង់ដោយសង្ខេបសម្រាប់យកមកធ្វើជាឯកសារយោងក្នុងការសរសេរអត្ថបទណាមួយប៉ុណ្ណោះ។

ការបោះពុម្ពផ្សាយនេះ ត្រូវបានធ្វើឡើងដោយកម្មវិធីបញ្ឈប់ការជួញដូរមនុស្ស (ETIP) ក្នុងនាមជាតំណាងនៃអង្គការទស្សនៈពិភពលោកអន្តរជាតិ ។

ចំពោះព័ត៌មានបន្ថែមអំពីការបោះពុម្ពផ្សាយនេះ ឬការបោះពុម្ពផ្សាយរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិឬប្រសិនបើត្រូវការច្បាប់ចម្លងបន្ថែមអំពីការបោះពុម្ពផ្សាយនេះសូមទាក់ទង wvi_publishing@wvi.org

អង្គការទស្សនៈពិភពលោកអន្តរជាតិ សូមសម្តែងនូវការកោតសរសើរ ចំពោះការទទួលយកសេចក្តីលម្អិតក្នុងឯកសារនេះ ជាប្រយោជន៍សម្រាប់ប្រើប្រាស់នៅក្នុងការបណ្តុះបណ្តាល ការស្រាវជ្រាវ ការរៀបចំកម្មវិធី អនុវត្តកម្មវិធី ឬវាយតម្លៃកម្មវិធី។

តំណាងគណៈគ្រប់គ្រងនៃ កម្មវិធីបញ្ឈប់ការជួញដូរមនុស្ស (ETIP) ដោយអ្នកនាង Amy Collins និងលោក Stefan Stoyanov។ នាយកនិពន្ធ លោក Heather Elliott អ្នកគ្រប់គ្រងការបោះពុម្ព Katie Klopman Fike អ្នកពិនិត្យកែសម្រួលដោយលោក Joan Weber Laflamme និង. អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធដោយ Audrey Dorsch ។ អ្នករចនាក្របខាងក្រៅ និងប្លង់ខាងក្នុង Inis Communications និងអ្នកបង្ហាញសាច់រឿងខ្លីៗដោយ Rishi Mandhyan, John Kelvin Co, and Natasha Bautista។

Australian Aid

World Vision®

# ឧបករណ៍ សម្តែងមតិដើម្បីឲ្យមាន ការផ្លាស់ប្តូរ



សៀវភៅណែនាំដើម្បីជំរុញ និងបណ្តុះបណ្តាលយុវជន ដើម្បីលើកកម្ពស់យុទ្ធនាការតស៊ូមតិ ប្រឆាំងនឹងការជួញដូរមនុស្ស ពលកម្មកុមារ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ។



# អារម្ភកថា

សៀវភៅណែនាំដែលមានចំណងជើងថា ឧបករណ៍សំដែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរ ត្រូវបានរៀបចំឡើងសម្រាប់បណ្តុះបណ្តាលយុវជននៅក្នុងប្រទេសមហាអនុតំបន់មេគង្គ Greater Mekong sub-region (GMS) អោយមានសំលេងចូលរួមរបស់ពួកគេ និងការតស៊ូមតិ ដើម្បីការពារដល់អ្នកដែលងាយរងគ្រោះ និងអ្នកដែលរងគ្រោះដោយអំពើជួញដូរមនុស្ស។ យុវជនដែលជាកម្លាំងចលករក្នុងការតស៊ូមតិ នឹងត្រូវបានទទួលការបណ្តុះ - បណ្តាលដើម្បីកំណត់រកបញ្ហាចំបងដែលទាក់ទងនឹងការជួញដូរមនុស្ស ដែលពួកគេចង់ឲ្យមន្ត្រីរដ្ឋាភិបាលមានការដោះស្រាយ ការបង្កើត និងការអនុវត្តផែនការតស៊ូមតិ។

សៀវភៅណែនាំដែលមានចំណងជើងថា ឧបករណ៍សំដែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរ គឺជាគូនឹងសៀវភៅណែនាំដែលមានចំណងជើងថា ឧបករណ៍នាវិកវៃឆ្លាត ។ សៀវភៅណែនាំដែលមានចំណងជើងថា ឧបករណ៍នាវិកវៃឆ្លាត  មាន៣១ មេរៀន ដែលចងក្រងឡើងដើម្បីជួយដល់យុវជន មានចំណេះដឹងទាក់ទងនឹងគ្រោះថ្នាក់នៃការជួញដូរ និងចំណាកស្រុកអសុវត្ថិភាព និងបានដឹងយ៉ាងច្បាស់លាស់អំពីជំហានដែលពួកគេអាចការពារខ្លួនឯងបាន។ សៀវភៅណែនាំដែលមានចំណងជើងថា ឧបករណ៍សំដែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរ ចងក្រងឡើងក្នុងគោលបំណងផ្តោតលើយុវជនដែលបានចូលរួមក្នុងក្លឹបយុវជននាវិកវៃឆ្លាត ហើយបានទទួលការបណ្តុះបណ្តាលរួចហើយអំពីខ្លឹមសារក្នុងសៀវភៅណែនាំដែលមានចំណងជើងថា ឧបករណ៍នាវិកវៃឆ្លាត ។

យុវជនទាំងនោះគឺ មានការស្ទាត់ជំនាញ នឹងមានកិច្ចខិតខំប្រឹងប្រែងជាមួយនឹងកិច្ចការប្រយុទ្ធប្រឆាំងនឹងការ ជួញដូរមនុស្ស ព្រមទាំងមានការពេញចិត្តយ៉ាងខ្លាំងក្នុងកាធ្វើអោយមានការផ្លាស់ប្តូរទាក់ទងនឹងការជួញដូរមនុស្ស ក្នុងគ្រួសារ សាលា និងសហគមន៍របស់ពួកគេ។

កម្រងសៀវភៅត្រួសត្រាយ (Vanguard Series) ត្រូវបានចងក្រងរួមបញ្ចូលធនធនបង្កើតថ្មី និងសម្ភារៈឧបទ្ទេស ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងចំណាកស្រុកអសុវត្ថិភាព ដែលបង្កើតដោយកម្មវិធីបញ្ឈប់ការជួញដូរមនុស្ស (ETIP) ។ ទាំងសៀវភៅណែនាំដែលមានចំណងជើងថា ឧបករណ៍សំដែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរ និងសៀវភៅដែលមានចំណងជើងថា ឧបករណ៍នាវិកវៃឆ្លាត សុទ្ធតែរាប់បញ្ចូលក្នុងកម្រងសៀវភៅត្រួសត្រាយផ្លូវ (Vanguard Series) ។

# កំណត់សម្គាល់ស្តីពីពាក្យបច្ចេកទេស

ឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះបានផ្តល់នូវនិយមន័យលើពាក្យថា យុវជន គឺសំដៅលើមនុស្សវ័យក្មេង ដែលមិនមែនជាកុមារ ។ ទោះបីជា អង្គការទស្សនៈពិភពលោក បានចាត់ទុកមនុស្សដែលមានអាយុក្រោម ១៨ឆ្នាំ ជាកុមារក៏ដោយ ក៏សៀវភៅណែនាំនេះ ប្រើពាក្យយុវជន និងក្លឹបយុវជន ដោយសំដៅទៅលើអ្នកដែលមានអាយុចាប់ពី  ១៨ឆ្នាំឡើងទៅ ហើយពួកគេបានទទួលស្គាល់ខ្លួនឯងថាជាយុវជនមិនមែនជាកុមារ។

ពាក្យថា ជនរងគ្រោះ ប្រើសំដៅលើមនុស្សដែលត្រូវបានគេជួញដូរ ។ នេះ គឺដោយសារមានទំនោរស្តីបន្ទោសដល់អ្នកធ្វើចំណាកស្រុកដែលទទួលរងនូវការជួញដូរ ចំពោះអ្វីដែលបានកើតឡើងទៅលើពួកគេ ។ ពាក្យថា ជនរងគ្រោះ ប្រើសម្រាប់បញ្ជាក់ថា អ្នកធ្វើចំណាកស្រុក មិនសុទ្ធតែជាអ្នកដែលត្រូវបានគេជួញដូរនោះឡើយ ។

ពាក្យថា ស្រីពេស្យា ក៏បានប្រើនៅក្នុងឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះដែរ ព្រោះឧបករណ៍នេះ ប្រើសម្រាប់កំណត់ស្ថានភាព ដែលយុវជនត្រូវបានគេបង្ខំឲ្យធ្វើការនៅក្នុងផ្ទះបន ហើយត្រូវបានចាត់ទុកថាជាជនរងគ្រោះ ។ អ្នករកស៊ីផ្លូវភេទ ចង់បង្ហាញថា កិច្ចការនៅក្នុងផ្ទះបន គឺជាមុខរបរមួយ ។ ចំពោះយុវជនដែលត្រូវគេជួញដូរទៅឲ្យផ្ទះបន  មិនមែនជាអ្នករកស៊ីផ្លូវភេទទេ ពីព្រោះយុវជនទាំងនេះ មិនបានជ្រើសរើសយកការប្រកបមុខរបរនៅក្នុងផ្ទះបនឡើយ ហើយពួកគេក៏មិនមានសេរីភាពក្នុងការចាកចេញដែរ ។ ជារឿយៗ ពួកគេមិនទទួលបានប្រាក់ឈ្នួលឡើយ ។

មានករណីសិក្សាជាច្រើននៅក្នុងឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះ បានលើកយករឿងពិតដែលបានកើតឡើងនៅក្នុងឆាកជីវិតរបស់អ្នកធ្វើចំណាកស្រុក ។ ដើម្បីរក្សាកិត្តិយស និងការពារកុំឲ្យមានការស្គាល់ជនរងគ្រោះពិត  អ្នកដែលលើកឡើងនៅក្នុងករណីសិក្សានេះ ត្រូវបានដាក់សម្គាល់ដោយអក្សរដើមនៃឈ្មោះរបស់គេប៉ុណ្ណោះ ។



# មាតិកា


## សេចក្តីផ្តើម:.........................................I

## ម៉ូឌីល១៖ ការរំលឹកឡើងវិញស្តីពីការជួញដូរមនុស្ស.................................... ៦

ទម្រង់លិខិតយល់ព្រមក្នុងម៉ូឌីល១៖ សម្រាប់ការចូលរួមរបស់យុវជន.................................. ៨

ទម្រង់លិខិតយល់ព្រមក្នុងម៉ូឌីល១៖ សម្រាប់ឪពុកម្តាយ ឬអាណាព្យាបាលយល់ព្រមសម្រាប់ការចូលរួមរបស់យុវជន ៩

**មេរៀនទី១.១:** ការរំលឹកដោយសង្ខេបស្តីពីការជួញដូរមនុស្ស ............................................... ១០

IS១.១: បណ្ណនិយមន័យការជួញដូរមនុស្ស.................. ១៥

**មេរៀនទី១.២:** ការរំលឹកឡើងវិញពីច្បាប់ និងកិច្ចព្រមព្រៀង ស្តីពីការជួញដូរមនុស្ស .............................. ២១

IS ១.២: បណ្ណសិទ្ធិកុមារ ............................................. ២៥

**មេរៀនទី១.៣:** ពលកម្មកុមារ ....................................... ២៧

IS១.៣: បណ្ណរូបភាពការងារពលកម្មកុមារ................... ៣០

**មេរៀនទី១.៤:** ការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ(CSEC)............................................ ៣១

## ម៉ូឌីល២: រៀបចំជាស្រេចដើម្បីធ្វើសកម្មភាព៖ ធ្វើផែនការយុទ្ធនាការតស៊ូមតិនិងទិដ្ឋភាពទូទៅអំពីការរៀបចំយុទ្ធនាការតស៊ូមតិ ............ ៣៤

**មេរៀនទី២.១:** ការណែនាំអំពីការតស៊ូមតិ និងទិដ្ឋភាពទូទៅ អំពីការរៀបចំយុទ្ធនាការតស៊ូមតិ ........................ ៣៦

IS ២.១ក: ឧទាហរណ៍នៃការតស៊ូមតិ .......................... ៣៩

IS ២.១ខ: ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ................................................. ៤២

**មេរៀនទី២.២:** កំណត់នូវបញ្ហាគន្លឹះនៃយុទ្ធនាការតស៊ូមតិ.៤៤

IS ២.២ក: សំណួរសកម្មភាពតាមផែនការ .................... ៤៨

IS ២.២ខ: រៀបបញ្ហាតាមលំដាប់................................ ៤៩

**មេរៀនទី២.៣:** ធ្វើការស្រាវជ្រាវអំពីបញ្ហា .................... ៥០

IS ២.៣ក: ការធ្វើបទសម្ភាសន៍ដ៏ល្អ ............................ ៥៦

IS ២.៣ខ: ទម្រង់លិខិតយល់ព្រម សម្រាប់អ្នកផ្តល់បទសម្ភាសន៍ .................................................... ៥៨

IS ២.៣គ: វែបសាយ .................................................. ៥៩

**មេរៀនទី២.៤:** កំណត់វត្ថុបំណងនៃយុទ្ធនាការទស្សនិកជនគោលដៅ និងសារយុទ្ធនាការ.................. ៦០

IS ២.៤ក:ផែនការតស៊ូមតិ ........................................ ៦៥

IS ២.៤ខ:អនុវត្តការកំណត់វត្ថុបំណង កំណត់ ទស្សនិកជនសារយុទ្ធនាការ និងសកម្មភាព.................................. ៦៧

**មេរៀនទី២.៥:** ធ្វើផែនការសកម្មភាព ពេលវេលា និង ថវិការសម្រាប់យុទ្ធនាការតស៊ូមតិ......................... ៧០

**មេរៀនទី២.៦:** ធ្វើការវាយតម្លៃនិងកាត់បន្ថយហានិភ័យ(គ្រោះថ្នាក់) នៅពេលធ្វើផែនការតស៊ូ........... ៧៥

IS ២.៦ក: សំណួរសុវត្ថិភាព........................................ ៧៩

IS ២.៦ខ: ចាត់ចំណាត់ថ្នាក់ហានិភ័យ......................... ៨០

IS ២.៦គ: ទម្រង់លិខិតយល់ព្រមសម្រាប់យុទ្ធនាការតស៊ូមតិ-អ្នកចូលរួម.................................................. ៨១

IS ២.៦ឃ: ទម្រង់លិខិតយល់ព្រមសម្រាប់ឪពុកម្តាយឬអាណាព្យាបាលអ្នកចូលរួមដែលមានអាយុក្រោម១៨ឆ្នាំ .................................................... ៨២

**មេរៀនទី២.៧:** អនុវត្តផែនការយុទ្ធនាការតស៊ូមតិ ................................................... ៨៣

**មេរៀនទី២.៨:** វាយតម្លៃយុទ្ធនាការតស៊ូមតិ.................. ៨៥

IS ២.៨ក:ការវាយតម្លៃ.............................................. ៨៥

**មេរៀនទី២.៩:** ការធ្វើផែនការតស៊ូមតិសម្រាប់ពេល អនាគត............................................... ៨៩

IS ២.៩ក:ផែនការតស៊ូមតិនៅពេលអនាគត ................ ៨៥

## ឯកសារយោង ក ..............................៩៥

កំណត់សម្គាល់...................................................... ១០៥

# សេចក្ដីផ្ដើម

ឧបករណ៍សម្ដែងមតិដើម្បីឲ្យមានការផ្លាស់ប្ដូរនេះផ្ដល់នូវការណែនាំជាជំហានៗអំពីរបៀបរៀបចំយុទ្ធនាការប្រកបដោយជោគជ័យ ប្រឆាំងនឹងការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព ។ ឧបករណ៍សម្ដែងមតិដើម្បីឲ្យមានការផ្លាស់ប្ដូរនេះ ក៏បានផ្ដល់ឱកាសក្នុងការកសាងសមត្ថភាព និង ជំនាញសម្រាប់ដោះស្រាយនូវបញ្ហាធ្ងន់ធ្ងរបំផុតដែលប៉ះពាល់ដល់ពួកគេផងដែរ។ ឧបករណ៍សម្ដែងមតិដើម្បីឲ្យមានការផ្លាស់ប្ដូរនេះ ត្រូវបានបែងចែកជាម៉ូឌីលចំនួនពីរ ៖

## ម៉ូឌីល ១ – ការរំលឹកអំពីការជួញដូរមនុស្ស

ម៉ូឌីលទី១ គឺការរំលឹកឡើងវិញទៅលើចំណេះដឹងស្ដីពីការជួញដូរមនុស្ស ដែលអ្នកចូលរួមបានរៀនរួចហើយពីក្នុងសៀវភៅណែនាំ ដែលមានចំណងជើងថា ឧករណ៍នាវិកវៃឆ្លាត ។

## ម៉ូឌីល ២ –រៀបចំជាស្រេចដើម្បីធ្វើសកម្មភាព ៖ ធ្វើផែនការយុទ្ធនាការតស៊ូមតិរបស់អ្នក

ម៉ូឌីលទី២គឺណែនាំពីការតស៊ូមតិដោយពន្យល់ពីវិធីដែលវាអាចចូលរួមចំណែកដើម្បីអោយមានការផ្លាស់ប្ដូរក្នុងសហគមន៍។  ហើយបន្ទាប់មកវាពិព័ណ៌នាពីសកម្មភាពប្លែកៗដែលនឹងជួយយុវជនអោយបង្កើតយុទ្ធនាការផ្ទាល់ខ្លួនរបស់ពួកគេ។ សកម្មភាពគឺត្រូវបានចងក្រងដើម្បីកំណត់រកបញ្ហា ទស្សនិកជនគោលដៅ គោលបំណង ទិសដៅសំខាន់និងសារ អ្នកគាំទ្រ និងវិធីអនុវត្តយុទ្ធនាការ។ វាផ្ដល់ផងដែរនូវព័ត៌មាននិងសម្ភារៈឧបទ្ទេស សម្រាប់អ្នកសម្របសម្រួលជាមនុស្សពេញវ័យដើម្បីផ្ដល់ការគាំទ្រតាមដានកុមារ និងយុវជន ក៏ដូចជាសម្ភារៈឧបទ្ទេស  និងដំណើរការសម្រាប់តាមដានសកម្មភាពយុវជនដើម្បីឲ្យប្រាកដថាកុមារនិងយុវជនមាន អារម្មណ៍សុវត្ថិភាពក្នុងអំឡុងពេលអនុវត្តយុទ្ធនាការ។   ម៉ូឌីលនេះណែនាំផងដែរពីប្រព័ន្ធផ្សព្វផ្សាយបណ្ដាញសង្គមការពន្យល់ពីវិធីដែលវាអាចត្រូវបានប្រើដើម្បីពង្រឹងការតស៊ូមតិ។ វាពន្យល់អ្នកចូលរួមពីវិធីទទួលយកការប្រុងប្រយ័ត្នដើម្បីរក្សាសុវត្ថិភាពដើម្បីជីវិតជាក់ស្ដែងក្នុងពិភពលោក។  ជាចុងក្រោយម៉ូឌីលទីពីរដឹកនាំយុវជន តាមរយៈដំណើរការប្រមូលព័ត៌មានទាក់ទងនឹងហានិភ័យ ដើម្បីជួយទប់ស្កាត់យុវជនតស៊ូមតិពីការផ្សាភ្ជាប់ក្នុងសកម្មភាពតស៊ូមតិដែលអាចត្រូវបានធ្វើអោយប៉ះពាល់ និងខូចប្រយោជន៍ដល់សុខមាលភាពនិងសុវត្ថិភាពរបស់ពួកគេ។

## ការវាយតម្លៃ

ផ្នែកចុងក្រោយនៃមេរៀន គឺផ្ដោតទៅលើការវាយតម្លៃ ។ ការផ្ដោតបែបនេះ ជួយដល់យុវជន ឲ្យចេះឆ្លុះបញ្ចាំងនូវអ្វីដែលពួកគេបានរៀន សម្រាប់ជួយដល់អង្គការទស្សនៈពិភពលោក  កែលំអនូវកម្មវិធីបណ្ដុះបណ្ដាលរបស់ខ្លួន ។ ការវាយតម្លៃ គួរធ្វើឡើងបន្ទាប់ពីការបណ្ដុះបណ្ដាល និងបន្ទាប់ពីយុទ្ធនាការតស៊ូមតិ ។

## តើការណែនាំនេះសម្រាប់នរណា ?

ឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះ ត្រូវបានរៀបចំឡើងសម្រាប់អ្នកសម្របសម្រួលជាមនុស្សពេញវ័យប្រើប្រាស់ ខណៈពេលដែលពួកគេធ្វើការជាមួយនឹងក្រុមយុវជន ដែលមានអាយុចាប់ពី ១៨ឆ្នាំ ។ អ្នកសម្របសម្រួលមនុស្សពេញវ័យទាំងនោះសុទ្ធតែបានចូលរួមរួចហើយជាមួយនឹងក្លឹបនារីកវែគ្លាត ហើយចាប់អារម្មណ៍នៅក្នុងការរៀបចំការតស៊ូមតិសម្រាប់បញ្ហាការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

ឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរ ក៏នឹងត្រូវយកមកណែនាំ នៅក្នុងសិក្ខាសាលារយៈពេលបីថ្ងៃដល់អ្នកចូលរួម ហើយបន្ទាប់ពីសិក្ខាសាលានេះ ពួកគេនឹងវិលត្រឡប់ទៅសហគមន៍ពួកគេវិញដើម្បីដឹកនាំក្លឹបយុវជនរបស់ពួកគេតាមរយៈដំណើរការនៃការរៀបចំយុទ្ធនាការតស៊ូមតិ ។ ឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រើប្រាស់ជាឧបករណ៍ទាំងនៅក្នុងសិក្ខាសាលាសម្រាប់រយៈពេលបីថ្ងៃ និងនៅពេលអ្នកចូលរួមត្រឡប់ទៅដឹកនាំសកម្មភាពតស៊ូមតិនៅក្នុងសហគមន៍របស់ពួកគេ ។

ឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះត្រូវបានរៀបចំឡើងដើម្បីប្រើប្រាស់សម្រាប់ក្រុមកុមារដែលមានគ្នាប្រហែលជា ២០នាក់ ។ ប្រសិនបើក្រុមកុមារមានចំនួនច្រើនជាងនេះព្យាយាមបំបែកក្រុមកុមារនេះជាពីរក្រុមផ្សេងៗគ្នា ។

## អ្នកសម្របសម្រួលជាមនុស្សពេញវ័យ

ក្រុមយុវជននីមួយៗ ត្រូវមានការគាំទ្រដោយសមាជិកបុគ្គលិកពេញវ័យរបស់អង្គការទស្សនៈពិភពលោកដែលធានាថាកុមារនឹងមិនត្រូវទទួលទុក្ខទោសដោយសារការតស៊ូមតិនេះទេ ។ នៅក្នុងដំណាក់កាលនីមួយៗនៃគម្រោងនេះនោះអ្នកសម្របសម្រួលជាមនុស្សពេញវ័យ គួរបន្តជួយដល់យុវជនក្នុងការវាយតម្លៃហានិភ័យ ។ អ្នកសម្របសម្រួលជាមនុស្សពេញវ័យ គឺជាអ្នកធ្វើសេចក្តីសម្រេចចិត្តចុងក្រោយថាតើគម្រោងនេះ មានសុវត្ថិភាពគ្រប់គ្រាន់សម្រាប់បន្តទៀតដែរ ឬក៏អត់ ។

តួនាទីពីររបស់មនុស្សពេញវ័យ គឺត្រូវជួយផ្តល់នូវការគាំទ្រដល់សកម្មភាពគម្រោង ។ មនុស្សពេញវ័យទាំងនេះអាចជាបុគ្គលិករបស់អង្គការទស្សនៈពិភពលោក/បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ឬសមាជិកផ្សេងទៀតរបស់សហគមន៍ដូចជាគ្រូបង្រៀន មន្ត្រីអាជ្ញាធរមូលដ្ឋាន ។ល។ មនុស្សពេញ វ័យទាំងនេះ ផ្តល់នូវការគាំទ្រដល់កុមារដើម្បីជួយពួកគេនៅក្នុងការរៀបចំយុទ្ធនាការតស៊ូមតិ។ យុវវ័យនៅក្នុងតួនាទីនេះ ត្រូវប្រាកដថាខ្លួនពិតជាបានអនុញ្ញាតឲ្យកុមារធ្វើការដឹកនាំ ដោយឲ្យពួកគេចេះបំផុសគំនិត ធ្វើសេចក្តីសម្រេចចិត្ត និងធ្វើកិច្ចការបានច្រើនបំផុតដោយខ្លួនឯង។

## តើអ្នកត្រូវការអ្វីខ្លះ សម្រាប់ការបណ្តុះបណ្តាល ?

ការបណ្តុះបណ្តាលអំពីឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះ គួរធ្វើឡើងនៅក្នុងបន្ទប់ស្ងាត់ ហើយអ្នកដែលមិនត្រូវចូលរួមនៅក្នុងការបណ្តុះបណ្តាល មិនគួរអនុញ្ញាតឲ្យឈរមើលទេ ។

តាមស្តង់ដាររបស់មេរៀន តម្រូវឲ្យមានប៊ិចសម្រាប់សមាជិកក្រុមទាំងអស់ និងក្រដាសផ្លីបឆាតជាច្រើនសន្លឹក។ មេរៀននីមួយៗ ក៏ត្រូវដាក់បញ្ចូលនូវបញ្ជីសម្ភារឧបទេសសម្រាប់មេរៀនជាក់លាក់ណាមួយនោះដែរ ។

ពេលវេលា សម្រាប់មេរៀននីមួយៗ គឺត្រូវកំណត់ក្នុងចំនួនប្រហាក់ប្រហែល ។ ពេលវេលាបណ្តុះបណ្តាលនេះ អាចមានរយៈពេលវែង ឬខ្លី អាស្រ័យលើចំណេះដឹងពីមុនរបស់អ្នកចូលរួម ។

មេរៀន ត្រូវបង្រៀនតាមលំដាប់របស់វា ព្រោះថានេះគឺជាការណែនាំតាមជំហាននីមួយៗ ។ មេរៀនភាគច្រើន ចាប់ផ្តើមដោយល្បែងទាក់ទាញអារម្មណ៍ ដែលអាចរកបាននៅក្នុងសម្ភារឧបទ្ទេស ។

## មុនពេលចាប់ផ្តើមសិក្ខាសាលា

វាមានសារសំខាន់ណាស់ដែលត្រូវស្វាគមន៍ និងដាក់បញ្ចូលយុវជនគ្រប់រូបនៅក្នុងសកម្មភាពរបស់សិក្ខាសាលា ។ សិក្ខាសាលា មិនគួររើសអើងយុវជនណាមួយនោះទេ ប៉ុន្តែគួរស្វាគមន៍យុវជនគ្រប់ប្រភេទទាំងអស់ ៖

- ដែលមានប្រភពមកពីគ្រួសារអ្នកមាន និងគ្រួសារអ្នកក្រ
- ដែលបានចូលសាលារៀន និងមិនចូលសាលារៀន
- ដែលមានប្រភពមកពីសាសនាផ្សេងៗ
- ដែលមានសារតារ ពូជសាសន៍ ឬជនជាតិមកពីប្រទេសផ្សេងៗគ្នា
- ដែលជាជនពិការ ។

វាពិតជាមិនអាចមានលទ្ធភាពឲ្យយុវជនផ្សេងៗគ្នាទាំងនេះចូលរួមនៅក្នុងសិក្ខាសាលាបានទេ ប៉ុន្តែវាជាការសំខាន់ណាស់ដែលត្រូវគាំទ្រដល់ពួកគេក្នុងការចូលរួមឲ្យបានច្រើនបំផុត ប្រសិន បើអាចធ្វើបាន ។ ការធ្វើដូច្នេះពីព្រោះថាការតស៊ូមតិ រឹតតែប្រសើរ ប្រសិនបើវាតំណាងឲ្យសម្លេង និងបទពិសោធន៍របស់យុវជនផ្សេងៗគ្នា ។

## ការការពារកុមារ

អ្នកសម្របសម្រួល ត្រូវអនុវត្តតាមគោលនយោបាយការពារកុមាររបស់អង្គការទស្សនពិភព លោកដែលបានដាក់បញ្ចូលនៅទីនេះ ឈ្មោះឧបសម្ព័ន្ធ ក ។

## ការយល់ព្រម

ការចូលរួមនៅក្នុងក្លឹបយុវជន និងនៅក្នុងយុទ្ធនាការតស៊ូមតិ គឺធ្វើឡើងដោយស្ម័គ្រចិត្ត ។ អ្នក ៖

- អាចសម្រេចចិត្តថាតើអ្នកចង់ចូលរួមនៅក្នុងក្លឹបនេះដែរ ឬក៏អត់ ។
- មានសេរីភាពក្នុងការលាឈប់ពីសកម្មភាពតស៊ូមតិនៅពេលណាក៏បាន ។
- សម្រេចថាតើអ្នកចង់ជួយដល់សកម្មភាពតស៊ូមតិនេះដែរ ឬទេ ដោយអ្នកមិនចាំបាច់ដើរតួនាទីសាធារណៈឡើយ ( ឧទាហរណ៍យុវជនអាចសម្រេចចិត្តជួយរៀបចំក្លឹប ប៉ុន្តែមិនចាំបាច់ ចូលរួមនៅក្នុងព្រឹត្តិការណ៍ណាមួយនៅខាងក្រៅក្លឹបទេ ) ។
- មានសេរីភាពធ្វើការតស៊ូមតិទៅលើប្រធានបទផ្សេងៗ
- ទទួលបានការជូនដំណឹងជាមុនអំពីវត្ថុបំណង និងសកម្មភាពដែលបានគ្រោងទុកនៅក្នុងយុទ្ធនាការតស៊ូមតិ ។

នៅពេលចាប់ផ្តើមធ្វើសិក្ខាសាលា ទាំងយុវជន និងអ្នកថែទាំ/ឪពុកម្តាយ ត្រូវចុះហត្ថលេខាលើទម្រង់យល់ព្រម នៅមុនពេលចាប់ផ្តើមសកម្មភាពតស៊ូមតិ ដើម្បីវាយតម្លៃគ្រោះថ្នាក់ ដោយទទួលស្គាល់ថាពួកគេបានយល់ដឹងច្បាស់ថាពួកគេអាចចូលរួមក៏បាន ឬមិនចូលរួមក៏បាន ។

## គាំទ្រអ្នករងគ្រោះពីការប៉ះទង្គិចផ្លូវចិត្ត

ការជួញដូរមនុស្ស គឺជាប្រធានបទដ៏រសើប ។ នៅក្នុងកំឡុងពេលធ្វើយុទ្ធនាការតស៊ូមតិ  យុវជនអាចដឹងអំពីបញ្ហាដែលធ្វើឲ្យពួកគេមិនសប្បាយចិត្ត ។ ប្រធានបទរសើបដែលបានយកមកពិភាក្សា អាចធ្វើឲ្យយុវជននឹកឃើញឡើងវិញ និងពិភាក្សានូវរឿងរ៉ាវ ស្មុគស្មាញ និងរឿងរ៉ាវមិនសប្បាយចិត្តរបស់ពួកគេ ដែលបានកើតឡើងចំពោះពួកគេកាលពីអតីតកាល ។ អ្នកសម្របសម្រួល ជាមនុស្សពេញវ័យ គួរប៉ាន់ស្មានអំពីស្ថានភាពនេះ ។ មុននឹងចាប់ផ្តើមយុទ្ធនាការ នោះអ្នកសម្របសម្រួលគួរកំណត់នូវសេវាគាំទ្រ ដែលអាចស្នើសុំជំនួយបានប្រសិនបើយុវជនមានការព្រួយបារម្ភ ហើយអាចទាក់ទងសេវាទាំងនេះបាន ប្រសិនបើចាំបាច់នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាលនេះ ។

# រាយការណ៍អំពីស្ថានភាពគ្រោះថ្នាក់

នៅក្នុងដំណើរការនៃការបណ្តុះបណ្តាល និងការតស៊ូមតិនេះ យុវជនអាចនិយាយទៅកាន់អ្នកសម្របសម្រួលអំពីស្ថានភាពលំបាកនៅក្នុងជីវិតរបស់ពួកគេ ។ ប្រសិនបើយុវជន ប្រាប់អ្នកសម្របសម្រួល ថាពួកគេស្ថិតនៅក្នុងភាពគ្រោះថ្នាក់ នោះអ្នកសម្របសម្រួលគួរធ្វើតាមផែនការឆ្លើយតបរបស់អង្គការទស្សនពិភពលោកភ្លាមៗ ដែលបានដាក់បញ្ចូលនៅខាងក្រោមនេះ ។

ការិយាល័យមួយចំនួន ប្រហែលជាមានផែនការរៀបចំឆ្លើយតបនឹងឧបទ្ទវហេតុដើម្បីការពារ កុមារកម្រិត ១ [Level 1 Child Protection Incident Preparedness Plan ( L1 CPIPP)] ដែលបានដាក់បញ្ចូលនៅក្នុងផែនការលម្អិត ។ សូមសួរមន្ត្រីការពារកុមារដែលធ្វើការនៅការិយាល័យនេះ ថាតើមានផែនការដូចនេះពីមុនដែរឬ ទេ ។ បើគ្មានទេ នោះមន្ត្រីរបស់អង្គការទស្សនៈពិភពលោក ដែលប្រចាំនៅប្រទេសនោះ គួរដាក់បញ្ចូលរួមគ្នានូវផែនការឆ្លើយតបដែលបានបង្ហាត់បង្ហាញថាតើបុគ្គលិក របស់អង្គការទស្សនៈពិភពលោក គួរឆ្លើយតបយ៉ាងដូចម្តេច ប្រសិនបើកុមារ បានរាយការណ៍ថាពួកគេ កំពុងទទួលរងគ្រោះពីការរំលោភបំពានផ្លូវកាយ និងផ្លូវភេទនោះ ។

ផែនការឆ្លើយតបនោះ ត្រូវដាក់បញ្ចូលនូវចំណុចខាងក្រោមនេះ ៖

- និតិវិធីដែលត្រូវអនុវត្តតាម ប្រសិនបើកុមារបានរាយការណ៍អំពីការរំលោភបំពាន រួមមានការរៀបរាប់លម្អិតនូវតួនាទីរបស់បុគ្គលិកអង្គការទស្សនៈពិភពលោកដែលមានការពាក់ព័ន្ធ ឬ របស់អង្គការក្រៅរដ្ឋាភិបាលដៃគូនៅក្នុងដំណើរការនេះ ។
- ការពន្យល់របស់អង្គការទស្សនៈពិភពលោក អំពីផែនការឆ្លើយតបទៅនឹងកុមារដែលមានបញ្ហា ។
- លេខទូរស័ព្ទទំនាក់ទំនងរបស់បុគ្គលិកអង្គការទស្សនៈពិភពលោក ដែលពាក់ព័ន្ធឬអង្គការក្រៅ

រដ្ឋាភិបាលដៃគូ ដែលនឹងឆ្លើយតបដោយចាត់វិធានការដើម្បីការពារកុមារដែលបានរាយការណ៍អំពីការរំលោភបំពាន ។

- វិធីសាស្ត្រការពារភ្លាមៗ ដល់កុមារដែលរាយការណ៍អំពីការរំលោភបំពាន ដើម្បីទប់ស្កាត់ការសងសឹកពីអ្នកដែលបានធ្វើការរំលោភបំពាន ។
- ការទំនាក់ទំនងជាមួយនឹងសេវាផ្តល់ការប្រឹក្សាក្នុងមូលដ្ឋាន

ឧទាហរណ៍នៃស្ថានភាពគ្រោះថ្នាក់ រួមមានដូចខាងក្រោម ៖

- មនុស្សម្នាក់ ដែលកំពុងត្រូវបានរំលោភបំពានផ្លូវកាយ ។
- មនុស្សម្នាក់ ដែលកំពុងត្រូវបានរំលោភបំពានផ្លូវភេទ ។
- មនុស្សម្នាក់ ដែលអ្នកជួញដូរមនុស្ស កំពុងសំដៅទៅរក។
- មនុស្សម្នាក់ដែលធ្វើការគ្រោះថ្នាក់ ។

បញ្ជីនេះ មិនបានរាប់បញ្ចូលនូវស្ថានភាពគ្រោះថ្នាក់ទាំងអស់នោះទេ ។

# វិធីសាស្ត្រសម្របសម្រួលការបណ្តុះបណ្តាល ឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរ

## ធ្វើឲ្យមានសុវត្ថិភាព

អ្នកសម្របសម្រួលគួរ ៖

- និយាយទៅកាន់យុវជនដោយការគោរព ស្មើភាពគ្នា ។
- ហាមប្រើប្រាស់ឈ្មោះដែលមានលក្ខណៈមើលងាយទៅលើយុវជននៅក្នុងក្លឹប ឬជាលក្ខណៈ ឯកជន ។
- អញ្ជើញយុវជនទាំងអស់មកចូលរួម (កត់សម្គាល់ទៅលើយុវជនដែលស្ងៀមស្ងាត់ ប៉ុន្តែហាមបង្ខំឲ្យពួកគេនិយាយ ឬចូលរួម) ។
- ហាមសួរដោយផ្ទាល់អំពីជីវិតរបស់មនុស្សវ័យក្មេងទាំងនោះ ប៉ុន្តែផ្ទុយមកវិញត្រូវសួរអំពីជីវិតរបស់យុវជនផ្សេងទៀត ដែលស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានេះ ។
- ហាមនិយាយអំពីជីវិតរបស់យុវជននៅក្នុងក្លឹបដល់មនុស្សនៅខាងក្រៅក្លឹប ។

## ធ្វើឲ្យមានភាពរីករាយ

ការសិក្សាតាមឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះ ត្រូវធ្វើឲ្យយុវជនមានភាពរីករាយ ។ ប្រសិនបើមានភាពរីករាយនោះយុវជន នឹងបន្តមកចូលរួមនៅក្នុងក្លឹប ហើយនឹងចងចាំនូវព័ត៌មានបានច្រើន ។ ដើម្បីធ្វើឲ្យមានបរិយាកាសរីករាយ នោះសូមពិចារណានូវសកម្មភាពដូចខាងក្រោម ៖

- ប្រើប្រាស់ ល្បែងទាក់ទាញអារម្មណ៍ ដោយដកស្រង់ចេញពីសម្ភារឧបទ្ទេស ។
- អង្គុយជារង្វង់ជាមួយនឹងយុវជន មិនមែនអង្គុយនៅខាងមុខថ្នាក់រៀនទេ ។
- សួរសំណួរឲ្យបានច្រើន ហាមនិយាយយូរពេកដោយមិនបានសួរសំណួរណាមួយសោះ
- សម្លឹងមើលភ្នែកយុវជន (ប្រសិនបើ នេះជាការសមស្របនឹងវប្បធម៌របស់ប្រទេសនោះ)
- ធ្វើកាយវិការដៃរបស់អ្នកខណៈពេលដែលអ្នកកំពុងនិយាយ ។
- ប្រើប្រាស់ពាក្យពេជន៍ និងភាសាដែលយុវជនប្រើប្រាស់ ។

## ផ្តល់ឲ្យយុវជនដឹកនាំ

ឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះ បានរំពឹងទុកថាយុវជននឹងមានសមត្ថភាពដឹកនាំយុទ្ធនាការតស៊ូមតិ ។ បញ្ហា និងវិធីសាស្ត្រ សម្រាប់ការតស៊ូមតិ នឹងត្រូវជ្រើសរើសដោយយុវជន ។ ភាគច្រើននៃសកម្មភាព តស៊ូមតិ ក៏នឹងត្រូវសម្រេច និងអនុវត្តដោយយុវជនផងដែរ ។ អ្នកសម្របសម្រួល គួរជួយយុវជនប្រសិនបើពួកគេស្នើសុំជំនួយ ប៉ុន្តែហាមដឹកនាំដោយខ្លួនឯង ។

# ផ្នែកទី១ ៖

## ការរំឭកឡើងវិញស្ដីពីការជួញដូរមនុស្ស





# ទម្រង់លិខិតយល់ព្រមក្នុងម៉ូឌីលទី ១ ៖ សម្រាប់អ្នកចូលរួមជាយុវជន

- វគ្គបណ្តុះបណ្តាលនេះ នឹងធ្វើឲ្យអ្នកទទួលបានព័ត៌មានស្តីពីការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស ។
- ការចូលរួមរបស់អ្នក នៅក្នុងការបណ្តុះបណ្តាលនេះ ធ្វើឡើងដោយស្ម័គ្រចិត្ត ហើយអ្នកអាចឈប់ចូលរួមនៅពេលណាក៏បាន ។
- ក្នុងពេលទទួលការបណ្តុះបណ្តាល អ្នកអាចសម្រេចចិត្តជ្រើសរើសឆ្លើយតែសំណួរណាដែលអ្នកចង់ឆ្លើយ ។ ប្រសិនបើអ្នកមិនចង់និយាយ អ្នកអាចនៅស្ងៀមបាន ។

ខ្ញុំបានអាន និងបានយល់អំពីព័ត៌មានខាងលើនេះហើយ ។
ខ្ញុំសុខចិត្តចូលរួមនៅក្នុងការបណ្តុះបណ្តាលនេះ ។
ខ្ញុំយល់ច្បាស់ថា ខ្ញុំអាចឈប់ចូលរួមពេលណាក៏បាន ។

ឈ្មោះ ________________________ កាលបរិច្ឆេទ ____________________________

ហត្ថលេខា ________________________________________________________

## ទម្រង់លិខិតយល់ព្រមនៅក្នុងផ្នែកទី១ ៖ សម្រាប់ឪពុកម្តាយ ឬអ្នកថែទាំរបស់អ្នកចូលរួមដែលជាយុវជន

សំគាល់៖ ឪពុកម្តាយ/អ្នកថែទាំ ត្រូវចុះហត្ថលេខាលើទម្រង់លិខិតយល់ព្រមជាសិន មុននឹងចាប់ផ្តើមមេរៀននេះ។

- វគ្គបណ្តុះបណ្តាលនេះ នឹងផ្តល់អោយកូនរបស់អ្នកទទួលបានព័ត៌មាន ស្តីពីការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស។ ការចូលរួមរបស់កូនអ្នកនៅក្នុងការបណ្តុះបណ្តាលនេះ គឺធ្វើឡើងដោយស្ម័គ្រចិត្ត ។ អ្នកអាចចម្រេចចិត្តឲ្យកូនឈប់នៅពេលណាក៏បាន ។
- ពេលកំពុងទទួលការបណ្តុះបណ្តាល កូនរបស់អ្នកអាចឆ្លើយតែសំណួរណា ដែលខ្លួនចង់ឆ្លើយប៉ុណ្ណោះ ។ ប្រសិនបើកូនរបស់អ្នក មិនចង់និយាយទេ កូនរបស់អ្នកអាចនៅស្ងៀមបាន ។

ខ្ញុំបានអាន និងបានយល់ព័ត៌មានខាងលើនេះហើយ ។
ខ្ញុំអនុញ្ញាតឲ្យកូនខ្ញុំចូលរួមនៅក្នុងការបណ្តុះបណ្តាលនេះ ។
ខ្ញុំយល់ច្បាស់ថា ខ្ញុំអាចឲ្យកូនឈប់ចូលរួមពេលណាក៏បាន ។

ឈ្មោះ ______________________________ កាលបរិច្ឆេទ __________________________________

ហត្ថលេខា ______________________________________________________________________



# មេរៀនទី១.១ ៖ ការរំឭកដោយសង្ខេប ស្តីពីការជួញដូរមនុស្ស

## វត្ថុបំណង ៖

អ្នកចូលរួមនឹងអាចកំណត់និយមន័យនៃពាក្យ ការជួញដូរ និងការធ្វើចំណាកស្រុក ហើយអាចភ្ជាប់និយមន័យ នេះទៅក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃ ។

***កំណត់សម្គាល់ទូទៅ ៖ មេរៀនទាំងអស់ត្រូវការក្រដាសផ្លីបឆាត ហ្វឺតសរសេរនិងប៊ិច ។ ចំពោះសម្ភារៈក្រៅពីនេះ មាននៅក្នុងបញ្ជីសម្ភារៈខាងក្រោមនេះ ៖***

## រយៈពេល ៖

៧៥ នាទី

## សម្ភារៈ

- កូនសៀវភៅនារីកវៃឆ្លាតសម្រាប់ចែកជូនអ្នកចូលរួមគ្រប់ៗគ្នា
- ប័ណ្ណព័ត៌មានលេខ ១.១ ៖ កាតនិយមន័យនៃការជួញដូរ (១ ដុំសន្លឹកកិច្ចការ សម្រាប់អ្នកចូលរួម១ក្រុមពីរនាក់)

## ការរៀបចំ

មុននឹងចាប់ផ្តើមមេរៀននៅក្នុងម៉ូឌីល នេះត្រូវធ្វើយ៉ាងណាឲ្យឪពុកម្តាយ / អ្នកថែទាំរបស់អ្នកចូលរួមវ័យក្មេង ចុះហត្ថលេខាលើទម្រង់លិខិតយល់ព្រមនៃប័ណ្ណព័ត៌មាន សម្រាប់ឪពុកម្តាយ ឬកូនរបស់គាត់ ។

## សេចក្តីផ្តើម

ចូរស្វាគមន៍យុវជននិងណែនាំកុមារឲ្យចូលក្នុងក្រុម។ ត្រូវឲ្យយុវជនណែនាំខ្លួនជាមុនសិន ប្រសិនបើពួកគេពុំទាន់បានស្គាល់គ្នាពីមុនមក។ ត្រូវលេងល្បែងទាក់ទាញអារម្មណ៍។ ត្រូវបញ្ជាក់បន្ថែមអំពីតារាងកាលវិភាគនៃវគ្គបណ្តុះបណ្តាល ។

## ខ្លឹមសារក្នុងឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរ

ចូរពន្យល់ថា ម៉ូឌីលទី១ ដែលមាននៅក្នុងឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរនេះត្រូវបាន បង្កើតឡើងសម្រាប់អ្នកចូលរួម ដែលទទួលបានការបណ្តុះបណ្តាល ពីបញ្ហា ការជួញដូរ មនុស្ស និងការធ្វើចំណាកស្រុករួចហើយ ទាក់ទង នឹងបញ្ហានៃការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដែល មាននៅក្នុងឧបករណ៍សម្តែងមតិដើម្បីឲ្យមានការផ្លាស់ប្តូរអ្នកតម្រង់ទិសឆ្លាតវៃ។ ម៉ូឌីលនេះត្រូវបានរៀបចំ ឡើងសម្រាប់ជួយដល់អ្នកចូលរួមក្នុងការរំឭកឡើងវិញនូវចំណេះដឹងស្តីពីគ្រោះថ្នាក់ ដែលមនុស្សជួបប្រទះ នៅពេលរកការងារធ្វើ។ ម៉ូឌីលនេះ ផ្តល់ព័ត៌មានស្តីពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ពលកម្មកុមារ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ។

## ការរំឭកនិយមន័យ

### ចូរសួរទៅកាន់អ្នកចូលរួមថា តើមានអ្នកណាម្នាក់នៅចាំនិយមន័យនៃពាក្យ "ការធ្វើចំណាកស្រុក" ឬទេ

ចូរពន្យល់ថា **ការធ្វើចំណាកស្រុក** មានន័យថា គឺការដែលមនុស្សផ្លាស់ទីទៅកន្លែងផ្សេងដើម្បី រកការងារការងារធ្វើ ។ **អ្នកធ្វើចំណាកស្រុក** សំដៅលើមនុស្សដែលធ្វើចំណាកស្រុក ។ ចូរពន្យល់ថា ការធ្វើចំណាកស្រុក

គឺជារឿងល្អ ព្រោះវាអាចធ្វើអោយមនុស្សវ័យក្មេងអាចរកការងារបានធ្វើ ស្គាល់កន្លែងថ្មីៗ ឬអាចទទួលបានការអប់រំ ជាដើម។មានមនុស្សជាច្រើននៅក្នុងបន្ទប់នេះ អាចនឹងកំពុងគិតអំពីការធ្វើចំណាកស្រុក។ប៉ុន្តែការធ្វើចំណាកស្រុក ក៏អាចមានគ្រោះថ្នាក់ដែរ។ មានមនុស្សជាច្រើនដែល ចង់កេងចំណេញឬបោកបញ្ឆោតអ្នកធ្វើចំណាកស្រុកក្មេងៗ ដើម្បីរកប្រាក់ចំនេញ។ បុគ្គលទាំងអស់នោះ អាចធ្វើឲ្យមនុស្សវ័យក្មេង ធ្លាក់ចូលទៅក្នុងបញ្ហាដ៏ធ្ងន់ធ្ងរ ។

## ចូរសួរទៅក្រុម តើមានអ្នកណាអាចអោយនិយមន័យនៃការជួញដូរបានទេ

ចូរពន្យល់ថា ការជួញដូរមនុស្ស គឺជាការបោកបញ្ឆោត ឬការបង្ខំមនុស្សឲ្យធ្លាក់ចូលទៅក្នុងទម្រង់នៃការកេងប្រវ័ញ្ចក្នុងការងារ ដែលធ្វើអោយ ជនរងគ្រោះដោយការជួញដូរនោះ មានការពិបាកក្នុងការដកខ្លួនចេញ។ ជារឿយៗ ការជួញដូរមនុស្សកើតឡើងដោយការយកជនរងគ្រោះ ចេញពីកន្លែងដែលពួកគាត់រស់នៅដោយការបង្ខិតបង្ខំ ឬបោកប្រាស់ ដើម្បីកេងប្រវ័ញ្ចលើពួកគាត់។ ប៉ុន្តែការជួញដូរមនុស្សក៏អាចកើតឡើង ដោយមិនចាំបាច់មានការផ្លាស់ទីកន្លែងដែរ។

## ចូរសួរនរណាម្នាក់នៅក្នុងក្រុមអោយពន្យល់ពីភាពខុសគ្នា រវាងការជួញដូរមនុស្ស និង ការរត់ពន្ធមនុស្ស

ចូរពន្យល់ថា ការជួញដូរមនុស្ស មានលក្ខណៈខុសគ្នាពី ការរត់ពន្ធមនុស្ស។ អ្នកដែលត្រូវបានគេរត់ពន្ធជាអ្នកដែលចំណាយប្រាក់ឲ្យគេជួយនាំគាត់លួចឆ្លងដែន ដោយមិនស្របច្បាប់។ បុគ្គលខ្លះជ្រើសរើសអោយគេរត់ពន្ធ។ ទោះបីអ្នកដែលត្រូវបានគេរត់ពន្ធចំណាយប្រាក់អោយគេនាំខ្លួនទៅក៏ដោយ ហើយអាចជំពាក់ប្រាក់គេនៅពេលដែលដំណើរនេះត្រូវបានបញ្ចប់ ជាធម្មតាពួកគេត្រូវមានសិទ្ធិសេរីភាពដើរហើរនៅពេលទៅដល់ប្រទេសគោលដៅ។ អ្នកដែលត្រូវគេជួញដូរ គ្មានសិទ្ធិសេរីភាពឡើយ ប៉ុន្តែ មិនមែនមានន័យថា ការរត់ពន្ធមានសុវត្ថិភាពឡើយ។ មនុស្សដែលត្រូវគេរត់ពន្ធឆ្លងកាត់ព្រំដែនអន្តរជាតិ ត្រូវប្រឈមមុខនឹងការប្រថុយប្រថានជាច្រើន។ ពួកគាត់អាចនឹងត្រូវអ្នករត់ពន្ធរំលោភបំពាន ឬត្រូវគេលួចប្រាក់អស់ ហើយនៅពេលពួកគាត់ទៅដល់ប្រទេសគោលដៅ ពួកគាត់មិនអាចសុំការគាំទ្រពីច្បាប់បានឡើយ ព្រោះពួកគាត់កំពុងរស់នៅប្រទេសនោះដោយខុសច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយ ការជួញដូរមនុស្ស មានគ្រោះថ្នាក់ជាង ការរត់ពន្ធមនុស្ស។

ចូរពន្យល់ថា ពិធីសារប៉ាឡឺម៉ូ គឺជាកិច្ចព្រមព្រៀងអន្តរជាតិមួយស្តីពីការជួញដូរមនុស្ស។ ពិធីសារប៉ាឡឺម៉ូ បានកំណត់ជាស្រេច នូវនិយមន័យនៃពាក្យ **ការជួញដូរមនុស្ស**។ ចូរពន្យល់អ្នកចូលរួមថា នៅក្នុងមេរៀននេះ នឹងមិនមានការពិនិត្យទៅលើនិយមន័យ ការជួញដូរមនុស្សទាំងស្រុង ព្រោះវាមានភាពស្មុគស្មាញប៉ុន្តែពិធីសារប៉ាឡឺម៉ូ បានអោយនិយមន័យនៃការជួញដូរមនុស្សគឺមានសមាសភាគចំនួនបីគឺ ៖ សកម្មភាព មធ្យោបាយ និង គោលបំណង ។

ចូរចែកកូនសៀវភៅនារីកវែឆ្លាតដល់អ្នកចូលរួម។ ចូរអោយអ្នកចូលរួមអានអោយឮៗនូវនិយមន័យនៃ ពាក្យការជួញដូរមនុស្សឲ្យក្រុមដទៃទៀតស្តាប់។ បន្ទាប់មកចូរសួរសំណួរដូចខាងក្រោមដើម្បីជួយពួកគាត់ ស្វែងយល់ពីនិយមន័យនេះ ។

## តើមានអ្នកណាម្នាក់ អាចឲ្យនិយមន័យ នៃពាក្យខាងក្រោមនេះបានឬទេ ?

### ការជ្រើសរើសបុគ្គលិក

ចម្លើយ ៖ គឺជាការស្វែងរក និងជួលមនុស្សឲ្យមកធ្វើការងារដែលត្រូវគេជួញដូរ

### ការផ្ទេរ / ការនាំយក

ចម្លើយ ៖ ការជួយឲ្យអ្នកណាម្នាក់ បានទៅប្រកបការងារដែលត្រូវមានគេជួញដូរ

### ការផ្តល់ជម្រកឃុំខ្លួន

ចម្លើយ ៖ ការផ្តល់ទីកន្លែងស្នាក់នៅ សម្រាប់អ្នកដែលកំពុងត្រូវគេជួញដូរ

### ការគំរាមដោយកំលាំង

ចម្លើយ ៖ ការនិយាយ ឬប្រព្រឹត្តនូវទង្វើបែបណាមួយ ដែលនាំឲ្យបុគ្គលណាម្នាក់ជឿថា ខ្លួន ឬបុគ្គលម្នាក់ផ្សេងទៀត នឹងត្រូវគេធ្វើបាប ។

### ការចាប់ពង្រត់

ចម្លើយ ៖ ការនាំបុគ្គលណាម្នាក់ទៅ ដោយមិនស្របតាមបំណងរបស់បុគ្គលនោះ ។ ការចាប់ជំរិត គឺជាទម្រង់នៃការចាប់ពង្រត់ ។

### ការបោកបញ្ឆោត / ការក្លែងបន្លំ

ចម្លើយ ៖ ការប្រាប់រឿងមិនពិត ដល់បុគ្គលណាម្នាក់ ឧទាហរណ៍ដូចជា ដំណឹងមិនពិត ស្តីពីការជ្រើសរើសបុគ្គលិក ។

### ការប្រើអំណាចខុសច្បាប់

ចម្លើយ៖ជាការប្រើប្រាស់មុខងារនៃអំណាចដោយបំពាន។ឧទាហរណ៍៖នាយកសាលាដែលជ្រើសរើសសិស្សឲ្យប្រកបការងារដែលត្រូវគេជួញដូរ ឬមិត្តប្រុសចំណាស់ដែលសុំឲ្យមិត្តស្រីរបស់គាត់ ដែលមានអាយុក្មេងជាងច្រើនអោយលក់ខ្លួនជាដើម ។

### ការងារដោយបង្ខំ

ចម្លើយ ៖ ការងារដែលគេហាមមិនឲ្យបុគ្គលិកឈប់ធ្វើ។ ឧទាហរណ៍ ៖ បុគ្គលិក ត្រូវគេឃុំទុកនៅក្នុងរោងចក្រ ។

### ទាសភាព

ចម្លើយ ៖ ការងារដែលត្រូវគេបង្ខំឲ្យធ្វើ និងមិនទទួលបានប្រាក់ឈ្នួល

### ពេស្យាកម្ម

ចម្លើយ ៖ ការលក់សេវាផ្លូវភេទ

## ការជួញដូរកុមារ

ចូរពន្យល់ថា ការជួញដូរអាចកើតឡើង ចំពោះក្មេង ចាស់ ប្រុស ស្រី ។

ចូរពន្យល់ថា ច្បាប់ដែលពាក់ព័ន្ធនឹង**ការជួញដូរកុមារ** មានលក្ខណៈខុសគ្នាទៅនឹងច្បាប់នៃការជួញដូរមនុស្សពេញវ័យ។ ចំពោះកុមារ ដែលត្រូវបានចាត់ទុកថា ជាជនរងគ្រោះដោយការជួញដូរនេះ អ្នកមិនចាំបាច់តែពួកគាត់ត្រូវគេបង្ខំ ឬស្ថិតក្រោមការគ្រប់គ្រងរបស់គេឡើយ។គ្រាន់តែមានការបង្ហាញថា មានសកម្មភាព ទុកកុមារឲ្យស្ថិតនៅក្នុងស្ថានភាពរងគ្រោះដោយការកេងប្រវ័ញ្ចគឺគ្រប់គ្រាន់នឹងនិយាយបានថាមានទោសទៅហើយ។ ចំពោះនិយមន័យនៃពាក្យជួញដូរដែលបានបង្ហាញនៅខាងដើមនោះអ្នកគ្រាន់តែបង្ហាញថា មានសកម្មភាព និងធ្វើដោយចេតនាចំពោះកុមារទៅបានហើយ ដោយមិនចាំបាច់បង្ហាញពីមធ្យោបាយអ្វីឡើយនៅ ពេលកំណត់ថាតើកុមារត្រូវគេជួញដូរ ឬអត់នោះ ។

## ការភ្ជាប់និយមន័យនៃពាក្យ ការជួញដូរ ទៅនឹងករណីសិក្សា

ចូរប្រាប់អ្នកចូលរួម ឲ្យចាប់ដៃគូដែលមានគ្នាពីរនាក់ ។

ត្រូវចែកប័ណ្ណព័ត៌មានលេខ IS1.1 ៖ កាតនិយមន័យការជួញដូរមនុស្ស ។ ចូរអោយក្រុមនីមួយៗអានព័ត៌មានដែលមាននៅក្នុងប័ណ្ណនោះ ហើយសាកគិតពីនិយមន័យនៃពាក្យនោះមុនពេលត្រលប់ក្រដាសប័ណ្ណទៅម្ខាងទៀតដើម្បីអាចចម្លើយ។ ចូរលើកទឹកចិត្ត និងបំផុសអោយមានការពិភាក្សានៅកំឡុងពេលនោះ ។ រឿងខ្លះអាចត្រូវនឹងនិយមន័យច្រើនជាងមួយ ។

ចូរប្រាប់ក្រុមឲ្យបង្ហាញចម្លើយដល់គ្នាទៅវិញទៅមក។ចូរធ្វើការបកស្រាយបន្ថែមអោយបានច្បាស់ដើម្បីកុំឲ្យមានការភាន់ច្រឡំ ។

### សង្ខេបមេរៀន

- ការធ្វើចំណាកស្រុក មានន័យថា គឺការដែលមនុស្សផ្លាស់ទីទៅកន្លែងផ្សេងដើម្បីប្រកបការងារ
- ការជួញដូរមនុស្ស គឺជាការបោកបញ្ឆោត ឬការបង្ខំមនុស្សឲ្យធ្លាក់ចូលទៅក្នុងទម្រង់នៃការកេងប្រវ័ញ្ចការងារព្រោះថានៅពេលនោះ ជនរងគ្រោះដោយការជួញដូរមានការលំបាកក្នុងការដកខ្លួនចេញ ។
- ការជួញដូរមនុស្ស មានធាតុផ្សំ ៣ គឺ សកម្មភាព មធ្យោបាយ និង គោលបំណងការជួញដូរមនុស្ស មានលក្ខណៈខុសគ្នាពី ការរត់ពន្ធមនុស្ស ។ អ្នកដែលត្រូវជ្រើសរើសអោយគេ រត់ពន្ធ និងបង់ប្រាក់អោយគេជួញនាំគាត់លួចឆ្លងដែនហើយជាទូទៅ មានសេរីភាព ដើរហើរ គ្រប់គ្រាន់ ។ ទោះជាយ៉ាងណាក៏ដោយ ការរត់ពន្ធមនុស្សមានគ្រោះថ្នាក់ដែរ។
- ច្បាប់ដែលពាក់ព័ន្ធនឹងការជួញដូរកុមារ មានលក្ខណៈខុសគ្នាទៅនឹងច្បាប់នៃការជួញដូរមនុស្ស ពេញវ័យ ។ ចំពោះកុមារដែលត្រូវបានចាត់ទុកថា ជាជនរងគ្រោះដោយការជួញដូរមនុស្សមិនចាំបាច់បង្ហាញថាពួកគាត់ត្រូវបានគេបង្ខំ ឬត្រូវគេគ្រប់គ្រងឡើយ។ គ្រាន់តែបង្ហាញថាមាននរណាម្នាក់ធ្វើសកម្មភាពទុកកុមារឲ្យស្ថិតនៅក្នុងស្ថានភាពរងគ្រោះដោយការកេងប្រវ័ញ្ចទៅ គឺគ្រប់គ្រាន់នឹងមានទោសហើយ ។



នារី ខ គឺជាស្ត្រីវ័យក្មេងម្នាក់ ។ ម្តាយមីងរបស់នាង បានទៅលេងផ្ទះនាង ហើយបានប្រាប់នាងថា គាត់អាចរកការងារល្អមួយឲ្យនារី ខ គឺការងារនៅក្នុងការិយាល័យមួយក្នុងប្រទេសម៉ាឡេស៊ី ។ ម្តាយមីង របស់នារី ខ ដឹងថា ការងារនោះ មិននៅក្នុងការិយាល័យឡើយ ប៉ុន្តែម្តាយមីងរូបនេះ នឹងទទួលបាន ប្រាក់ ចំពោះការដែលគាត់បានបញ្ជូនមនុស្សទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ហេតុនេះ គាត់ក៏និយាយកុហកនារី ខ ។



បុរស ស គឺជាមនុស្សដ៏មានអំណាចម្នាក់ នៅទីប្រជុំជននៃអ្នកនេសាទ ។ គាត់មានផ្ទះមួយ សម្រាប់ លាក់ជនរងគ្រោះដែលត្រូវគេជួញដូរស្នាក់នៅ ដើម្បីរង់ចាំទូកនេសាទនាំពួកគេទៅសមុទ្រ ។ ជនរងគ្រោះ ត្រូវបានឃុំខ្លួនទុកនៅក្នុងផ្ទះ ។




បុរស ប គឺជាអ្នកបើករថយន្តក្រុង ដែលតែងតែដឹកជនរងគ្រោះដោយការជួញដូរមនុស្ស ពីព្រំដែន ទៅកាន់ទូកនេសាទ ។ បុរស ប ដឹងថា ជនរងគ្រោះទាំងនោះត្រូវបានគេបោកបញ្ឆោតឲ្យមកប្រកប ការងារនេះ ប៉ុន្តែបុរសរូបនោះទទួលបានប្រាក់បន្ថែមក្នុងការដែលខ្លួនដឹកពួកគេទៅ ហើយដោយមិនអោយសួរដេញដោល អ្វីទាំងអស់។

**ចម្លើយ ៖**

ការជ្រើសរើសបុគ្គលិក

**ចម្លើយ ៖**

ការផ្ទេរ / ការនាំយក

**ចម្លើយ ៖**

ការផ្តល់ជម្រកឃុំខ្លួន





ឪពុករបស់នារី ម មានមុខរបរជាកសិករ ។ គាត់បានទៅខ្ចីប្រាក់ពីអ្នករកស៊ីចងការម្នាក់ដែលជា ម្ចាស់រង្គសាលមួយនៅក្នុងស្រុក ។ នៅពេលឪពុករបស់នាង មិនអាចមានលទ្ធភាពសងបំណុលនោះ អ្នកចងការបានទាមទារអោយនារី ម លក់ភេទនៅក្នុងរង្គសាលរបស់គាត់ ដើម្បីដោះបំណុល។ អ្នករកស៊ីចងការនោះបាននិយាយថា បើនារី ម បដិសេដមិនព្រមធ្វើការងារនេះទេ គាត់នឹងប្តឹងប៉ូលីសចាប់ឪពុកនាងដាក់គុក ។



នារី ល បានធ្វើការជាអ្នកបម្រើតាមផ្ទះអស់រយៈពេល ៣ ឆ្នាំមកហើយ ហើយនាងទទួលបាន ប្រាក់ឈ្នួលយ៉ាងតិច ។ នាងត្រូវបានគេឃុំទុកនៅក្នុងផ្ទះ ហើយគេគំរាមនាងថា បើនាងហ៊ានរត់ គ្រួសាររបស់នាង នឹងត្រូវគេបង្ខំឲ្យសងប្រាក់មួយចំនួនធំ ទៅឲ្យអ្នករើសបុគ្គល ។




អ្នករើសបុគ្គលិក បានចាត់ចែងបញ្ជូននារី ខ ទៅប្រទេសម៉ាឡេស៊ីថាអោយធ្វើការងារដ៏ល្អមួយ ។ ពេលទៅដល់ប្រទេសម៉ាឡេស៊ី គេប្រាប់នាងថា នាងគឺមកដើម្បីធ្វើការជាអ្នកបម្រើតាមផ្ទះ ហើយមិនអនុញ្ញាតឲ្យចាកចេញពីផ្ទះឡើយ ។

**ចម្លើយ ៖**

ការងារដោយបង្ខំ និង ការប្រើអំណាចខុសច្បាប់

**ចម្លើយ ៖**

ការប្រើអំណាចខុសច្បាប់

**ចម្លើយ ៖**

ការបោកបញ្ឆោត





បុរស ខ ធ្វើការនៅក្នុងចំការអស់រយៈពេលប្រាំឆ្នាំហើយ ។ជនប្រដាប់អាវុធបានយាមនៅតាមរបងហើយគេបានប្រាប់បុរស ខ ថា បើគាត់ហ៊ានចាកចេញ គ្រួសារបុរសនោះនឹងត្រូវគេពិន័យ ។



នារី ម បានធ្វើការជាពេស្យាចារ អស់រយៈពេលពីរឆ្នាំហើយ នៅកន្លែងពេស្យាដើម្បីសងបំណុល ឪពុកនាង ។



បុរស ន គឺជាអ្នកធ្វើចំណាកស្រុកម្នាក់ ដែលទៅរស់នៅទីក្រុងដ៏ធំមួយ ដាច់ឆ្ងាយពីប្រទេសរបស់គាត់។ គាត់ពុំមានការងារធ្វើឡើយ ។មានបុរសម្នាក់បានមករកគាត់ ហើយប្រាប់គាត់ថា បុរស ន អាចរកប្រាក់បានច្រើន ប្រសិនបើគាត់លក់ក្រលៀនរបស់គាត់។ មនុស្សដែលមករកគាត់នោះ និយាយថា គេចំណាយពេលតែមួយថ្ងៃប៉ុណ្ណោះ ដើម្បីវះកាត់យកក្រលៀន ហើយថា បុរស ន នៅក្មេង មានសុខភាពរឹងមាំ ដូចនេះពេលវះកាត់រួចហើយសុខភាពគាត់នៅតែល្អដដែល ។ ក្រោយពីការវះកាត់រួច បុរស ន មានការឈឺចុកចាប់យ៉ាងខ្លាំង ហើយមន្ទីរព្យាបាលឯកជនដែលគាត់ទៅវះកាត់នោះ ក៏មិនបានផ្ដល់កន្លែងដល់បុរស ន ស្នាក់នៅដើម្បីព្យាបាលឲ្យជាសះស្បើយ ឬ ផ្ដល់ថ្នាំសង្កូវអ្វីឡើយ។ នៅពេលបុរស ន សុំឲ្យបង់ប្រាក់មកខ្លួននោះ មន្ទីរព្យាបាល បានផ្ដល់ប្រាក់ឲ្យគាត់តែមួយ២៥%នៃតម្លៃដែលបានព្រមព្រៀងប៉ុណ្ណោះ ។ បុរស ន ឈឺចុកចាប់ណាស់ ហើយទន់ខ្សោយ ហេតុនេះ គាត់មិនអាចបដិសេធអ្វីបានឡើយ ។

**ចម្លើយ ៖**

ការបង្ខំដោយកំលាំង / ទាសភាព

**ចម្លើយ ៖**

ពេស្យាចារ

**ចម្លើយ ៖**

ការជួញដូរសេរីរាង្គ





# មេរៀនទី ១. ២ ៖
# ការរំឭកឡើងវិញ នូវច្បាប់ និងកិច្ចព្រមព្រៀងស្តីពីការជួញដូរមនុស្ស

## វត្ថុបំណង ៖

អ្នកចូលរួមនឹងរំឭកឡើងវិញអំពីច្បាប់ និងកិច្ចព្រមព្រៀងស្តីពីការជួញដូរមនុស្ស

## រយៈពេល ៖

៧៥ នាទី

## សម្ភារៈ

- ប័ណ្ណព័ត៌មានលេខ ១.១៖ ប័ណ្ណស្តីពីនិយមន័យការជួញដូរមនុស្ស (១ ឈុត សម្រាប់ ១ក្រុមដែលមានសមាជិក ២ នាក់)
- ប័ណ្ណព័ត៌មានលេខ ១.២៖ ប័ណ្ណស្តីពីសិទ្ធិកុមារ( ចូរថតចម្លងអោយគ្រប់ចំនួន ដើម្បីឲ្យក្រុមនីមួយ ដែលមានសមាជិកពី ៦ ទៅ ១០ នាក់ អាចមាន ១ ឈុត សម្រាប់ខ្លួន។ចូរកាត់ប័ណ្ណទាំងនោះអោយរួចរាល់មុនចាប់ផ្តើមមេរៀន)
- កូនសៀវភៅនារីកវៃឆ្លាតសម្រាប់ចែកជូនអ្នកចូលរួមនីមួយៗ

## ការរំឭកឡើងវិញ នូវអនុសញ្ញាស្តីពីសិទ្ធិកុមារ

ចូរពន្យល់ថា មេរៀននេះ គឺនិយាយអំពីច្បាប់ ដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ។ ចូរពន្យល់ថា នៅក្នុង ក្លឹបយុវជននារីកវៃឆ្លាត អ្នកចូលរួម រៀនអំពីច្បាប់ខ្លះរួចទៅហើយ ប៉ុន្តែ ដោយសារច្បាប់នេះ មានសភាពស្មុគស្មាញច្រើន ដូច្នេះយើងក៏នឹងធ្វើការរំឭក វាឡើងវិញ ។

ចូរពន្យល់ថា ប្រទេសជាតិនីមួយៗ សុទ្ធតែមានច្បាប់គ្រប់គ្រងអ្វីដែលកើតឡើងនៅក្នុងប្រទេស របស់ខ្លួន។ ប៉ុន្តែប្រទេសទាំងអស់ក៏បានចុះហត្ថលេខាយល់ព្រមលើកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលត្រូវ បានយកទៅអនុវត្តដែរនៅក្នុងប្រទេសផ្សេងៗផងដែរ។ នៅពេលប្រទេសជាតិមួយចុះហត្ថលេខាលើ កិច្ចព្រម ព្រៀងអន្តរជាតិណាមួយ មានន័យថាប្រទេសនោះមានភារកិច្ចខិតខំ អនុវត្តស្របនឹងគ្រប់មាត្រា ទាំងឡាយ ដែលមានចែងក្នុងកិច្ចព្រមព្រៀងនោះនៅក្នុងប្រទេសរបស់ខ្លួន។ ចូរសួរថា ៖ តើមានអ្នកណាម្នាក់អាច ប្រាប់ឈ្មោះកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួនដែលពាក់ព័ន្ធទៅនឹងការជួញដូរមនុស្សបាន?

ចូរពន្យល់ថា កិច្ចព្រមព្រៀងសំខាន់ៗមានពីរគឺ ៖

១) អនុសញ្ញាស្តីពីសិទ្ធិកុមារ

២) ពិធីការប៉ាឡឹម៉ូ (មានឈ្មោះពេញនៅខាងក្រោម)

1 Officially titled the United Nations Protocol to Prevent, Suppress and Punish Trafficking in Persons Especially Women and Children, supplementing the United Nations Convention against Transnational Organized Crime (New York: 15 November 2000). For more information, see http://www.palermoprotocol.com.

ចូរសួរអ្នកចូលរួមណាម្នាក់អោយពន្យល់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ។ បើចាំបាច់ចូរពន្យល់បន្ថែមថា អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាអនុសញ្ញាអន្តរជាតិមួយ ដែលបង្ហាញត្រួសៗអំពីសិទ្ធិកុមារ ។អនុសញ្ញានេះត្រូវបានបង្កើតឡើងជាង២០ឆ្នាំមកហើយ ដោយអង្គការសហប្រជាជាតិ ហើយដែលមានប្រទេស ជាច្រើនទៀត បានចុះហត្ថលេខារួមទាំងប្រទេសខ្លួនឯងនោះផង។ ប្រទេសដែលបានចុះហត្ថលេខនៅក្នុងអនុសញ្ញាស្តីពី សិទ្ធិកុមារនេះយល់ព្រមអនុវត្តតាមច្បាប់ដែលទាក់ទងទៅនឹងកុមារដូចៗគ្នា។ នេះមានន័យថាប្រទេសនោះ បានព្រមព្រៀងថាកុមារនៅក្នុងប្រទេសខ្លួនគួរតែមានសិទ្ធិដូចលក្ខខណ្ឌនានាដែលបានចែងនៅក្នុងអនុសញ្ញា ស្តីពីសិទ្ធិកុមារនេះ។

ចូរពន្យល់ថា នៅក្នុងមាត្រាទាំង៥៤នោះ អនុសញ្ញាស្តីពីសិទ្ធិកុមារ បានចែងអំពីសិទ្ធិផ្សេងៗដែលកុមារគួរតែទទួលបាន ។ ដោយសារអនុសញ្ញានេះមានបង្ហាញពីសិទ្ធិយ៉ាងច្រើនសម្រាប់កុមារទើបសិទ្ធិទាំងនោះ ត្រូវសង្ខេបមកត្រឹមបួនចំណុចសំខាន់ ដែលឲ្យឈ្មោះថា "សិទ្ធិជាមូលដ្ឋានរបស់កុមារ" ដើម្បីឲ្យស្រួលចាំ។ ត្រូវសួរថា ៖ មានអ្នកណាអាចប្រាប់បានទេថា តើសិទ្ធិទាំងបួន ដែលជាសិទ្ធិជាមូលដ្ឋានរបស់កុមារនេះ មានអ្វីខ្លះ? ចូរសរសេរឈ្មោះសិទ្ធិទាំងបួននោះ នៅក្នុងរង្វង់មូលលើក្រដាសផ្លិបឆាត ។

សិទ្ធិទាំងនេះ រួមមាន ៖

## សិទ្ធិរស់រានមានជីវិត

ត្រូវពន្យល់ថា សិទ្ធិទាំងនេះរួមមាន សិទ្ធិទទួលបានអាហារបរិភោគគ្រប់គ្រាន់ សិទ្ធិទទួលបានការថែទាំសុខភាព សិទ្ធិមានទីជម្រក សិទ្ធិមានឈ្មោះ និងសញ្ជាតិស្របច្បាប់ ។

## សិទ្ធិទទួលបានការការពារ

ចូរពន្យល់ថា សិទ្ធិទាំងនេះរួមមាន សិទ្ធិទទួលបានការការពារពីការប្រើអំពើហឹង្សា ឬការរំលោភបំពានលើរូបរាងកាយ និងសតិអារម្មណ៍ សិទ្ធិទទួលបានការការពារពីការទុកចោលមិនយកចិត្តទុកដាក់ ឬការកេងប្រវ័ញ្ច សិទ្ធិទទួលបានការការពារពីការបំពានផ្លូវភេទ សិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចកម្លាំង ពលកម្ម និងការប្រើប្រាស់គ្រឿងញៀន ។

## សិទ្ធិអភិវឌ្ឍន៍

ចូរពន្យល់ថា សិទ្ធិទាំងនេះ រួមមាន សិទ្ធិលេងកំសាន្ត សិទ្ធិទទួលបានការអប់រំ និងសិទ្ធិទទួលបានការថែទាំយ៉ាងកក់ក្តៅពីឪពុកម្តាយ ។

## សិទ្ធិចូលរួម

ចូរប្រាប់អ្នកចូលរួមថា សិទ្ធិទាំងនេះរួមមាន សិទ្ធិសំដែងមតិយោបល់ និងនិយាយ សិទ្ធិក្នុងការស្តាប់ សិទ្ធិទទួលបានព័ត៌មាន និងសេរីភាពក្នុងការចូលរួមសកម្មភាពនានាៗ។ ចុងក្រោយរាប់បញ្ចូលទាំងសិទ្ធិចូលរួមក្រុម ( ដូចជា SNYC ) ជាដើម ) ដើម្បីជួបជុំជាមួយមិត្តភក្តិ ។

## សកម្មភាពប្រមូលផ្តុំប័ណ្ណសិទ្ធិកុមារ

ចូរប្រាប់អ្នកចូលរួម ឲ្យបង្កើតជាក្រុមមានគ្នាពី៦ទៅ១០នាក់ ។ ចែកប័ណ្ណសិទ្ធិកុមារមួយឈុតៗ ទៅឲ្យក្រុមនីមួយៗ (ប័ណ្ណព័ត៌មានលេខ ២ ៖ ប័ណ្ណសិទ្ធិកុមារ) ។

ចូរប្រាប់អ្នកចូលរួមឲ្យរៀបចំប័ណ្ណទាំងនោះដាក់ផ្តុំ ហើយចាត់ឲ្យមនុស្សណាម្នាក់ ទៅបើកប័ណ្ណទាំងនោះម្តងមួយៗ។ នៅពេលបើកប័ណ្ណអស់ហើយ ក្រុមអ្នកចូលរួមគួរតែសម្រេចមើលថា តើតួអង្គកុមារដែលមាន នៅក្នុងប័ណ្ណនេះ ទទួលបានសិទ្ធិរបស់ខ្លួនឬទេ។ ប្រសិនបើក្រុមអ្នកចូលរួមសម្រេចថា កុមារនោះមិនបានទទួលសិទ្ធិរបស់ខ្លួនទេនោះ អ្នកចូលរួមគួរតែបញ្ជាក់ពីមូលហេតុ។ (ឧទាហរណ៍ ៖ កុមារម្នាក់ដែលគេមិនបានអនុញ្ញាតឲ្យលេងជាមួយ មិត្តភក្តិ គឺមិនទទួលបានសិទ្ធិចូលរួមឡើយ) ។

នៅពេលចប់ ត្រូវប្រាប់ក្រុមអ្នកចូលរួមឲ្យអានប័ណ្ណនោះម្តងទៀត ហើយឲ្យពួកគាត់ជ្រើសរើស ទុកមួយដុំនូវប័ណ្ណទាំងឡាយណា ដែលបង្ហាញពីស្ថានភាពណាដែលអាចធ្វើឲ្យកុមារងាយនឹងត្រូវគេយក ទៅជួញដូរជាងគេ ។ (ឧទាហរណ៍ ៖ កុមារម្នាក់ដែលពុំមានឯកសារបញ្ជាក់ពីអត្តសញ្ញាណ នៃជាតិកំណើតរបស់ខ្លួន ទំនងជាមិនសូវបានចូលរៀនឡើយ ដែលកត្តាបែបនេះ ធ្វើឲ្យកុមារទាំងនោះ កាន់តែងាយរងគ្រោះ ដោយសារត្រូវគេជួញដូរ។ កុមារម្នាក់ដែលគ្មានឯកសារបញ្ជាក់ពីអត្តសញ្ញាណ ក៏អាចនឹងមិនហ៊ានទំនាក់ទំនង ទៅប៉ូលីសឡើយ បើកុមារនេះត្រូវគេជួញដូរ ។)

## ច្បាប់ស្តីពីការជួញដូរ

បន្ទាប់មក ប្រាប់អ្នកចូលរួមឲ្យយកកូនសៀវភៅព័ត៌មានសម្រាប់អ្នកតម្រង់ទិសឆ្លាតវៃចេញមកហើយ ប្រាប់ពួកគេឲ្យអានត្រង់ផ្នែក ច្បាប់ស្តីពីការជួញដូរ ដែមានចំណងជើងថា ពីធីសារប៉ាឡឺម៉ូនៅទំព័រទី ២ ។ ចូរពន្យល់ថា ពិធីសារប៉ាឡឺម៉ូ គឺជាកិច្ចព្រមព្រៀងអន្តរជាតិមួយ ដែលគេបានធ្វើឡើងនៅក្នុងឆ្នាំ២០០០ ហើយមានប្រទេសជាច្រើនបានចុះហត្ថលេខា។ ចូរពន្យល់ថា និយមន័យនៃការជួញដូរមនុស្ស គឺជាចែងពីសកម្មភាព មធ្យោបាយ និងគោលបំណង ដែលយើងបានប្រើប្រាស់នៅក្នុងសៀវភៅណែនាំនេះ ។

បន្ទាប់មក ត្រូវប្រាប់អ្នកចូលរួមឲ្យអានច្បាប់នៅក្នុងប្រទេសរបស់ខ្លួន ដែលទាក់ទងទៅនឹងការជួញដូរ ។

បន្ទាប់មក ត្រូវសួរអ្នកចូលរួមថា ៖

- សិទ្ធិកុមារត្រូវបានរំលោភបំពានដោយការជួញដូរមនុស្សដែរឬទេ ? (ចម្លើយ ៖ មែន)
- តើការជួញដូរ គឺជាការរំលោភលើពិធីការប៉ាឡឺម៉ូ ឬទេ? (ចម្លើយ ៖ មែន)
- តើការជួញដូរគឺជាអំពើខុសច្បាប់ ឬទេ នៅក្នុងប្រទេសអ្នក? (ចម្លើយ ៖ មែន)
- តើការជួញដូរនៅតែកើតមាននៅក្នុងប្រទេសអ្នក ឬទេ? (ចម្លើយ ៖ មែន)

ចូរពន្យល់ថា ការជួញដូរមនុស្សគឺជាបញ្ហាមួយយ៉ាងធំ ។ នៅត្រូវបង្ហាញថា បើតាមការប៉ាន់ស្មាន មានកុមារដល់ទៅ២លាននាក់ ដែលត្រូវបានគេកេងប្រវ័ញ្ច តាមរយៈអំពើពេស្យាកម្ម ឬរូបភាពអាសអាភាស នៅជុំវិញពិភពលោកក្នុង១ឆ្នាំៗ ។

អង្គការសហប្រជាជាតិបានប៉ាន់ស្មានថា មានកុមារជាង១,២លាននាក់ ដែលទទួលរងនូវការជួញដូរក្នុងមួយឆ្នាំៗ ។

បើតាមការប៉ាន់ស្មាន បច្ចុប្បន្ន មានមនុស្សជាង២៧លាននាក់ ដែលក្លាយជាជនរងគ្រោះដោយសារ ការជួញដូរមនុស្ស។

ត្រូវសួរថា ៖ ប្រសិនបើការជួញដូរ ខុសច្បាប់បែបនេះ ចុះហេតុអ្វីបានជាអំពើនេះបានរីករាលដាល យ៉ាងដូច្នេះ? តើមានអ្នកណាម្នាក់ គិតឃើញពីមូលហេតុ ដែលធ្វើឲ្យការជួញដូរនេះចេះតែបន្តរីកធំទៅៗ ឬទេ?

---

1 Child Safe Tourism, 'UNICEF: A Statistical Snapshot on Child Abuse in East Asia and the Pacific.' (2 September 2013), http://www.childsafetourism.org/unicef-statistical-snapshot-child-abuse-east-asia-pacific/.

2 UNICEF, 'Child Protection Information Sheet: Trafficking' (May 2006), http://www.unicef.org/protection/files/Trafficking.pdf.

3 Department of State, United States of America, 'Traffficking in Persons Report' (Washington DC: Department of State, 2012).

នៅពេលក្រុមអ្នកចូលរួមនោះបានសម្តែងនូវគំនិតរបស់ខ្លួនរួចហើយ ចូរបង្ហាញមូលហេតុបីយ៉ាង ប្រសិនបើមូលហេតុទាំងបីនេះ មិនទាន់ត្រូវបានលើកយកមកពីភាក្សា ៖

- អ្នកជួញដូរមនុស្សអាចរកប្រាក់បានច្រើន ។
- ប្រព័ន្ធអយុត្តិការមិនមានភាពរឹងមាំ ។
- ជនរងគ្រោះអាចបដិសេធផ្តល់ការផ្តល់ភស្តុតាងណាមួយ ឬភស្តុតាងណាដែលមានប្រយោជន៍ ព្រោះពួកគាត់មានការភ័យខ្លាច ។

ចូរប្រាប់អ្នកចូលរួមថា ដើម្បីក្លាយជាអ្នកតស៊ូមតិដ៏ល្អ ពួកគាត់ត្រូវដឹង និងយល់អំពីច្បាប់ដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ហើយត្រូវដឹងខ្លះៗអំពីចំនួនមនុស្ស ដែលជាជនរងគ្រោះដោយសារ ការជួញដូរ មនុស្ស ។ ចូរពន្យល់ថា នៅក្នុងការបណ្តុះបណ្តាលក្រោយៗ យើងនឹងសិក្សាបន្ថែមទៀត អំពីការជួញដូរមនុស្ស ប៉ុន្តែត្រូវប្រាប់ពួកគាត់ថាជាការប្រសើរណាស់ ប្រសិនបើអ្នកចូលរួមចំណាយពេលសិក្សាអំពីច្បាប់ស្តីពី ការជួញដូរមនុស្សដើម្បីឲ្យពួកគេបានជ្រាបកាន់តែច្បាស់ ។

## សង្ខេបមេរៀន

- អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាកិច្ចព្រមព្រៀងអន្តរជាតិមួយ ដែលមានប្រទេសមួយចំនួនធំបានចុះហត្ថលេខាព្រមព្រៀងទទួលស្គាល់នូវសិទ្ធិជាក់លាក់របស់កុមារ ។
- សិទ្ធិទាំងនេះ អាចបែងចែកជា៤ប្រភេទសំខាន់ៗគឺ ៖ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិចូលរួម និងសិទ្ធិអភិវឌ្ឍន៍ ។
- ពលកម្មកុមារ និងការជួញដូរកុមារបានធ្វើឲ្យកុមារមិនអាចទទួលបាននូវសិទ្ធិទាំងឡាយទៅតាម អនុសញ្ញានៃសិទ្ធិកុមារ ។
- ពិធីសារប៉ាឡឺម៉ូ គឺជាកិច្ចព្រមព្រៀង អន្តរជាតិមួយ ដែលមានប្រទេសជាច្រើនបានចុះហត្ថលេខា ក្នុងនោះក៏មានប្រទេសយើងខ្លួនឯងផងដែរ។
  ពិធីសារប៉ាឡឺម៉ូ ចែងថាការជួញដូរមនុស្សគឺជាអំពើខុសច្បាប់។
- ការជួញដូរមនុស្សនៅតែបន្តកើតឡើងជានិច្ច ទោះបីមានកិច្ចព្រមព្រៀមអន្តរជាតិទាំងនេះ ដោយកត្តាជាច្រើនដូចជាអ្នកជួញដូរអាចរកប្រាក់បានច្រើន ប្រព័ន្ធអយុត្តិការមិនរឹងមាំ និងជនរងគ្រោះអាចសម្រេចចិត្ត មិនឲ្យមានការកាត់ទោស។

| | |
|---|---|
| កុមារបានចូលរៀន | កុមារមិនបានចូលរៀន |
| កុមារទទួលបានការថែទាំសុខភាព | កុមារមិនទទួលបាន<br>ការថែទាំសុខភាព |
| កុមារត្រូវបានអនុញ្ញាតឲ្យមានជម្រើស | កុមារមិនត្រូវបានអនុញ្ញាតឲ្យ<br>មានជម្រើស |
| កុមារទទួលបានអាហារបរិភោគគ្រប់គ្រាន់ | កុមារមិនទទួលបានអាហារ<br>បរិភោគមិនគ្រប់គ្រាន់ |
| កុមារត្រូវបានអនុញ្ញាតឲ្យលេងជាមួយ<br>មិត្តភក្តិ | កុមារមិនត្រូវបានអនុញ្ញាតឲ្យលេង<br>ជាមួយមិត្តភក្តិ |
| កុមារមានសំបុត្រកំណើត | កុមារមិនមានសំបុត្រកំណើត |
| កុមារមានលិខិតបញ្ជាក់ពីអត្តសញ្ញាណ<br>នៃជាតិកំណើត | កុមារពុំមានលិខិតបញ្ជាក់ពី<br>អត្តសញ្ញាណនៃជាតិកំណើត |

| | |
|---|---|
| កុមារត្រូវបានអនុញ្ញាតឲ្យនិយាយ<br>ភាសាកំណើត | កុមារមិនត្រូវបានអនុញ្ញាតឲ្យនិយាយ<br>ភាសាកំណើត |
| កុមារត្រូវបានអនុញ្ញាតឲ្យគោរព<br>សាសនាដែលខ្លួនជ្រើសរើស | កុមារមិនត្រូវបានអនុញ្ញាតឲ្យគោរព<br>សាសនាដែលខ្លួនជ្រើសរើស |
| កុមារត្រូវបានការពារពីការបំពាន<br>លើរូបរាងកាយ/ការបំពានផ្លូវភេទ | កុមារទទួលរងការបំពានលើ<br>រូបរាងកាយ/ការបំពានផ្លូវភេទ |
| កុមារត្រូវទទួលបានព័ត៌មាន | កុមារមិនអាចទទួលបានព័ត៌មាន |
| កុមារត្រូវបានការពារអោយបញ្ចៀស<br>ពីការប្រើប្រាស់គ្រឿងញៀន<br>ឬផឹកស្រាច្រើនហួសកម្រិត | កុមារប្រើគ្រឿងញៀន<br>ឬផឹកស្រាច្រើនហួសកម្រិត |
| កុមារត្រូវបានការពារពីការធ្វើការងារធ្ងន់ | កុមារត្រូវធ្វើការងារធ្ងន់ៗ |
| កុមារត្រូវបានការពារពីការរំលោភ<br>បំពានផ្លូវភេទ | កុមារធ្វើការនៅកន្លែងពេស្យាចារ |





# មេរៀនទី ១.៣ ៖ ពលកម្មកុមារ

## វត្ថុបំណង ៖

អ្នកចូលរួមនឹងអាចដឹងពីផលប៉ះពាល់អវិជ្ជមាននៃពលកម្មកុមារ

## រយៈពេល ៖

៧៥ នាទី

## សម្ភារៈ

- មេរៀន ១.៣. ពលកម្មកុមារ......
- ស្ទីក័រ តូចៗពណ៌ក្រហម បៃតង ខៀវ និង លឿង

## កិច្ចស្វាគមន៍

- ចូរអោយកុមារចូលតាមក្រុម
- ចូរលេងល្បែងទាក់ទាញអារម្មណ៍

## តើពលកម្មកុមារ គឺជាអ្វី ?

ចូរឲ្យអ្នកចូលរួមរៀបរាប់អំពីពលកម្មកុមារ ។

ចូរពន្យល់ថា ជាទូទៅ ពាក្យ "ពលកម្មកុមារ" សំដៅលើការងារដែលធ្វើឲ្យកុមាររាំងស្ទះ ការវិវត្តន៍ កុមារភាព ទេព្យកោសល្យ និងសេចក្ដីថ្លៃថ្នូររបស់គេ ហើយការងារនេះ ធ្វើឲ្យប៉ះពាល់ ដល់ការអភិវឌ្ឍន៍រាងកាយ និងសតិបញ្ញារបស់កុមារ ។

ចូរពន្យល់ថា វាជារឿងធម្មតាដែលកុមារធ្វើការបន្តិចបន្តួចនៅក្នុងសហគមន៍របស់ខ្លួនដើម្បីជួយដល់ ក្រុមគ្រួសាររបស់ខ្លួន នៅពេលសម្រាកពីការសិក្សា ឬជួយការរកស៊ីរបស់គ្រួសារ ។ ទង្វើបែបនេះអាចជា ចំណុចល្អ។ វាជាការជួយដល់គ្រួសារ និងជួយឲ្យកុមារចេះបំនិនជីវិតផ្សេងៗ ។

ប៉ុន្តែ វាក៏ពេញនិយមណាស់ដែរ ដែលកុមារត្រូវធ្វើការងារដែលធ្វើរាំងស្ទះការវិវត្តន៍ កុមារភាព ទេពកោសល្យ សេចក្តីថ្លៃថ្នូរ ការអភិវឌ្ឍរាងកាយ និងបញ្ញារបស់កុមារ។ នៅពេលកុមារធ្វើការងារណា ដែលបង្កគ្រោះថ្នាក់ដល់គាត់បែបនេះ គេហៅថា "ពលកម្មកុមារ" ។ ចូរពន្យល់ថាពលកម្មកុមារអាចមានផល មិនល្អដល់កុមារជាពិសេសនៅពេល ការងារនោះ ៖

- ធ្វើឲ្យកុមារឈឺចាប់ផ្លូវកាយ ឬផ្លូវចិត្ត ។
- មិនឲ្យកុមារមានមិត្តភក្តិ ។
- មិនឲ្យកុមារបានចូលរៀន ។
- មិនឲ្យកុមារមានពេលវេលាធ្វើកិច្ចការ ដែលសាលាដាក់ឲ្យធ្វើនៅផ្ទះ ។
- កុមារមិននឿយហត់អស់កម្លាំងហួសប្រមាណ ពេលទៅសាលារៀន នៅថ្ងៃបន្ទាប់ ។
- ធ្វើឲ្យមានផលប៉ះពាល់ ដល់អនាគតរបស់កុមារ ។

## ភាពខុសគ្នា រវាងពលកម្មកុមារ និងការជួញដូរ

ចូរពន្យល់ថា ពលកម្មកុមារ អាចធ្វើឲ្យកុមារទទួលរងនូវការឈឺចាប់ ប៉ុន្តែមិនមែនមានន័យថា រាល់ពលកម្មកុមារ គឺជាទម្រង់នៃការជួញដូរឡើយ ។ ពលកម្មកុមារអាចជាការជួញដូរកុមារបាន លុះត្រាតែមានការកេងប្រវ័ញ្ចដោយតម្រូវឲ្យកុមារធ្វើការងារដោយបង្ខំ/ទាសភាព ពេស្យាកម្ម/លក់ភេទ ឬវះកាត់យកសរីរាង្គកុមារ ។ ឧទាហរណ៍ ៖

ការងារខាងក្រោមនេះ ត្រូវបានចាត់ទុកជាការជួញដូរ ៖

- កុមារដែលជាទាសករ (ទាសករ គឺជាមនុស្សដែលធ្វើការគ្មានប្រាក់ឈ្នួលហើយមិនអាចចាកចេញទៅណាបានឡើយ ។ ទាសករ ត្រូវបានចាត់ទុកដូចជាទ្រព្យសម្បត្តិរបស់ថៅកែផងដែរ)
- កុមារដែលធ្វើការនៅកន្លែងពេស្យា បំរើសេវាផ្លូវភេទ ។
- កុមារដែលធ្វើការជាអ្នកបម្រើតាមផ្ទះ មិនទទួលបានប្រាក់ឈ្នួល ។

ការងារខាងក្រោមនេះ គឺជាពលកម្មកុមារ ប៉ុន្តែអាចមិនមែនជាការជួញដូរ ៖

- កុមារដែលធ្វើការនៅក្នុងហាង មានសិទ្ធិចាកចេញ ហើយមានប្រាក់ខែ ។
- កុមារដែលប្រមូលផលស្រូវ ទទួលបានប្រាក់ឈ្នួល ហើយរស់នៅឯផ្ទះរបស់ខ្លួន ។

ចូរសួរអ្នកចូលរួម ប្រសិនបើពួកគាត់មានសំណួរ ។ បន្ទាប់មក បើនៅសល់ពេល ចូរឲ្យពួកគាត់លើកឧទាហរណ៍មកបញ្ជាក់ដោយខ្លួនឯង ។

## ការពិចារណាអំពីពលកម្មកុមារ និងការជួញដូរកុមារ នៅក្នុងសហគមន៍របស់យើង

ចូរប្រាប់ឲ្យអ្នកចូលរួមឲ្យចែកជាក្រុម ដែលមានគ្នាពី៦ ទៅ៨នាក់ ។ ចែកក្រដាសផ្លីបឆាតដល់ក្រុមនីមួយៗ ហើយប្រាប់ឲ្យក្រុមទាំងនោះគូររូបភាពសហគមន៍របស់ខ្លួន ដោយបង្ហាញប្រភេទការងារផ្សេងៗ ដែលកុមារនៅក្នុងសហគមន៍គេធ្វើ ព្រមទាំងទីកន្លែងនានាដែលនៅជុំវិញនោះ ។

ប្រាប់អ្នកចូលរួមឲ្យគិតអំពីការងារដែលកុមារធ្វើនៅតាមកន្លែងដូចខាងក្រោម ៖

- នៅផ្ទះ
- ក្នុងអាជីវកម្មជាលក្ខណៈគ្រួសារ
- តាមហាងលក់ឥវ៉ាន់ក្នុងមូលដ្ឋាន
- ក្នុងរោងចក្រ
- ក្នុងវាលស្រែ
- ក្នុងព្រៃ
- ក្នុងរង្គសាល

ឥឡូវ សូមចែកស្ទីក័រឲ្យទៅឲ្យអ្នកចូលរួម ។ ចូរប្រាប់អ្នកចូលរួមឲ្យបិទស្ទីក័រពណ៌បៃតងលើរូបភាព របស់គេ ដោយបិទទៅលើការងារទាំងឡាយណា ដែលបង្ហាញនូវការប៉ះពាល់ដល់ការសិក្សារបស់កុមារ ។

ចូរប្រាប់ពួកគេឲ្យបិទស្ទីក័រពណ៌ខៀវលើការងារទាំងឡាយណា ដែលប៉ះពាល់សុខភាពកុមារ។

ចូរប្រាប់ឲ្យបិទស្ទីក័រពណ៌លឿងលើការងារទាំងឡាយណា ដែលប៉ះពាល់ដល់អនាគតរបស់កុមារ (ឧទាហរណ៍ កុមារដែលបោះបង់ការសិក្សាទៅធ្វើការនៅតាមការដ្ឋានសំណង់មិនទទួលបានការសិក្សា គ្រប់គ្រាន់ដើម្បីទទួលបានការងារដែលមានប្រាក់ខែខ្ពស់នៅពេលអនាគត)។

សូមប្រាប់ឲ្យពួកគេបិទស្ទីក័រពណ៌ក្រហមលើការងារទាំងឡាយណា ដែលពាក់ព័ន្ធនឹងការជួញដូរ កុមារ។

២០នាទីក្រោយ ចូរប្រាប់អ្នកចូលរួមទាំងអស់ឲ្យមកផ្តុំគ្នាជារង្វង់មូល ហើយប្រាប់ឲ្យពួកគាត់លើករូបភាពរបស់ខ្លួនឡើង ដើម្បីបង្ហាញពីចំនួនស្ទីក័រដែលមាន។ (សូមកុំអោយពួកគេធ្វើការបកស្រាយលើស្ទីក័រទាំងអស់ នៅលើរូបភាពរបស់ខ្លួនឡើយ ព្រោះការធ្វើបែបនេះនឹងចំណាយពេលអស់ច្រើន)។

## ការពិភាក្សា

សូមប្រាប់អ្នកចូលរួមឲ្យពិនិត្យបញ្ជីសំណួរ បន្ទាប់មកឲ្យពួកគាត់ឆ្លើយ ៖

- តើទម្រង់ពលកម្មកុមារដែលសំបូរបំផុតនៅក្នុងសហគមន៍របស់អ្នក មានអ្វីខ្លះ?
- តើទម្រង់ពលកម្មកុមារណាខ្លះដែលគ្រោះថ្នាក់បំផុត នៅក្នុងសហគមន៍របស់អ្នក?
- តើហេតុផលអ្វីខ្លះ ដែលកុមារត្រូវបានបង្ខំកុមារឲ្យធ្វើការងារនៅក្នុងសហគមន៍របស់អ្នក?
- តើយើងអាចធ្វើដូចម្តេច ដើម្បីជួយឲ្យកុមារដែលនៅក្នុងសហគមន៍បាននៅតែបន្តរៀនសូត្រ ?

## សង្ខេបមេរៀន

ពលកម្មកុមារ គឺជាការងារដែលធ្វើអោយរាំងស្ទះការវិវត្តន៍ កុមារភាព ទេពកោសល្យ សេចក្តីថ្លៃថ្នូរ ហើយដែលប៉ះពាល់ដល់ការអភិវឌ្ឍផ្នែករូបរាងកាយ និងបញ្ញារបស់កុមារ ។

នៅពេលកុមារជួយធ្វើការងារបន្តិចបន្តួចនៅក្នុងគ្រួសាររបស់ខ្លួន ឬ នៅក្នុងសហគមន៍របស់គេ ដោយមិនបង្កឲ្យពួកគាត់មានគ្រោះថ្នាក់ ហើយ ជួយឲ្យពួកគាត់ចេះមានបំណិនផ្សេងៗ នោះគឺអាចជារឿងមួយល្អប្រសើរ។ ការងារបែបនេះ មិនមែនជាពលកម្មកុមារ ឬការជួញដូរកុមារឡើយ ។

ពលកម្មកុមារអាចមានផលប៉ះពាល់មិនល្អចំពោះកុមារ ជាពិសេសនៅពេលដែលការងារនោះ ៖

- មានគ្រោះថ្នាក់ដល់រាងកាយ ឬបញ្ញាស្មារតីរបស់កុមារ
- រារាំងកុមារមិនឲ្យមានមិត្តភក្តិ
- រារាំងកុមារមិនឲ្យចូលរៀន
- រារាំងកុមារមិនឲ្យធ្វើកិច្ចការសាលា
- ធ្វើឲ្យកុមារអស់កម្លាំងមិនអាចទៅរៀនបាន នៅថ្ងៃបន្ទាប់

ពលកម្មកុមារ គឺជាការជួញដូរកុមារ ប្រសិនបើកុមារត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងកេងប្រវ័ញ្ច ដោយឲ្យធ្វើការងារដោយបង្ខំ/ទាសភាព ឬពេស្យាកម្ម/បម្រើផ្លូវភេទ ឬ វះកាត់យកសរីរាង្គរបស់កុមារ។

# សន្លឹកកិច្ចការ ១.៣៖ កន្លែង ពលកម្មកុមារ


ផ្ទះ


អាជីវកម្មជា
លក្ខណៈគ្រួសារ


ហាងលក់ឥវ៉ាន់
ក្នុងមូលដ្ឋាន


ក្នុងរោងចក្រ


ក្នុងវាលស្រែ


ព្រៃ


រង្គសាល



# មេរៀនទី ១.៤៖ ការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ (CSEC)

## វត្ថុបំណង៖

អ្នកចូលរួមនឹងមានអាចកំណត់និយមន័យអំពីការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ និងយល់ថាកុមារដែលត្រូវបានកេងប្រវ័ញ្ចតាមរបៀបនេះ មិនគួរទទួលរងនូវការស្តីបន្ទោសឡើយ ។

## រយៈពេល៖

៧៥ នាទី

## ការរៀបចំ

- មុននឹងចាប់ផ្តើមមេរៀននេះ សូមប្រាប់ឪពុកម្តាយ/អ្នកថែទាំរបស់អ្នកចូលរួមថា ប្រធានបទនៃមេរៀននេះគឺការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ។
- ប្រសិនបើមានអ្នកចូលរួមណាម្នាក់ធ្លាប់ ត្រូវបានគេរំលោភបំពានផ្លូវភេទ ឬត្រូវបានរំលោភ ពីមុនមក សូមប្រាប់ពួកគាត់អំពីប្រធានបទនៃមេរៀននៅនេះ មួយសប្តាហ៍មុនពេលបង្រៀន ដោយជួបជាមួយបុគ្គលផ្ទាល់។ អ្នកចូលរួម អាចសម្រេចចិត្តចូលរួម ឬមិនចូលរួម ។
- ចាំបាច់ត្រូវរៀបចំសេវាបញ្ជូនមួយចំនួន មុនពេលចាប់ផ្តើមរៀន ។
- សូមអានត្រង់ផ្នែកនេះឆ្លើយតមនឹងភាពឈឺចាប់ នៅក្នុងសៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់អ្នកតម្រង់ទិសឆ្លាតវៃ ដើម្បីឆ្លើយតបចំពោះអ្នកចូលរួមដែលស្ថិតក្នុងសភាពទុក្ខព្រួយ ។
- ប្រសិនបើ មានអ្នកចូលរួមណាម្នាក់បង្ហាញនូវភាពក្រៀមក្រំ ក្នុងពេលកំពុងរៀនមេរៀន សូមកុំផ្តោតការយកចិត្តទុកដាក់លើពួកគាត់នៅពេលភ្លាមៗ ហើយមិនត្រូវសួរគេនៅក្នុងចំនោមអ្នកចូលរួមទាំងអស់ទេ។ សូមរងចាំរហូតដល់អ្នកចូលរួមផ្សេងទៀតបានចាកចេញអស់ ទើបសួរអ្នកចូលរួមរូបនោះថា តើគាត់មានអ្វីចង់និយាយប្រាប់យើងឬទេ ។

## កិច្ចស្វាគមន៍

- ចូរស្វាគមន៍ និងណែនាំកុមារឲ្យចូលទៅក្នុងក្រុម
- ចូរលេងល្បែងទាក់ទាញអារម្មណ៍

## តើការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ គឺជាអ្វី?

ចូរពន្យល់ថា ប្រធានបទសម្រាប់មេរៀនថ្ងៃនេះ មានការពិបាកនៅក្នុងការពិភាក្សា ហើយជួនកាល នៅពេលអ្នកចូលរួមពិភាក្សាអំពីប្រធានបទនេះ អាចធ្វើឲ្យពួកគាត់ក៏ក្រៀមក្រំ ។ ចូរពន្យល់ប្រាប់អ្នកចូលរួមថា បើគេគិតថាប្រធានបទនេះពិបាកពិភាក្សា អ្នកចូលរួមអាចអង្គុយនៅស្ងៀមស្ងាត់ ឬអាចចាកចេញក៏បាន។ សូមពន្យល់ថា ប្រសិនបើអ្នកចូលរួមមានទុក្ខក្រៀមក្រំ ហើយចង់និយាយប្រាប់អំពីទុក្ខក្រៀមក្រំរបស់ខ្លួន អ្នកសម្របសម្រួលនឹងនៅចាំស្តាប់គាត់និយាយ នៅពេលចប់មេរៀន ។

សូមពន្យល់ថា លទ្ធផលនៃការជួញដូរមនុស្សអាចធ្វើអោយបុគ្គលធ្លាក់ចូលទៅក្នុងការងារដែលមានគ្រោះថ្នាក់ ។ សូមពន្យល់ថា ជាញឹកញយ អ្នកចូលរួមត្រូវបានគេជួញដូរដើម្បីទៅបម្រើការងារដែលប្រើ កំលាំងកាយ (ឧទាហរណ៍ ការងារក្នុងរោងចក្រ ធ្វើការនៅលើទូកនេសាទបង្គារ ឬធ្វើអ្នកបម្រើតាមផ្ទះ) ។ ប៉ុន្តែ មនុស្សក៏អាចត្រូវបានគេជួញដូរ សម្រាប់លក់ផ្លូវភេទដែរ។

## ការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ

សូមពន្យល់ថាការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ ជាស្ថានការណ៍ដែលមនុស្សម្នាក់ ជាទូទៅ គឺជាមនុស្សពេញវ័យ (ប៉ុន្តែជួនកាលជាកុមារ) រំលោភផ្លូវភេទលើកុមារ ហើយចំណាយប្រាក់លើការរំលោភ នេះ ឬរកប្រាក់ ឬទទួលបានផលប្រយោជន៍ផ្សេងទៀតពីអ្នកដែលចំណាយប្រាក់ក្នុងការកេងប្រវ័ញ្ចផ្លូវភេទពីកុមារ ។ មនុស្សពេញវ័យអាចចាយប្រាក់ ឬតាមមធ្យោបាយណាមួយផ្សេងទៀត ដូចជាផ្តល់អាហារ ឬរបស់របរ ដែលកុមារពេញចិត្ត។

ចូរពន្យល់ថា មានជាច្រើនដងដែលកុមារមិនបានទទួលការប្រាក់ឈ្នួលពីការងាររបស់ខ្លួន។ ប្រាក់នោះ បែរជាបានទៅឲ្យមនុស្សពេញវ័យ ដូចជាម្ចាស់ផ្ទះបន ឬញាតិសន្តានរបស់កុមារទៅវិញ ។

ចូរពន្យល់ថា ការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ អាចនឹងកើតឡើងលើកុមារគ្រប់រូបទាំង ប្រុសទាំងស្រី ។

ចូរពន្យល់ថា ប្រទេសខុសគ្នា ផ្តល់និយមន័យផ្សេងគ្នា ទៅលើពាក្យថាកុមារ ប៉ុន្តែអង្គការទស្សនៈ ពិភពលោក បានកំណត់ថា កុមារ សំដៅលើអ្នកដែលមានអាយុក្រោម១៨ឆ្នាំ។

ការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ មានច្រើនប្រភេទខុសៗគ្នា ប៉ុន្តែប្រភេទសំខាន់ៗមាន ដូចខាងក្រោម ៖

- ពេស្យាចារលើកុមារ (រាប់បញ្ចូលទាំងទេសចរណ៍ផ្លូវភេទ)
- ការថតរូបកុមារអាសអាភាស

**ពេស្យាកម្ម** មានន័យថាមនុស្សម្នាក់ត្រូវវាបានគេអោយប្រាក់ ដើម្បីគេអាចទៅរួមភេទជាមួយ មនុស្សម្នាក់ផ្សេងទៀត ។ ពេលកុមារត្រូវគេបង្ខំឲ្យធ្វើជាពេស្យាចារ ជាធម្មតា អ្នកដែលគ្រប់គ្រង ទៅលើកុមារទាំងនោះ នឹងទទួលយកប្រាក់នេះជំនួសកុមារ ។

**រូបអាសអាភាស** អាចជារឿង រូបភាព និងភាពយន្តអាសអាភាស ។ ជួនកាល គេមើលរូបអាសអាភាស នៅតាមអ៊ីនធឺណិត ឬនៅក្នុងទូរស័ព្ទដៃ ។

នៅពេលកុមារ ធ្លាក់ជាជនរងគ្រោះនៅក្នុង ការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ មនុស្សពេញវ័យដែលគ្រប់គ្រងលើកុមារនោះ នឹងខំព្យាយាមបំបាក់កុមារ ។ អំពើបែបនេះ រួមមាន ការគំរាមកំហែងការវាយដំ ការបង្អត់អាហារ ឬឲ្យកុមារប្រើគ្រឿងញៀន ដើម្បីឲ្យកុមារទាំងនោះធ្វើតាមសម្តីរបស់គេ ហើយបង្ខំ ពួកគាត់ឲ្យញញឹមដាក់ភ្ញៀវ ។

ការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ គឺជាទម្រង់នៃការជួញដូរមនុស្ស ព្រោះថា កុមារកំពុងត្រូវគេកេងប្រវ័ញ្ច ដើម្បីរកប្រាក់ ។

## អ្វីទៅជាកន្លែងពេស្យា?

ចូរពន្យល់ថា ឥឡូវនេះ យើងនឹងពិភាក្សាអំពីប្រធានបទដ៏ពិបាកមួយទៀត។ កន្លែងពេស្យា គឺជាទីដែលបុរសនាំគ្នាទៅកំសាន្ត ដោយចំណាយប្រាក់ដើម្បីរួមភេទ ។ (ជួនកាល ក៏មានការលក់ផ្លូវភេទនៅតាមផ្លូវ ក្នុងភោជនីយដ្ឋាន រង្គសាលខារ៉ាអូខេ និងនៅក្នុងផ្ទះផងដែរ) ។ ជារឿយៗ គេឃើញមាន កន្លែងពេស្យានៅក្នុងសហគមន៍ ហើយក៏មានមនុស្សនៅក្នុងសហគមន៍នោះជាច្រើននាក់ដែរ ដែលដឹងថា ស្គាល់ទីកន្លែងនោះមានអ្វីខ្លះកើតឡើង ។ ក្នុងករណីខ្លះ កន្លែងបែប មានសភាពបិទបាំងណាស់ ប៉ុន្តែមនុស្ស ដែលចង់ចំណាយប្រាក់ដើម្បីរួមភេទ នៅតែរកកន្លែងនោះឃើញ ។

ចូរពន្យល់ថា ស្ត្រី និងកុមារ អាចត្រូវគេជួញដូរទៅកន្លែងពេស្យា ហើយក៏ត្រូវគេបង្ខំឲ្យរួមភេទ ជាមួយភ្ញៀវដែរ ។

ចូរពន្យល់ថា កន្លែងពេស្យាអាចជាចំណែកមួយដែលជំរុញអោយមានការជួញដូរមនុស្ស ហើយកុមារ អាចនឹងត្រូវគេជួញដូរទៅកន្លែងពេស្យា ។

ចូរពន្យល់ថា ដរាបណាមានបុរសទៅកន្លែងពេស្យា ដរាបនោះ ស្ត្រីពេស្យា ដែលគាត់រួមភេទជាមួយ អាចនឹងជាកុមារ ដែលត្រូវបានគេជួញដូរ ។

ចូរពន្យល់ថា ទោះបីជាស្ត្រីដែលគាត់រួមភេទជាមួយនោះ មិនមែនជាកុមារក៏ដោយ ប៉ុន្តែជួនកាល ស្ត្រីរូបនោះ អាចបានត្រូវគេជួញដូរទៅកន្លែងពេស្យា ហើយរូបនាងមិនអាចចាកចេញពីកន្លែងនោះបាន។ ទោះបីជាស្ត្រីពេស្យានោះបានសម្រេចជ្រើសរើសយកការងារនៅកន្លែងពេស្យាក្តី ប៉ុន្តែ ជីវិតរបស់នាង អាចត្រូវ បានគេធ្វើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ មកលើរូបរាងកាយ និង សតិបញ្ញា ។

ចូរសួរទៅអ្នកចូលរួមថា តើមានអ្នកណាម្នាក់ធ្លាប់បានឮគេនិយាយពីពេស្យាចារថា "នាងជាកូនស្រីដ៏ល្អម្នាក់ តែជាស្ត្រីដ៏អាក្រក់មួយរូប" ដែរឬទេ ? ចូរពន្យល់ថា នៅពេលមនុស្សនិយាយពាក្យនេះ ពួកគាត់កំពុងស្តីបន្ទោសទៅលើក្មេងស្រីៗ ដែលបានប្រឡូកខ្លួននៅក្នុងពេស្យាកម្ម ក្នុងគោលបំណងផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ខ្លួន។ នេះគឺជារបួសទីពីរ ។ របួសទីមួយនោះគឺ ពួកនាងជាជនរងគ្រោះ ដោយការជួញដូរ ក្នុងគោលដៅផ្លូវភេទ។ ហើយបន្ទាប់មក សហគមន៍ក៏ធ្វើឲ្យគាត់មាន របួសទីពីរទៀត គឺការរើសអើងចំពោះ ពួកគាត់ ។

ចូរពន្យល់ថា នៅពេល ជនណាត្រូវគេកេងប្រវ័ញ្ចផ្លូវភេទ យើងចាំបាច់ត្រូវទទួលស្គាល់ថា ជនទាំងនោះ ត្រូវបានគេធ្វើបាប ហើយនោះពុំមែនជាកំហុសរបស់គាត់ឡើយ និងត្រូវទទួលស្គាល់ថា ពួកគាត់ត្រូវការជំនួយ និងការទទួលស្គាល់ពីពួកយើងទាំងអស់គ្នា ។

## សង្ខេបមេរៀន

- មនុស្សអាចត្រូវគេជួញដូរ ដើម្បីកេងកម្លាំងពលកម្ម ឬដើម្បីជួញដូរដើម្បីលក់ផ្លូវភេទ ។
- កុមារអាចត្រូវគេជួញដូរ ក្នុងគោលបំណងទាក់ទងនឹងផ្លូវភេទ ។ ទង្វើបែបនេះហៅថាការកេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ ។
- កុមារទាំងប្រុសទាំងស្រី អាចនឹងត្រូវគេជួញដូរ ដើម្បីជាប្រយោជន៍ផ្លូវភេទ ។
- កន្លែងពេស្យាចារអាចរួមចំណែក ជំរុញអោយមានការជួញដូរមនុស្ស ព្រោះកុមារ និងស្ត្រីអាចនឹងត្រូវគេជួញដូរទៅកន្លែងពេស្យាចារ។ ហេតុនេះ បុរសដែលទៅកំសាន្តនៅកន្លែងពេស្យាចារ អាចនិយាយបានថា ពួកគេកំពុងគាំទ្រអោយមានទៅលើឧស្សាហកម្មជួញដូរមនុស្សសម្រាប់ផ្លូវភេទ ។
- វាជាការសំខាន់ក្នុងការគាំទ្រចំពោះជនរងគ្រោះដោយការជួញដូរផ្លូវភេទ និង កេងប្រវ័ញ្ចកុមារសម្រាប់អាជីវកម្មផ្លូវភេទ ។ ជនរងគ្រោះមិនគួរទទួលនូវការស្តីបន្ទោស លើការដែលត្រូវគេជួញដូរ ឡើយ ។

# ម៉ូឌុលទី២៖

## ត្រៀមជាស្រេចដើម្បីធ្វើសកម្មភាព ៖ ធ្វើផែនការយុទ្ធនាការតស៊ូមតិរបស់អ្នក







# ម៉ូឌីលទី២៖
# ត្រៀមជាស្រេចដើម្បីធ្វើសកម្មភាព ៖ ធ្វើផែនការយុទ្ធនាការតស៊ូមតិរបស់អ្នក

## វត្ថុបំណង ៖

អ្នកចូលរួម នឹងមានសមត្ថភាពរៀបរាប់អំពីការតស៊ូមតិ និងចេះអំពីរបៀបរៀបចំយុទ្ធ នាការតស៊ូមតិ ។

General note: All sessions require flip-chart paper and pens.
Additional materials are listed in resources.

## រយៈពេល ៖

៩០ នាទី

## សម្ភារៈ ៖

- ប័ណ្ណព័ត៌មាន "IS២.១ក:  ឧទាហរណ៍នៃការតស៊ូមតិ"
- "IS២.១ខ: ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ"

## ការរៀបចំ ៖

មុននឹងចាប់ផ្តើមរៀនម៉ូឌីលនេះ
នោះអ្នកត្រូវប្រាកដថាឳពុកម្តាយ/អ្នកថែទាំ និងអ្នកចូលរួមបានចុះហត្ថលេខាលើទម្រង់លិខិតយល់ព្រមជាមុនសិន (ប្រសិនបើម៉ូឌីលនេះ ត្រូវយកមកបង្រៀននៅតាមក្លឹបយុវជន) ។
ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ (សូមមើល IS ២.១ខ) ត្រូវបានយកមកប្រើប្រាស់នៅក្នុងម៉ូឌីលនេះទាំងមូល ក្នុងលក្ខណៈជារចនាសម្ព័ន្ធរៀបចំ ។ ជំហានទាំងនោះ ក៏នឹងត្រូវទុកជាឯកសារយោងនៅស្ទើរគ្រប់មេរៀនទាំងអស់ ហើយគួរយកមកបង្ហាញនៅក្នុងពេលបង្រៀនមេរៀននីមួយៗ ។

## ស្វាគមន៍

ប្រសិនបើមេរៀននេះ គឺជាផ្នែកដែលបានយកមកបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលា នោះអ្នកចូលរួមបានស្វាគមន៍គ្នារួចហើយ ។ ប៉ុន្តែប្រសិនបើមេរៀននេះ ត្រូវយកមកបង្រៀននៅក្នុងក្លឹបយុវជនតាមភូមិ នោះសូមស្វាគមន៍យុវជន ។ សូមលេង "ល្បែងបង្កភាពកក់ក្តៅ" ស្រង់ចេញពីបញ្ជីនៅក្នុងឯកសារជំនួយបាន ។

សូមបញ្ជាក់អំពីពេលវេលាបណ្តុះបណ្តាល ។

## ណែនាំអំពីខ្លឹមសារនៅក្នុងម៉ូឌីល

សូមពន្យល់ថាម៉ូឌីល ២ នៃកញ្ចប់ឧបករណ៍នេះ ត្រូវបានរៀបចំឡើងដើម្បីជួយអ្នកចូលរួមឲ្យដឹងថា អ្វីទៅជាការតស៊ូមតិ ហើយថាតើត្រូវចាប់ផ្តើមយុទ្ធនាការតស៊ូមតិដោយរបៀបណា ។

## ការណែនាំអំពីការតស៊ូមតិ

សូមសួររកមើលថាតើមានអ្នកចូលរួមណាម្នាក់អាចពន្យល់បានថាតើអ្វីទៅជាការតស៊ូមតិដែរឬទេ។

សូមពន្យល់ថា ការតស៊ូមតិ គឺមានឥទ្ធិពលទៅលើអ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្តគោលនយោបាយ ដើម្បីផ្លាស់ប្តូរ ឬធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយ និងប្រព័ន្ធទាំងឡាយដែលមានភាពមិនយុត្តិធម៌ ។ អ្នកតស៊ូមតិធ្វើការតស៊ូមតិ តាមយៈការបញ្ចុះបញ្ចូល ការពិភាក្សាដោយមានហេតុផល ។

សូមពន្យល់ថាចំពោះអង្គការទស្សនពិភពលោក ការងារតស៊ូមតិរួមទាំងការជួយមនុស្សឲ្យចេះធ្វើការតស៊ូមតិដោយខ្លួនឯង និងតស៊ូមតិជំនួសអ្នកដទៃដើម្បីឲ្យមានការផ្លាស់ប្តូរគោលនយោបាយ ។ សូមមើលគំរូ (នៃការតស៊ូមតិ) ដូចដែលមានបង្ហាញនៅក្នុងរូបភាព ២.១ ខាង ក្រោម ។

## រូបភាព ២.១ ៖ ការអនុវត្តការតស៊ូមតិទាំងបួនប្រភេទរបស់អង្គការទស្សនពិភពលោក




**សញ្ញាព្រួញបានបង្ហាញនូវគោលបំណងសំខាន់នៃការអប់រំ និងសកម្មភាពគៀងគរ (ប្រជាជន) ដើម្បីឲ្យមានការផ្លាស់ប្តូរគោលនយោបាយ និងឲ្យមានសកម្មភាពអនុវត្តគោលនយោបាយ**

សូមពន្យល់ថាអ្នកតស៊ូមតិ គឺជាមនុស្សដែលខិតខំប្រឹងប្រែងធ្វើឲ្យមានការផ្លាស់ប្តូរនូវគោលនយោ បាយ ឬឲ្យមានការអនុវត្តនូវគោលនយោបាយណាមួយ ។

សូមពន្យល់ពាក្យ គោលនយោបាយ ថាជាទិសដៅនៃសកម្មភាព ដែលប្រកាន់យកដោយស្ថាប័នមួយ ឧទាហរណ៍ ដោយរដ្ឋាភិបាល ដើម្បីនាំផ្លូវ និងកំណត់នូវការសម្រេចចិត្ត និងសកម្មភាពរបស់ មនុស្សនៅក្នុងស្ថាប័នមួយនោះ ។ ឧទាហរណ៍ ប្រសិនបើសាលារៀន មានគោលនយោបាយស្តីពី ការលើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព នោះសាលារៀននោះ អាចនឹងរៀបចំនូវកម្មវិធី និងការណែនាំដើម្បីគាំទ្រការធ្វើចំណាកស្រុកដោយសុវត្ថិភាព ។

បន្ទាប់មក សូមពន្យល់ពាក្យ ទស្សនិកជនគោលដៅ ថាជាមនុស្សដែលអ្នកតស៊ូមតិ មានបំណង ចង់ធ្វើឲ្យមានឥទ្ធិពលទៅលើពួកគាត់ទាំងនោះ ។ ទស្សនិកជនគោលដៅ សម្រាប់អ្នកតស៊ូមតិរបស់ អង្គការទស្សនពិភពលោក សំដៅដល់អ្នកទាំងឡាយណាដែលមានអំណាចក្នុងការរៀបចំ ឬអនុវត្តច្បាប់ និងគោលនយោបាយ ដូចជាអ្នករៀបចំគោលនយោបាយ អ្នកតាក់តែងច្បាប់ អ្នកនយោបាយ និង មន្ត្រីរាជការស៊ីវិលរបស់រដ្ឋាភិបាល ។

សូមពន្យល់ថា យុទ្ធនាការតស៊ូមតិ គឺជាសកម្មភាពដែលក្រុម (តស៊ូមតិ) មួយធ្វើឡើង ដោយមានជា ផែនការ និងអនុវត្តផែនការនោះ ក្នុងគោលបំណងឲ្យមានការផ្លាស់ប្តូរគោលនយោបាយ និងលើក កម្ពស់ការយល់ដឹងទៅលើបញ្ហាជាក់លាក់ណាមួយដើម្បីទទួលបាននូវការគាំទ្រពីសាធារណជន ។

អ្នកចូលរួម អាចនឹងមានអារម្មណ៍ភិតភ័យ នៅពេលដែលគិតទៅដល់ការធ្វើយុទ្ធនាការតស៊ូមតិ ដើម្បីឲ្យអ្នករៀបចំគោលនយោបាយ អ្នកតាក់តែងច្បាប់ និងអ្នកនយោបាយ ។ល។ មានការផ្លាស់ ប្តូរនូវគោលនយោបាយរបស់ពួកគេ ។ សូមធានាជូនអ្នកចូលរួមថាយុទ្ធនាការតស៊ូមតិ អាចធ្វើឡើង ក្នុងទ្រង់ទ្រាយតូចក៏បាន ធំក៏បាន ។ ឧទាហរណ៍ សិស្សមួយក្រុម ដែលរៀបចំព្រឹត្តិការណ៍មួយ ដើម្បីផ្លាស់ប្តូរគោលនយោបាយរបស់សាលារៀនពាក់ព័ន្ធ នឹងថាតើអាចអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិ បាលក្នុងស្រុកមួយចែករំលែកនូវសារចំណេះដឹងអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពក្នុងចំណោម សិស្សបានដែរ ឬក៏អត់ នោះគឺមានន័យថាការរៀបចំដូច្នេះមានលក្ខណៈជាយុទ្ធនាការតស៊ូមតិ ហើយ ។

សូមពន្យល់ថាការចូលរួមនៅក្នុងព្រឹត្តិការណ៍តស៊ូមតិ គឺធ្វើឡើងដោយការស្ម័គ្រចិត្ត ។ អ្នកចូលរួម អាចសម្រេចចិត្តនៅក្នុងដំណាក់កាលណាមួយថាតើត្រូវចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិដែរ ឬ ក៏ អត់ ។

ជាមួយគ្នានេះ សូមពន្យល់ផងដែរថា ព្រឹត្តិការណ៍តស៊ូមតិ មិនគួរធ្វើឲ្យអ្នកចូលរួមស្ថិតនៅក្នុងភាព ប្រឈមមុខជាមួយនឹងគ្រោះថ្នាក់នោះទេ ។ សូមពន្យល់ថានៅពេលធ្វើយុទ្ធនាការតស៊ូមតិ នោះជា ការសំខាន់ណាស់ដែលត្រូវធានានូវសុវត្ថិភាពរបស់អ្នកចូលរួម ។

## ចែករំលែកនូវឧទាហរណ៍នៃការតស៊ូមតិ

សូមពន្យល់ថាព្រឹត្តិការណ៍តស៊ូមតិ អាចជាព្រឹត្តិការណ៍ដ៏តូចមួយនៅក្នុងសហគមន៍របស់ពួកគេ ឬជា ព្រឹត្តិការណ៍ដ៏ធំដែលមានការសម្របសម្រួលរវាងសហគមន៍នានា ឬក៏ព្រឹត្តិការណ៍ធំជាងនេះដែល មានការសម្របសម្រួលរវាងបណ្តាប្រទេសនានា។ ព្រឹត្តិការណ៍តស៊ូមតិដែលមានទ្រង់ទ្រាយធំ ជារឿយៗ កើតចេញពីកិច្ចសហប្រតិបត្តិការរវាងមនុស្សវ័យក្មេង និងអង្គការមិនមែនរដ្ឋាភិបាល ឬ ស្ថាប័នផ្សេងៗទៀត ។

ចែកឲ្យនូវប័ណ្ណព័ត៌មាន "IS ២.១ក ៖ ឧទាហរណ៍នៃការតស៊ូមតិ" សូមឲ្យអ្នកចូលរួមបំបែកគ្នាជាក្រុម ដែលមានសមាជិកពី ៦-៨ នាក់ រួចហើយឲ្យអាននូវឧទាហរណ៍ទាំងនោះ ដែលផ្អែកទីលើរឿងពិត ។ បន្ទាប់មកឲ្យក្រុមនីមួយៗ ពិភាក្សាគ្នានូវសំណួរខាងក្រោម ។ សូមចំណាយពេលជាមួយនឹងក្រុម នីមួយៗ ដើម្បីធានាថាសមាជិកក្រុមទាំងអស់យល់អំពីឧទាហរណ៍ទាំងនោះច្បាស់លាស់ ។

## ណែនាំអំពីជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ

ចែកឲ្យប័ណ្ណព័ត៌មាន "IS២.១ខ ៖ ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ ។

សូមពន្យល់ថានៅក្នុងមេរៀននេះទាំងមូល នោះអ្នកចូលរួម ត្រូវអនុវត្តតាមនូវជំហានទាំងនេះ ក្នុងការរៀបចំយុទ្ធនាការតស៊ូមតិផ្ទាល់ខ្លួនរបស់ពួកគេ ។ (ជំហានទាំងនោះ គួរដាក់បង្ហាញនៅរាល់ពេល រៀនមេរៀនទាំងអស់ ។) សូមឲ្យអ្នកចូលរួមអានជំហានទាំងនោះឮៗ ។

សូមពន្យល់ថាវាក៏មិនមានជាបញ្ហាអ្វីដែរ ប្រសិនបើអ្នកចូលរួមមិនយល់អំពីជំហានទាំងអស់នោះ ភ្លាមៗទេ ។ ពួកគេនឹងសិក្សាអំពីជំហានទាំងអស់នោះ នៅក្នុងម៉ូឌីលនៃមេរៀនមួយ ។ សួរថាតើ មាននរណាម្នាក់មានចម្ងល់ដែរ ឬទេ ?

## សង្ខេបមេរៀន

- ការតស៊ូមតិ គឺជាការខិតខំប្រឹងប្រែងដើម្បីដោះស្រាយនូវបញ្ហាមួយ ឬដើម្បីគាំទ្រនូវបុព្វ ហេតុមួយតាមរយៈការធ្វើឲ្យមានការផ្លាស់ប្តូរគោលនយោបាយ ការធ្វើច្បាប់ ឬការអនុវត្ត (គោលនយោបាយ) ។
- ទស្សនិកជនគោលដៅ ដែលអ្នកតស៊ូមតិ មានគោលបំណងធ្វើឲ្យមានឥទ្ធិពលទៅលើពួកគេនោះ គឺជាមនុស្សដែលមានសិទ្ធិអំណាចក្នុងការធ្វើ ឬអនុវត្តច្បាប់ ឬគោលនយោបាយ ។
- អ្នកតស៊ូមតិ គឺជាមនុស្សដែលខិតខំប្រឹងប្រែងធ្វើឲ្យមានការផ្លាស់ប្តូរនូវគោលនយោបាយ ឬដើម្បីឲ្យមានការអនុវត្តគោលនយោបាយណាមួយ ។ យុទ្ធនាការតស៊ូមតិ មានដូចជា សកម្មភាពទាំងឡាយណាដែលក្រុមតស៊ូមតិមួយ បានរៀបចំផែនការ និងអនុវត្តនូវផែនការ នោះដើម្បីធ្វើឲ្យមានឥទ្ធិពលផ្លាស់ប្តូរដល់គោលនយោបាយ និងដើម្បីលើកកម្ពស់ការយល់ ដឹងទៅលើបញ្ហាជាក់លាក់ណាមួយដល់សាធារណជន ។ ការតស៊ូមតិ អាចធ្វើឡើងក្នុង លក្ខណៈជា ជាព្រឹត្តិការណ៍តាមមូលដ្ឋានទ្រង់ទ្រាយតូច ឬជាព្រឹត្តិការណ៍ធំៗ ដែលបានរៀបចំឡើងក្នុងចំណោមសហគមន៍ ឬបណ្តាប្រទេសនានា ។

# IS ២.១ក ៖ ឧទាហរណ៍នៃការតស៊ូមតិ

## ឧទាហរណ៍ទី ១



ក្មេងស្រីមួយក្រុមនៅក្នុងប្រទេសកម្ពុជា បានចូលរួមនៅក្នុងកម្មវិធីមួយដែលមានឈ្មោះថា កម្មវិធី ក្រោយម៉ោងសិក្សា ដែលនៅក្នុងកម្មវិធីនេះ ពួកគេបានរៀនអំពីបំណិនជីវិត ។ នៅក្នុងក្រុម ពួកគេទទួលស្គាល់ថាវាពិតជាមានការលំបាកណាស់សម្រាប់ក្មេងស្រីមករៀននៅសាលារៀនពីព្រោះ សាលារៀន មានបន្ទប់ទឹកតែមួយ ហើយត្រូវប្រើប្រាស់រួមគ្នាទាំងសិស្សប្រុស និងសិស្សស្រី ។ ដូច្នេះក្មេងស្រីមានការខ្មាស់អៀនណាស់ក្នុងការចូលបន្ទប់ទឹកម្តងៗ ។ ពួកគេក៏បានដឹងទៀតថា ឪពុកម្តាយមួយចំនួននៅតាមភូមិ បានហាមឃាត់ក្មេងស្រីមិនឲ្យទៅរៀននៅសាលារៀនទេ ពីព្រោះតែសាលារៀនអត់មានបន្ទប់ទឹកសម្រាប់តែសិស្សស្រីប្រើប្រាស់ ។ ដូចនេះ សិស្សស្រីទាំងនោះ ក៏ធ្វើយុទ្ធនាការតស៊ូមតិមួយ ។ ក្មេងស្រីមួយក្រុមខាងលើនេះ ក៏បានដឹងផងដែរថានៅក្នុងតំបន់ជន បទដាច់ស្រយាលរបស់ពួកគេ សិស្សស្រីៗទំនងជាបោះបង់ចោលការសិក្សាច្រើនជាងសិស្សប្រុស ហើយពួកគេក៏បានដឹងអំពីផលវិបាកនៃរឿងនេះមកលើជីវិតរបស់ពួកគេផងដែរ ។ ពួកគេបានសួរ ជាងសំណង់ម្នាក់ថាតើបង្គន់ថ្មីមួយត្រូវសាងសង់អស់ទឹកប្រាក់ចំនួនប៉ុន្មាន ។ ពួកគេបានស្នើសុំឲ្យប្រធានក្រុមយុវជនរបស់ពួកគេ ជួយពួកគេក្នុងការរៀបចំនូវកិច្ចប្រជុំមួយជាមួយនឹងនាយកសាលារៀន ។ ពួកគេបានសរសេរលិខិតមួយដោយបានពន្យល់ថាសិស្សស្រី មានអារម្មណ៍មិនល្អសោះ ចំពោះសាលារៀនពីព្រោះតែសាលារៀនមានបង្គន់តែមួយ ហើយក៏បានពន្យល់អំពីផលវិបាកអវិជ្ជ មាននាំការបោះបង់ចោលការសិក្សារបស់សិស្សស្រី ។ ពួកគេបានជម្រាបជូននាយកសាលាអំពី តម្លៃនៃការសាងសង់បង្គន់ថ្មីមួយសម្រាប់សិស្សស្រី ។ នាយកសាលា ក៏បានសម្រេចចិត្តចាត់វិធាន ការដោយបានស្នើសុំឲ្យឪពុកម្តាយសិស្សដែលមានទ្រព្យសម្បត្តិ នៅក្នុងសាលារៀននោះជួយបរិ ច្ចាកនូវលុយកាក់តិចតួចរបស់ពួកគេសាងសង់នូវបង្គន់ថ្មីមួយសម្រាប់តែសិស្សស្រី ។

## ឧទាហរណ៍ទី ២



សាលារៀនមួយនៅក្នុងប្រទេសវៀតណាម មានកុមារជាច្រើន បានមកជួយធ្វើការឲ្យឪពុកម្តាយ របស់ពួកគេក្រោយចេញពីសាលារៀន ។ ជាមួយគ្នានោះ ក៏មានអង្គការមិនមែនរដ្ឋាភិបាលមួយបានជួយបង្រៀនបន្ថែមម៉ោងសម្រាប់សិស្សក្រីក្រ ប៉ុន្តែការបង្រៀនបន្ថែមម៉ោងនោះ ត្រូវធ្វើឡើង ភ្លាមៗ បន្ទាប់ពីម៉ោងរបស់សាលារដ្ឋ ដូច្នេះកុមារដែលជួយធ្វើការឪពុកម្តាយរបស់ពួកគេ មិនអាចមកចូលរៀនបានឡើយ ។ មានកុមារមួយចំនួន ជាសមាជិករបស់ក្រុមយុវជន ដែលពួកគេតែងតែជួបជុំគ្នា រៀងរាល់ព្រឹកថ្ងៃអាទិត្យ ។ ពួកគេបានពិភាក្សាអំពីបញ្ហានៅក្នុងក្រុមរបស់ពួកគេ ។ ពួកគេរកឃើញ ថាប្រសិនបើការបង្រៀនបំប៉នបន្ថែម ធ្វើឡើងនៅព្រឹកព្រលឹមថ្ងៃសៅរ៍ នោះកុមារដែលជួយធ្វើការឪពុកម្តាយរបស់ពួកគេក្រោយពីចុះពីសាលារៀនរដ្ឋ នឹងអាចមករៀនបាន ។ ពួកគេបានស្នើសុំជំនួយពីគ្រូបង្រៀនរបស់ពួកគេ ដើម្បីស្វែងរកវិធីទាក់ទងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលមួយ នោះ ។ នៅពេលដែលពួកគេរកឃើញឈ្មោះមនុស្សដែលទទួលបន្ទុកគ្រប់គ្រងកម្មវិធី ពួកគេក៏បាន រៀបចំឲ្យមានការប្រជុំមួយ ។ ពួកគេក៏បានសម្រេចផងដែរថាវានឹងមានប្រសិទ្ធភាពរឹតតែខ្ពស់ ប្រសិនបើកុមារដែលជួយធ្វើការឪពុក ម្តាយរបស់ពួកគេ បានប្រាប់អ្នកទទួលបន្ទុកគ្រប់គ្រងកម្មវិធី របស់អង្គការ នូវរឿងរ៉ាវពិតរបស់ពួកគេ ។ កុមារបានសរសេររៀបរាប់យ៉ាងខ្លីអំពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ រៀបរាប់អំពីក្តីសង្ឃឹមរបស់ពួកគេក្នុងការធ្វើការងារអ្វីមួយ និងពួកគេបានប្រាប់ថាតើហេតុអ្វី បានជាពួកគេត្រូវការថ្នាក់បំប៉នបន្ថែម ។ ពួកគេបានអនុវត្តការនិយាយរឿងនេះ រហូតដល់ពួកគេ មានជំនឿចិត្តខ្លាំង និងចាំបានល្អ ។ ក្រោយ មក នៅពេលដែលពួកគេទៅធ្វើទស្សនកិច្ចនៅអង្គការនោះ ពួកគេបានផ្លាស់ប្តូរវេនគ្នានិយាយរឿងរ៉ាវរបស់ពួកគេ ។ អង្គការមិនមែនរដ្ឋាភិបាលនោះក៏ បានផ្លាស់ប្តូរនូវគោលន យោបាយ និងរបៀបរបបនៃការធ្វើការរបស់ខ្លួនដោយបានចាប់ផ្តើមបង្រៀនបំប៉នបន្ថែមនៅពេលវេលាសមស្របដែលកុមារជួយធ្វើការឪពុកម្តាយទាំងនោះ អាចមកចូលរៀនបាន ។

## សំណួរ

សម្រាប់ឧទាហរណ៍នីមួយៗ ខាងលើនេះ សូមពិភាក្សានូវសំណួរទាំងនេះ ។

- តើនរណារៀបចំនូវយុទ្ធនាការតស៊ូមតិ ?
- តើពួកគេ កំពុងខិតខំប្រឹងប្រែងព្យាយាមធ្វើឲ្យមានឥទ្ធិពលទៅលើនរណាខ្លះ ?
- តើព្រឹត្តិការណ៍នោះ បាននាំមកនូវដំណោះស្រាយចំពោះបញ្ហា ឬធ្វើឲ្យមានការផ្លាស់ប្តូរ គោលនយោបាយដោយរបៀបណា ?
- តើអ្នកធ្លាប់បានឮនូវការតស៊ូមតិណាមួយ ដែលអ្នកតស៊ូមតិបានធ្វើឡើងដើម្បីឲ្យមានការ ផ្លាស់ប្តូរ នៅក្នុងសហគមរបស់អ្នកដែរ ឬទេ ? តើអ្នកអាចចែករំលែករឿងនេះ ជាមួយនឹង អ្នកដទៃទៀតបានដែរ ឬទេ ?

## IS ២.១ខ ៖ ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ

១. កំណត់បញ្ហា ៖ តើបញ្ហា ឬរឿងរ៉ាវជាក់លាក់ណាមួយ ដែលយើងចង់ដោះស្រាយ ?

២. ធ្វើការស្រាវជ្រាវអំពីបញ្ហា ៖ តើយើងអាចរៀនបានអ្វីខ្លះពីបញ្ហានេះ ?

៣. កំណត់នូវគោលបំណងនៃយុទ្ធនាការតស៊ូមតិ ៖ តើយើងចង់ឲ្យមានការផ្លាស់ប្តូរ ឬដំណោះស្រាយអ្វីខ្លះ ?

៤. កំណត់នូវទស្សនិកជនគោលដៅ ៖ តើយើងចង់ឲ្យមានឥទ្ធិពលទៅលើនរណាខ្លះក្នុងការ សម្រេចបាននូវគោលបំណងរបស់យើង ?

៥. រៀបចំនូវសារយុទ្ធនាការតស៊ូមតិ ៖ តើសារអ្វីខ្លះ ដែលយើងចង់បង្ហាញជូនដល់ឲ្យទស្សនិក ជនគោលដៅរបស់យើង ?

៦. ធ្វើផែនការសកម្មភាពយុទ្ធនាការតស៊ូមតិ ពេលវេលា និងថវិការ ៖ តើយើងត្រូវធ្វើអ្វីខ្លះដើម្បីសម្រេចនូវគោលដៅរបស់យើង ?

៧. វាយតម្លៃគ្រោះថ្នាក់ចំពោះយុវវ័យនៅក្នុងការធ្វើយុទ្ធនាការតស៊ូមតិ ៖ តើយើងធ្វើឲ្យប្រាកដដោយរបៀបណាថាយុទ្ធនាការតស៊ូមតិ មានសុវត្ថិភាព សម្រាប់ពួកយើង ?

៨. កំណត់នូវអ្នកគាំទ្រ។

៩. អនុវត្តយុទ្ធនាការតស៊ូមតិ ។

១០. វាយតម្លៃយុទ្ធនាការតស៊ូមតិ ៖ តើយុទ្ធនាការនោះ ទទួលបានជោគជ័យកម្រិតណា ? តើនៅមានបញ្ហាប្រឈមអ្វីខ្លះ ដែលយើងនៅជួបប្រទះ ?

១១. សម្លឹងមើលទៅអនាគត ៖ តើយើងចង់ធ្វើអ្វីបន្តទៀត?


1. កំណត់បញ្ហា ឬរឿងរ៉ាវ
2.ធ្វើការស្រា ជ្រា វ អំពីបញ្ហា
3 កំណត់គោល បំណងនៃយុទ្ធនាការ តស៊ូមតិ
4 កំណត់ទស្សនិកជន គោលដៅ
5 រៀបចំទូវសារ យុទ្ធនាការតស៊ូមតិ
6 ធ្វើផែនការសកម្មភាព យុទ្ធនាការតស៊ូមតិពេលវេលាថវិការ
7 វាយតម្លៃគ្រោះថ្នាក់ចំពោះយុវវ័យនៅក្នុងការធ្វើយុទ្ធនាការតស៊ូមតិ
8 កំណត់អ្នកគាំទ្រ
9អនុវត្តយុទ្ធនាការ តស៊ូមតិ
10 វាយតម្លៃយុទ្ធនាការ តស៊ូមតិ
សម្លឹងមើលទៅ អនាគត



# មេរៀន ២.២
# កំណត់នូវបញ្ហាគន្លឹះនៃយុទ្ធនាការតស៊ូមតិ

## វត្ថុបំណង ៖

អ្នកចូលរួមនឹងមានសមត្ថភាពកំណត់នូវបញ្ហានានាដែលជាប់ពាក់ព័ន្ធជាមួយនឹង ការជួញដូរមនុស្ស ឬការធ្វើចំណាកស្រុកគ្មានសុវត្ថិភាពនៅក្នុងសហគមរបស់ពួកគេ ។ អ្នកចូលរួមនឹងជ្រើសរើសនូវបញ្ហាជាក់លាក់ណាមួយ ដែលជាបញ្ហាត្រូវផ្តោតការយកចិត្តទុកដាក់នៅក្នុងការធ្វើយុទ្ធនាការតស៊ូមតិ ។

## រយៈពេល ៖

៩០ នាទី

## ស្វាគមន៍

ប្រសិនបើមេរៀននេះ គឺមេរៀនមួយផ្នែក ដែលបានយកមកបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលា នោះអ្នកចូលរួមបានស្វាគមន៍គ្នារួចហើយ ។ ប៉ុន្តែប្រសិនបើមេរៀននេះ ត្រូវយកមកបង្រៀននៅក្នុង ក្លឹបយុវវ័យតាមភូមិ នោះសូមស្វាគមន៍យុវជន ។ សូមលែង "ល្បែងបង្កភាពកក់ក្តៅ" ដោយអាចដកស្រង់ចេញពីបញ្ជី នៅក្នុងឯកសារគាំទ្របាន ។

## សម្ភារ ៖

- ប័ណ្ណព័ត៌មាន "IS ២.១ខ ៖ ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ"
- ប័ណ្ណព័ត៌មាន "IS២.២ក ៖ សំណួរសកម្មភាពតាមផែនការ"
- ក្រដាសស្អិតមួយដុំ (ក្រដាសដែលផ្ទៃស្អិតមួយចំរៀកតូច) ។
- ក្រដាសបឺសន្លឹក ដែលមានសរសេរអក្សរថា "កើតឡើងជាញឹកញាប់", "កើតឡើងម្តងម្កាល", និង"កម្រកើតឡើង"
- ក្រដាសបឺសន្លឹក ដែលមានសរសេរអក្សរថា "ធ្ងន់ធ្ងរ", "ធ្ងន់ធ្ងរណាស់" និង "ធ្ងន់ធ្ងរជាទីបំផុតហើយអាចកើតឡើងបាន"
- ប័ណ្ណព័ត៌មាន "IS២.២ខ ៖ ការរៀបបញ្ហាតាមលំដាប់"

## ណែនាំអំពីសកម្មភាពធ្វើតាមផែនការ

សួរថាតើមាននរណាម្នាក់អាចចងចាំអំពីជំហានទាំងឡាយ ឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិកាលពីរៀនមេរៀនលើកចុងក្រោយដែរ ឬទេ? ប្រសិនបើគ្មានអ្នកណាចងចាំទេ នោះសូមឲ្យអ្នកចូលរួមណាម្នាក់អាននូវជំហានទាំងនោះឮៗពីប័ណ្ណព័ត៌មាន "IS២.១ខ ៖ ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ"។ (អ្នកគួរបិទបង្ហាញនូវជំហានទាំងនោះនៅរាល់ពេលរៀនមេរៀនទាំងអស់។)

សូមពន្យល់ថាមេរៀននៅថ្ងៃនេះ គឺនិយាយអំពី "ជំហានទី ១. បញ្ហា ៖ តើបញ្ហាអ្វីទៅដែលយើងចង់ដោះស្រាយ?" នេះមានន័យថានៅថ្ងៃនេះ អ្នកចូលរួមនឹងសម្រេចចិត្តទៅលើបញ្ហាជាក់លាក់ណា មួយដែលពួកគេចង់ដោះស្រាយនៅក្នុងពេលធ្វើយុទ្ធនាការរបស់ពួកគេ ។ សូមពន្យល់ថាមេរៀន នេះ នឹងផ្តោតទៅលើការកំណត់បញ្ហា ។ ដំណោះស្រាយដែលអាចដោះស្រាយបញ្ហាបាន នឹងត្រូវ លើកយកមកពិភាក្សានៅពេលក្រោយ ។ (ប្រសិនបើអ្នកចូលរួមមានការភ័ន្តច្រឡំ សូមប្រើប្រាស់ ឧទាហរណ៍មួយនេះ ៖ បញ្ហានោះគឺថា ក្រុមហ៊ុនរថយន្តក្នុងស្រុកមួយបានអនុញ្ញាតឲ្យមេខ្យល់ទុច្ចរិត ធ្វើការជ្រើសរើសអ្នកធ្វើចំណាកស្រុកនៅលើរថយន្តក្រុង ។ ដំណោះស្រាយ អាច

ថាក្រុមហ៊ុន រថយន្តក្រុងក្នុងស្រុកនោះ ត្រូវបង្កើតនូវគោលនយោបាយមួយក្នុងការហាមឃាត់មេខ្យល់មិនឲ្យ ជ្រើសរើសកម្មករនៅលើរថយន្តក្រុងជាដាច់ខាត ។ )

សូមពន្យល់ថាការតស៊ូមតិ គឺមានប្រសិទ្ធិភាពបំផុត ប្រសិនបើការតស៊ូមតិនោះ ដោះស្រាយនូវ បញ្ហាពិតៗ ដែលមានភាពទាក់ទងជាមួយនឹងប្រជាពលរដ្ឋ ក្នុងន័យសង្ឃឹមថានឹងមានការផ្លាស់ប្តូរ ណាមួយកើតឡើង។ ដោយសារហេតុផលនេះ សកម្មភាពនេះនឹងជួយដល់អ្នកចូលរួមអាចកំណត់ បាននូវបញ្ហានានា ដែលកើតមានឡើងនៅក្នុងសហគមរបស់ពួកគេ ។

សូមឲ្យអ្នកចូលរួមបំបែកគ្នាជាបួនក្រុម ។

ចែកឲ្យក្រុមនីមួយៗនូវក្រដាសផ្លីបឆាត, ប៊ិច និងក្រដាសស្អិតមួយដុំ ។ សូមពន្យល់ថាក្រុមនីមួយៗ ត្រូវធ្វើសកម្មភាព "ធ្វើតាមផែនការ" ។ សូមពន្យល់ថាក្រុមនីមួយៗ មានសំណួរផ្សេងៗគ្នាសម្រាប់ ឆ្លើយនៅក្នុងសកម្មភាព ធ្វើតាមផែនការ ហើយថាចម្លើយទៅនឹងសំណួរ ត្រូវសរសេរនៅលើក្រដាសស្អិត ។ ពួកគេត្រូវសរសេរចម្លើយមួយ នៅលើក្រដាសស្អិតមួយសន្លឹក បើមិនធ្វើដូច្នេះទេ នោះការ ធ្វើសកម្មភាពនៅក្នុងមេរៀននេះ នឹងមិនអាចដំណើរការបានល្អទេ ។

សូមពន្យល់ថាបន្ទាប់ពីរយៈពេលប្រាំនាទី នោះនឹងមានមនុស្សចំនួនពីរនាក់មកពីក្រុមនីមួយៗ ត្រូវចេញពីក្រុមរបស់ខ្លួន ហើយចូលរួមជាមួយនឹងក្រុមនៅខាងស្តាំដែលនៅជិតបំផុត ។ បន្ទាប់មកទៀត ពួកគេនឹងបន្តបង្កើតសកម្មភាព ធ្វើតាមផែនការ ជាមួយនឹងក្រុមថ្មី ។

ចែកឲ្យក្រុមនីមួយៗនូវសំណួរផ្សេងៗគ្នា ដែលមាននៅក្នុងប័ណ្ណព័ត៌មាន "IS២.២ក ៖ សំណួរសកម្មភាពធ្វើតាមផែនការ"។

## សកម្មភាពធ្វើតាមផែនការ

សុំឲ្យក្រុមទាំងអស់ធ្វើសកម្មភាពតាមផែនការ របស់ពួកគេសម្រាប់រយៈពេលប្រាំនាទី ។

ក្រោយមក បន្ទាប់ពីរយៈពេលប្រាំនាទីនេះ សុំឲ្យសមាជិកពីរនាក់មកពីក្រុមនីមួយៗ ចូលរួមជាមួយនឹងក្រុមនៅខាងស្តាំជិតបំផុត ។ ឲ្យពួកគេចូលរួមបង្កើតក្រុមថ្មីបែបនេះ ចំនួនបីដឹង ។ ពេលបង្កើត ក្រុមថ្មីម្តងៗស្នើឲ្យអ្នកចូលរួមដែលមិនធ្លាប់ចូលរួមជាមួយសមាជិកក្រុមថ្មីពីមុនសោះ ឲ្យចូលរួមជា មួយសមាជិកថ្មី ។ ( សកម្មភាពទាំងមូលនេះ ប្រើប្រាស់ពេលវេលា ១៥ នាទី ) ។

នៅពេលធ្វើសកម្មភាពតាមផែនការ ត្រូវបានបញ្ចប់រួចរាល់ហើយ នោះសូមអាននូវលទ្ធផលឮៗ ដល់ សមាជិកក្រុមទាំងមូល ។

## រៀបបញ្ហាតាមលំដាប់

សូមគូររូបចម្លងឲ្យបានធំតាមប័ណ្ណព័ត៌មាន "IS២.២ខ ៖ រៀបបញ្ហាតាមលំដាប់" នៅលើក្រដាសផ្លីប ឆាត រួចហើយបិទក្រដាសនៅទីកន្លែងដែលអ្នកចូលរួមងាយមើលឃើញ ។

សុំឲ្យអ្នកចូលរួមមើលមកក្រដាសផ្លីបឆាតនោះ ។ សូមពន្យល់ថាពួកគេ ត្រូវរៀបចម្លើយដែលសរ សេរនៅលើក្រដាសស្អិត យកមកបិទនៅលើក្រដាសផ្លីបឆាត ។ សូមពន្យល់ថាពាក្យនៅខាងលើក្រ ដាសផ្ទាំងធំនេះ អាចរៀបបញ្ហាដែលមាននៅលើក្រដាសស្អិតបាន ដោយផ្អែកលើថាបញ្ហាធ្ងន់ធ្ងរ កម្រិតណា ។ បញ្ហា ដែលបានរៀបរាប់នៅលើក្រដាសស្អិតដែលវា ធ្ងន់ធ្ងរ ត្រូវដាក់នៅកូឡោនខាង ឆ្វេង ចំណែកឯបញ្ហាដែលវា ធ្ងន់ធ្ងរបំផុត ត្រូវដាក់នៅកូឡោនកណ្តាល ហើយបញ្ហា ដែល ធ្ងន់ធ្ងរ ជាទីបំផុតហើយអាចកើតឡើងបាន ត្រូវដាក់នៅក្នុងកូឡោនខាងស្តាំ ។

បន្ទាប់មកទៀត សូមពន្យល់ពាក្យនៅក្នុងកូឡោនខាងឆ្វេងនៃឆាត ដែលរៀបបញ្ហាតាមលំដាប់ និងដែលសរសេរនៅលើក្រដាសស្អិត ផ្អែកលើថាបញ្ហានោះកើតឡើងញឹកញាប់កម្រិតណា ។ បញ្ហាដែល កើតឡើងញឹកញាប់ត្រូវដាក់នៅខាងជួរលើ រីឯបញ្ហាដែលកើតឡើង ម្តងម្កាល ត្រូវដាក់នៅជួរទីពីរ ហើយបញ្ហាដែល កម្រ កើតមានឡើងត្រូវដាក់នៅក្នុងជួរខាងក្រោមគេបង្អស់ ។

សកម្មភាពនេះ អាចធ្វើឲ្យអ្នកចូលរួមមានការយល់ច្រឡំបន្តិច ដូច្នេះត្រូវប្រើពេលច្រើននាទីបន្តិច ដើម្បីពន្យល់ពួកគេថាតើឆាតនេះដំណើរការយ៉ាងដូចម្ដេច ។ (វាកាន់តែមានភាពងាយស្រួលទៅ ទៀតក្នុងការពន្យល់ឲ្យអ្នកចូលរួមយល់ ប្រសិនបើអ្នកសម្របសម្រួលពន្យល់ដោយធ្វើការចង្អុល តារាងនោះ) ។ សូមយកក្រដាសស្អិតមួយ ដែលមានសរសេរបញ្ហា រួចហើយសុំឲ្យអ្នកចូលរួមសម្រេច ថាតើបញ្ហានេះ វាធ្ងន់ធ្ងរ ធ្ងន់ធ្ងរណាស់ ឬធ្ងន់ធ្ងរជាទីបំផុតហើយអាចកើតឡើងបាន ។ បន្ទាប់មក ទៀត សូមឲ្យពួកគេសម្រេចថាតើបញ្ហានេះ កើតឡើង ញឹកញាប់ ម្ដងម្កាល ឬកម្រ ។

សុំឲ្យអ្នកចូលរួមកំណត់ថាតើប្រអប់នៅក្នុងតារាង ដែលថាបញ្ហាធ្ងន់ធ្ងរកម្រិតណា ត្រូវកាត់កែងជា មួយនឹងលទ្ធភាពកើតឡើងញឹកញាប់នៃបញ្ហា ។ ឧទហរណ៍ ប្រសិនបើក្រដាសស្អិតសរសេរថា "ការជួញដូរផ្លូវភេទកុមារ" នោះអ្នកចូលរួម អាចសម្រេចចិត្តថាវាជាបញ្ហា ធ្ងន់ធ្ងរជាទីបំផុតហើយអាច កើតឡើងបាន ប៉ុន្តែវា ក៏អាចជាបញ្ហាកម្រ កើតមានឡើងដែរ ។ ដូច្នេះក្រដាសស្អិត ត្រូវដាក់នៅ ក្នុងប្រអប់នៅជ្រុងខាងក្រោមនៃតារាងនៅខាងស្ដាំដៃ ដែលជួរពាក្យថា កម្រ កាត់ជាមួយនឹងកូឡោន ដែលមានពាក្យ ធ្ងន់ធ្ងរ ។

ធ្វើដំណើរការនេះឡើងវិញ ដោយត្រូវបង្ហាញជាក់ស្ដែងអំពីរបៀបរៀបបញ្ហាតាមលំដាប់ បន្ថែមទៀត រហូតដល់អ្នកប្រាកដថាអ្នកចូលរួម បានយល់ហើយ ។

បន្ទាប់មកទៀត សូមឲ្យសមាជិករបស់ក្រុម ស្វែងរកដំណោះស្រាយទៅនឹងបញ្ហា ដែលពួកគេសរសេរនៅលើក្រដាសស្អិត ហើយរៀបដាក់ក្រដាសស្អិតនោះនៅលើតារាង ។ សូមលើកទឹកចិត្តឲ្យមាន ការពិភាក្សាក្នុងចំណោមសមាជិកក្រុមរបស់ពួកគេនៅពេលដែលពួកគេធ្វើសកម្មភាពនោះ ។

នៅពេលដែលក្រដាសស្អិតទាំងអស់ ត្រូវបានតម្រៀបទៅតាមប្រភេទរបស់វានៅលើតារាងហើយនោះ សូមធ្វើជាបញ្ជីមួយ ដោយដាក់ចំណងជើងថា "បញ្ហាធ្ងន់ធ្ងរ និងទូទៅ" ដោយប្រើប្រាស់នូវក្រដាស ស្អិតនេះ ដោយដាក់វានៅលើប្រអប់ក្រហម ។ (នេះគឺជាបញ្ហាដែលតែងតែកើតឡើង ញឹកញាប់ និង ធ្ងន់ធ្ងរ ឬញឹកញាប់ និងធ្ងន់ធ្ងរជាទីបំផុតហើយ អាចកើតឡើងបាន ហើយនិងម្ដងម្កាល និងធ្ងន់ ធ្ងរជាទីបំផុតហើយអាចកើតឡើងបាន។) ប្រសិនបើវាជាបញ្ហាដែលវាធ្ងន់ធ្ងរ និងកើតឡើងជាទូទៅ នោះបញ្ហានោះហើយ ដែលវាសំខាន់ត្រូវផ្ដោតយកចិត្តទុកដាក់ ។

## ជ្រើសរើសចំណុចផ្ដោតយកចិត្តទុកដាក់ជាក់លាក់សម្រាប់តស៊ូមតិ

សុំឲ្យអ្នកចូលរួម បង្កើតជាក្រុមធំមួយ ។

សូមអានបញ្ជីដែលដាក់ចំណងជើងថា "បញ្ហាធ្ងន់ធ្ងរ និងទូទៅ" ដល់ក្រុមទាំងមូល ។

សុំឲ្យសមាជិកក្រុម សម្រេចថាតើបញ្ហាជាក់លាក់ណាមួយ ដែលមាននៅក្នុងបញ្ជី ដែលពួកគេ ចង់ ផ្ដោតយកចិត្តទុកដាក់សម្រាប់យុទ្ធនាការតស៊ូមតិរបស់ពួកគេ ។ សូមពន្យល់ថានៅក្នុងម៉ូឌីលក្រោយៗ ទៀតនោះ អ្នកចូលរួមទាំងអស់ ត្រូវចូលរួមគ្នាបង្កើតជាយុទ្ធនាការតស៊ូមតិមួយ ដើម្បីដោះស្រាយ បញ្ហាមួយ ដែរ ។

សុំឲ្យអ្នកចូលរួមពិភាក្សាជាក្រុមនូវបញ្ហាដែលរៀបរាប់នៅក្នុងបញ្ជីនោះ ។ សូមលើកទឹកចិត្តឲ្យអ្នកចូលរួមទាំងអស់ បញ្ចេញនូវការយល់ឃើញរបស់ពួកគេ ។ សុំឲ្យអ្នកចូលរួមពិចារណាថាតើបញ្ហា ណាមួយក្នុងចំណោមបញ្ហាទាំងអស់នោះ វាបង្ករឲ្យមានរឿងរ៉ាវរហូតដល់ដោះស្រាយមិនបាន។ ឧទាហរណ៍ ពួកគេអាចកំណត់ថា "ការជួញដូរកុមារនៅក្នុងផ្ទះបន" គឺជាបញ្ហា ។ ដូច្នេះប្រធានបទ នេះ អាចបង្ករឲ្យមានរឿងរ៉ាវ ហើយការដោះស្រាយបញ្ហានេះ វាអាចធ្វើឲ្យអ្នកចូលរួមប្រឈមនឹង គ្រោះថ្នាក់ ។ នៅក្នុងករណីនេះ សមាជិកក្រុម ត្រូវផ្ដោតយកចិត្តទុកដាក់ទៅលើបញ្ហាផ្សេងទៀត ។

សូមពន្យល់ថាសមាជិកក្រុមនឹងចេះសម្រេចចិត្ត នៅក្នុងមេរៀនលើកក្រោយ ក្នុងការធ្វើសកម្មភាព អ្វីខ្លះនៅក្នុងយុទ្ធនាការតស៊ូមតិរបស់ពួកគេ ហើយនៅពេលនោះ ពួកគេត្រូវធានាថារាល់សកម្មភាព ទាំងអស់របស់ពួកគេត្រូវតែអាចធ្វើបាន និងមានសុវត្ថិភាព ។ យ៉ាងនេះក្ដី នៅក្នុងពេលបច្ចុប្បន្ន នេះ ការពិភាក្សា គួរផ្ដោតទៅលើបញ្ហាមិនមែន

ផ្តោតទៅលើដំណោះស្រាយឡើយ ឬសកម្មភាព សម្រាប់ពេលអនាគតទេ ។ ជាចុងក្រោយ ទាញសមាជិកក្រុមទាំងអស់ឲ្យឈានដល់ការព្រមព្រៀង រួមទាំងអស់គ្នា ដើម្បីឲ្យពួកគេគ្រប់គ្នា មានការប្តូរផ្តាច់ក្នុងការដោះស្រាយបញ្ហា ។ ប្រសិន បើមិនអាចសម្រេចបាននូវការព្រមព្រៀងរួមទេ នោះត្រូវចែកឲ្យក្រដាសមួយចំរៀកទៅអ្នកចូលរួម រួចហើយឲ្យពួកគេ ធ្វើការបោះឆ្នោត ។

នៅពេលដែលគោលបំណងជាក់លាក់នៃយុទ្ធនាការតស៊ូមតិរបស់អ្នក ត្រូវបានសម្រេចជ្រើសរើស ហើយនោះនោះ ត្រូវប្រកាសឲ្យសមាជិករបស់ក្រុមទាំងអស់បានដឹងអំពីការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុម ។

## សង្ខេបមេរៀន

- ការតស៊ូមតិ កាន់តែមានប្រសិទ្ធិភាពខ្ពស់ នៅពេលដែលការតស៊ូមតិនេះ វាដោះស្រាយនូវបញ្ហាពិតនៅក្នុងសហគមរបស់ពួកគេ ។
- គោលបំណងជាក់លាក់នៃយុទ្ធនការតស៊ូមតិរបស់ក្រុម គឺ ____________________( សូមបញ្ចូលចំណងជើងបញ្ហា ដែលក្រុមបានសម្រេចចិត្តធ្វើការសោះស្រាយ ) ពីព្រោះនេះ ជាបញ្ហាដ៏ធ្ងន់ធ្ងរបំផុតដែលវាតែងតែកើតឡើងនៅក្នុងសហគមរបស់ពួកយើង ។

# IS ២.២ក ៖ សំណួរសកម្មភាពតាមផែនការ

## សំណួរសម្រាប់យុវជនវ័យនៅក្នុងប្រទេសដែលជាទូទៅ តែងតែបញ្ជូនអ្នកធ្វើចំណាកស្រុក

- តើបញ្ហាអ្វីខ្លះដែលបណ្តាលឲ្យមនុស្សវ័យក្មេងចាកចេញពីសហាគមន៍របស់ពួកគេធ្វើ ដំណើររកការងារធ្វើ ?
- តើមានគ្រោះថ្នាក់អ្វីខ្លះ កើតឡើងនៅពេលដែលមនុស្សវ័យក្មេងធ្វើដំណើររកការ ងារធ្វើ ?
- តើមានគ្រោះថ្នាក់អ្វីកើតឡើង នៅពេលដែលមនុស្សវ័យក្មេងធ្វើការនៅក្នុងប្រទេសមួយទៀត?
- តើមនុស្សវ័យក្មេងនៅក្នុងសហាគមន៍របស់អ្នក ធ្វើការងារប្រកបដោយគ្រោះថ្នាក់អ្វីខ្លះ?

## សំណួរសម្រាប់យុវជនវ័យនៅក្នុងប្រទេសដែលជាទូទៅ តែងតែទទួលនូវអ្នកធ្វើចំណាកស្រុក

- តើអ្នកធ្វើចំណាកស្រុក តែងតែងប្រឈមមុខជាមួយនឹងគ្រោះថ្នាក់អ្វីខ្លះ នៅពេល ធ្វើដំណើរមកក្នុងប្រទេសនេះ?
- តើអ្នកធ្វើចំណាកស្រុក តែងតែងប្រឈមមុខជាមួយនឹងគ្រោះថ្នាក់អ្វីខ្លះ នៅពេល ធ្វើការនៅក្នុងប្រទេសនេះ?
- តើមនុស្សវ័យក្មេងនៅក្នុងប្រទេសនេះ ធ្វើការងារប្រកបដោយគ្រោះថ្នាក់អ្វីខ្លះ?

# IS ២.២ខ៖ រៀបបញ្ហាតាមលំដាប់

| | ធ្ងន់ធ្ងរ | ធ្ងន់ធ្ងរណាស់ | ធ្ងន់ធ្ងរជាទីបំផុត ហើយអាចកើតឡើងបាន |
|---|---|---|---|
| ញឹកញាប់ | | | |
|ម្តងម្កាល | | | |
| កម្រ | | | |



# មេរៀន ២.៣ ៖ ធ្វើការស្រាវជ្រាវអំពីបញ្ហា

## វត្ថុបំណង ៖

ដើម្បីជួយឲ្យអ្នកចូលរួម បានសិក្សាស្វែងយល់អំពីបញ្ហា តាមរយៈការចុះធ្វើសម្ភាសន៍ និងការស្រាវជ្រាវតាមអ៊ិនធឺណេត ។

## រយៈពេល ៖

៩០ នាទី

## សម្ភារៈ ៖

- ប័ណ្ណព័ត៌មាន "IS២.៣ក ៖ ការចុះធ្វើសម្ភាសន៍ល្អ ឯកសារថតចម្លងឲ្យបានគ្រប់គ្រាន់ សម្រាប់អ្នកចូលរួមទាំងអស់"
- ប័ណ្ណព័ត៌មាន"IS២.៣ខ ៖ ទម្រង់លិខិតយល់ព្រមសម្រាប់អ្នកផ្តល់បទសម្ភាសន៍"
- ប័ណ្ណព័ត៌មាន"IS ២.៣គ ៖ វែបសាយ"
- ក្រដាសស្អិតជាច្រើនដុំ
- សៀវភៅកត់ត្រា (ឲ្យបានគ្រប់គ្នា ដើម្បីឲ្យពេលដែលអ្នកចូលរួមបង្កើតគ្នាជាក្រុម ដែលមានសមាជិកចាប់ពី ៣-៥ នាក់ ក្រុមនីមួយៗ មានសៀវភៅកត់ត្រា នោះគ្រប់ក្រុម)

មេរៀននេះ គួរសិក្សានៅក្នុងហាងកាហ្វេ ឬការិយាល័យដែលមានកុំព្យូទ័រពីប្រាំមួយគ្រឿងដល់ប្រាំបីគ្រឿង មានភ្ជាប់អ៊ិនធឺណេត។ ប្រសិនបើមិនអាចធ្វើដូច្នេះបានទេ នោះអ្នកចូលរួមអាចប្តូរវេនគ្នា ប្រើប្រាស់កុំព្យូទ័ររួមបាន។ អ្នកសម្របសម្រួល គួរស្នើសុំម្ចាស់ហាងអ៊ិនធឺណេតកាហ្វេឲ្យបញ្ចូលកម្មវិធី ទប់ស្កាត់វែបសាយអាសអាភាសនៅលើកុំព្យូទ័រ។ ប្រសិនបើក្រុមទាំងអស់ មិនមានអ៊ិនធឺណិតប្រើទេ នោះមុននឹងចាប់ផ្តើមមេរៀន អ្នកសម្របសម្រួលគួរចូលមើលវែបសាយដែលមាននៅលើប័ណ្ណព័ត៌មាន "IS២.៣គ ៖ វែប សាយ" ដែលផ្តល់នូវព័ត៌មានអំពីការធ្វើចំណាកស្រុក និងការជួញដូរ។ សូមព្រីនចេញប័ណ្ណព័ត៌មាននោះជាច្រើនទំព័រពីវែបសាយនីមួយៗ រួចហើយសុំឲ្យក្រុមអានអត្ថបទទាំងនោះ ដើម្បីស្វែងរកព័ត៌មានដែលពាក់ព័ន្ធ ។

## ការរៀបចំ ៖

មុននឹងទៅចូលអនុវត្តជាក់ស្តែងនៅលើអ៊ិនធឺណេត នោះត្រូវឲ្យអ្នកចូលរួមទាំងអស់ បានរៀន អំពីមេរៀនស្តីពី សុវត្ថិភាពនៅលើអ៊ិនធឺណេត នៅក្នុងកញ្ចប់ឧបករណ៍ អ្នក តម្រង់ទិសវ័យឆ្លាត ។ (អ្នកចូលរួម ដែលបានចូលរួមរៀននៅក្នុងការបណ្តុះបណ្តាល កញ្ចប់ឧបករណ៍នារីកវៃឆ្លាត គឺបានសិក្សាមេរៀននេះរួចហើយ។)

ប្រសិនបើអ្នកចូលរួម មិនបានរៀនបញ្ចប់មេរៀនស្តីពីសុវត្ថិភាពនៅលើអ៊ិនធឺណេត នេះទេ នោះអ្នកសម្របសម្រួលត្រូវ ព្រីនចេញនូវឯកសារ ដែលបានដកស្រង់ចេញពី ប័ណ្ណព័ត៌មាន "IS២.៣គ៖ វែបសាយ" ជំនួសឲ្យការអនុវត្តជាក់ស្តែងនៅលើអ៊ិនធឺណេត ។

មុននឹងចាប់ផ្តើមរៀនមេរៀននេះ នោះអ្នកសម្របសម្រួលគួរចូលមើលវែបសាយនៅ លើប័ណ្ណព័ត៌មាន "IS២.៣គ ៖ វែបសាយ" ដើម្បីមើលថាតើវែបសាយទាំងនោះ មាន ជាភាសាក្នុងស្រុកដែរ ឬទេ ។ អ្នកចូលរួម គួររំលងផ្នែកនៃមេរៀននេះផ្នែកដែលពាក់ ព័ន្ធជាមួយនឹងអ៊ិនធឺណេត ប្រសិនបើអ្នកចូលរួមជាច្រើន មិនអាចអានភាសាអង់គ្លេស បានទេ ។

## ស្វាគមន៍

ប្រសិនបើមេរៀននេះ គឺមេរៀនមួយផ្នែកដែលបានយកមកបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលា នោះអ្នកចូលរួមបានស្វាគមន៍គ្នារួចហើយ ។ ប៉ុន្តែប្រសិនបើមេរៀននេះ ត្រូវយកមកបង្រៀននៅក្នុង ក្លឹបយុវជនតាមភូមិ នោះសូមស្វាគមន៍យុវជន ។ សូមលែង "ល្បែងបង្កភាពកក់ក្តៅ" ដោយអាចដក ស្រង់ចេញពីបញ្ជីនៅក្នុងឯកសារគាំទ្របាន ។

## សិក្សាបន្ថែមទៀត

សូមពន្យល់ថាមេរៀនេះ ផ្តោតជាសំខាន់ទៅលើគោលបំណងជាក់លាក់នៃយុទ្ធនាការតស៊ូមតិ ។ សូមសួរថាតើមាននរណាម្នាក់អាចចងចាំបានថាអ្វីទៅជាបញ្ហាដែរ ឬទេ ? សូមសរសេររៀបរាប់នូវ បញ្ហានៅលើក្រដាសផ្លិបឆាត ។

សួរថាតើមាននរណាម្នាក់អាចចាំបានអំពីជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិដែរ ឬទេ? ប្រសិនបើមិនមានអ្នកចាំទេ នោះសូមរកអ្នកស្ម័គ្រចិត្តម្នាក់ឲ្យអានឮៗនូវជំហានទាំងនោះ ដែលដកស្រង់ចេញពីប័ណ្ណព័ត៌មាន IS២.១ខ ពីមេរៀនទីមួយ ។

សូមពន្យល់ថាមេរៀនថ្ងៃនេះ គឺរៀនអំពី "ជំហានទី ២. ការចុះស្រាវជ្រាវអំពីបញ្ហា ៖ តើយើងបានដឹងអ្វីខ្លះពីបញ្ហានេះ ?" អ្នកចូលរួម ជាក្រុម នឹងគិតអំពីព័ត៌មាន ដែលមានសារប្រយោជន៍សម្រាប់យុទ្ធ នាការរបស់ពួកគេ ។

## ក្រុមទាំងអស់រៀនអំពីការសរសេរសំណួរ

សុំឲ្យអ្នកចូលរួមបង្កើតគ្នាជាក្រុមដែលមានសមាជិកចាប់ពី ៣-៥ នាក់។ចែកក្រដាសផ្លិបឆាតឲ្យក្រុមនីមួយៗ។

សុំឲ្យក្រុមនីមួយៗគូរបន្ទាត់នៅលើក្រដាសផ្លិបឆាតនោះ ជាបួនចំណែក ឬប្រអប់។ បន្ទាប់មកសុំ ឲ្យអ្នកស្ម័គ្រចិត្តនៅក្នុងក្រុមនីមួយៗ សរសេរសំណួរខាងក្រោមនៅក្នុងប្រអប់ខាងក្នុង (មួយសំណួរ សម្រាប់មួយប្រអប់ ៖

**តើមានមនុស្សប៉ុន្មាននាក់រងផលប៉ះពាល់ពីបញ្ហានេះ** ?
**តើមានអ្វីកំពុងកើតឡើងក្នុងពេលបច្ចុប្បន្ននេះពាក់ព័ន្ធជាមួយនឹងបញ្ហា** ?
**តើបញ្ហាផ្តល់នូវលទ្ធផលយ៉ាងដូចម្តេចខ្លះមកលើជនរងគ្រោះ និងគ្រួសាររបស់ពួកគេ** ?
**តើមានច្បាប់អ្វីខ្លះពាក់ព័ន្ធជាមួយនឹងបញ្ហានេះ** ?

សូមពន្យល់ប្រាប់អ្នកចូលរួមថាពួកគេត្រូវគិតនូវសំណួរទាំងនោះថាតើការតស៊ូមតិមានគោលបំណង ជាក់លាក់ចង់ធ្វើអ្វី ដែលវាឆ្លើយតបទៅនឹងប្រភេទនៃសំណួរនីមួយៗ ។ សូមផ្តល់ជូននូវឧទាហរណ៍ ខាងក្រោម ដើម្បីបំភ្លឺឲ្យងាយស្រួលយល់ ៖ ប្រសិនបើគោលបំណងជាក់លាក់របស់ការតស៊ូមតិ គឺផ្តោតទៅលើ "ពលកម្មកុមារ" នោះសំណួរខាងក្រោមទាំងនេះ អាចយកប្រើប្រាស់បាន ៖

**តើមានកុមារចំនួនប៉ុន្មាននាក់ដែលទទួលរងនូវការប៉ះពាល់ពីបញ្ហានេះ** ?
- តើមានកុមារប៉ុន្មាននាក់នៅក្នុងប្រទេសរបស់ខ្ញុំ មិនបានទៅសាលារៀន ?
- តើមានកុមារប៉ុន្មាននាក់ធ្វើការងារដែលមានគ្រោះថ្នាក់ ?

**តើមានអ្វីកំពុងកើតឡើង ដែលពាក់ព័ន្ធជាមួយនឹងបញ្ហានេះ** ?
- តើការងារប្រភេទអ្វីខ្លះ ដែលកុមារធ្វើនៅក្នុងសហាគមន៍របស់ខ្ញុំ ?
- តើទម្រង់គ្រោះថ្នាក់បំផុតនៃពលកម្មកុមារនៅក្នុងប្រទេសខ្ញុំ មានអ្វីខ្លះ ?

**តើផលប៉ះពាល់នៃបញ្ហាមានអ្វីខ្លះចំពោះជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ** ?
- តើអ្នកដែលជាជនរងគ្រោះជាកុមារ ទទួលរងនូវការឈឺចាប់ដូចម្តេចខ្លះ ?
- តើគ្រួសាររបស់ពួកគេទទួលរងនូវការឈឺចាប់ដូចម្តេចខ្លះ ?

**តើមានច្បាប់អ្វីខ្លះពាក់ព័ន្ធជាមួយនឹងបញ្ហានេះ** ?

- តើត្រូវមានអាយុប៉ុន្មានដើម្បីអាចធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសរបស់ខ្ញុំបាន ?
- តើនិយោជិតទាំងអស់ គោរពច្បាប់ដែរ ឬទេ ?

នៅពេលដែលពួកគេគ្រប់គ្នាយល់ហើយ នោះសូមចែកឲ្យក្រុមនិមួយៗនូវក្រដាសស្អិតមួយក្រុម មួយដុំ ។ រួចហើយទុកពេលវេលាប្រហែលជាដប់ប្រាំនាទីសរសេរ សំណួរផ្ទាល់ខ្លួនរបស់ពួកគេ ដោយប្រើប្រាស់ការបែងចែកប្រភេទសំណួរទាំងនេះ នៅក្នុងក្រដាសផ្លិបឆាតរបស់ពួកគេ។ សូមពន្យល់ ថាសំណួរនីមួយៗ គួរសរសេរនៅលើក្រដាសស្អិត ។ ហើយត្រូវសរសេរមួយសំណួរ នៅលើ ក្រដាសស្អិតចំនួនមួយសន្លឹកដែរ បើមិនធ្វើដូច្នេះទេ នោះសកម្មភាពនេះ នឹងមិនដំណើរការទេ ។ សូមលើកទឹកចិត្តពួកគេគិតដល់សំណួរណាដែលនឹងជួយជូនដំណឹងអំពីយុទ្ធនាការតស៊ូមតិ ។

នៅពេលដែលពួកគេបានបញ្ចប់សកម្មភាពនេះរួចហើយ នោះសូមយកក្រដាសផ្លិបឆាតបួនផ្ទាំង ធំៗចេញមក ។ សូមដាក់សម្គាល់ក្រដាសផ្លិបឆាតបួនផ្ទាំងនោះ នូវចំណងជើងសំណួរដូចខាង ក្រោម ៖

**តើមានកុមារចំនួនប៉ុន្មាននាក់ដែលទទួលរងនូវការប៉ះពាល់ពីបញ្ហានេះ** ?
**តើមានអ្វីកំពុងកើតឡើង ដែលពាក់ព័ន្ធជាមួយនឹងបញ្ហានេះ** ?
**តើផលប៉ះពាល់នៃបញ្ហាមានអ្វីខ្លះចំពោះជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ** ?
**តើមានច្បាប់អ្វីខ្លះពាក់ព័ន្ធជាមួយនឹងបញ្ហានេះ** ?

បន្ទាប់មកឲ្យក្រុមទាំងអស់យកក្រដាសស្អិតដែលគេបានសរសេរសំណួរនោះ ទៅបិតនៅលើប្រអប់ ដែលសមស្របជាមួយនឹងសំណួរនោះ ។ ប្រសិនបើមានក្រដាសស្អិតចំនួនពីរ ដែលមានសួរសំណួរ ដូចគ្នា ឬស្រដៀងគ្នានោះ សូមបញ្ចូលសំណួរទាំងពីរនោះជាសំណួរតែមួយ ។

នៅពេលដែលពួកគេយកក្រដាសស្អិតទៅបិតអស់ហើយ នោះសូមឲ្យក្រុមទាំងមូលជ្រើសរើស សំណួរចំនួនចាប់ពីបី ទៅប្រាំសំណួរ សំខាន់ៗ ចេញពីប្រអប់នីមួយៗ ។ សូមឲ្យអ្នកស្ម័គ្រចិត្តម្នាក់ សរសេរសំណួរទាំងនោះឲ្យបានស្អាត នៅលើក្រដាសផ្លិបឆាត ដែលដាក់ចំណងជើងថា "សំណួរ ស្តីពីបញ្ហារបស់ពួកយើង" ។ គួរមានសំណួរចាប់ពី ១២ ដល់ ២០ សំណួរសរុបទាំងអស់ ។

## តើយើងអាចរកចម្លើយទៅនឹងសំណួរដោយរបៀបណា ? តើនរណាអាចដឹងចម្លើយ ទៅនឹង សំណួរទាំងនេះ ?

សូមពន្យល់ថាមានពីរវិធីដើម្បីឆ្លើយសំណួរនេះ ។ វិធីទីមួយ គឺការស្វែងរកចម្លើយបន្ថែមនៅលើ អ៊ិនធឺណិត (ប្រសិនបើក្រុម មិនមានអ៊ិនធឺណិតប្រើប្រាស់ទេ នោះក្រុមត្រូវប្រើប្រាស់ការសង្ខេបព័ត៌មាន ដែលបានដកស្រង់ចេញពីអ៊ិនធឺណិត ។ វិធីទីពីរ គឺការពិភាក្សាជាមួយនឹងមនុស្សចេះដឹងនៅក្នុងសហាគមរបស់ពួកគេ ។

### ស្វែងរកចម្លើយនៅលើអ៊ិនធឺណិត

ឲ្យពួកគេបង្កើតជាក្រុមម្តងទៀត ដែលមួយក្រុម មានសមាជិកចាប់ពី ៣-៥ នាក់ ។ រួចហើយចែកឲ្យប័ណ្ណព័ត៌មានចម្លង "IS២.៣គ ៖ វែបសាយ" ដល់ក្រុមនីមួយៗ ។ ឲ្យក្រុមមើលវែបសាយនៅលើ ប័ណ្ណព័ត៌មាន ។ សូមពន្យល់ថាវែបសាយទាំងនេះ ត្រូវបានបង្ហោះឡើងដោយអង្គការដែលល្បីឈ្មោះ ដែលបានត្រួតពិនិត្យនូវរឿងពិតរួចហើយ ដូច្នេះ រាល់ព័ត៌មានរបស់ពួកគេ គឺអាចទុកចិត្តបាន ។

សូមពន្យល់ថា អ៊ិនធឺណិត គឺជាធនធានដ៏ល្អសម្រាប់ស្វែងរកចម្លើយទៅនឹងសំណួរ ប៉ុន្តែក៏ត្រូវចង្អុលបង្ហាញផងដែរថា មិនមែនវែបសាយទាំងអស់ សុទ្ធតែប្រាប់នូវការពិតនោះទេ ។

ចែកសៀវភៅសរសេរមួយក្បាលឲ្យក្រុមនីមួយៗ ។ សួររកអ្នកស្ម័គ្រចិត្តម្នាក់ពីក្រុមនីមួយៗ ឲ្យចម្លងសំណួរនៅក្នុងបញ្ជីលើក្រដាសផ្លិបឆាត "សំណួរស្តីពីបញ្ហារបស់ពួកយើង" ចូលទៅក្នុងសៀវភៅសរសេរ ។ ដាក់ការងារឲ្យក្រុមនីមួយៗធ្វើ ដោយចែកឲ្យវែបសាយផ្សេងៗគ្នាដែលមាននៅក្នុងប័ណ្ណព័ត៌មាន ។ សូមពន្យល់ថាក្រុមនីមួយៗ

ត្រូវចំណាយពេលប្រហែលជា ម្ភៃនាទីចូលមើលវែបសាយ ដែលបានដាក់ឲ្យ ដើម្បីស្វែងរកចម្លើយទៅនឹងសំណួរ នៅក្នុងសៀវភៅសរសេរឃើញដែរ ឬក៏អត់ ។ (ប្រសិនបើអ្នកចូលរួម ប្រើប្រាស់ឯកសារដែលព្រីនចេញពីអ៊ិនធឺណិត នោះ សូមចែកឲ្យក្រុមនី មួយៗនូវឯកសារដែលព្រីនចេញនោះ ។) សូមឲ្យក្រុមសរសេរនូវចម្លើយរបស់ពួកគេនៅក្នុង សៀវភៅសរសេរ រួចហើយសរសេរឈ្មោះរបស់វែបសាយនៅក្បែរចម្លើយនោះផង ។

នៅពេលដែលពួកគេបញ្ចប់រួចរាល់ នោះសូមឲ្យពួកគេបង្កើតជាក្រុមធំវិញ ។ អានសំណួរដែលមាន នៅក្នុង បញ្ជី នៅលើក្រដាសផ្លិបឆាត រួចហើយសុំឲ្យអ្នកចូលរួមចែករំលែកនូវចម្លើយរបស់ពួកគេ ។ សូមលើកទឹកចិត្ត ក្រុមនីមួយៗ ឲ្យបន្ថែមព័ត៌មានដែលក្រុមផ្សេងទៀត បានរកឃើញចម្លើយរបស់ ពួកគេនៅក្នុងសៀវភៅសរសេរ ។

### ការសិក្សាបន្ថែមទៀតពីសហគម

បន្ទាប់មកទៀតសូមឲ្យក្រុមដដែល ដែលមានសមាជិកចាប់ពី ៣-៥ នាក់ អានសំណួរដែលមាននៅ ក្នុងបញ្ជី ម្តងទៀត រួចហើយឲ្យពួកគេរិះគិតអំពីមនុស្សនៅក្នុងសហគម ដែលអាចដឹងចម្លើយមួយ ចំនួន ។ សូមលើកទឹកចិត្តពួក គេឲ្យគិតអំពីមនុស្សដែលចេះដឹងតាមរយៈបទពិសោធន៍របស់ពួកគេ ក៏ដូចជាអ្នកដែលចេះដឹងតាមរយៈការសិក្សា របស់ពួកគេ ។ អាស្រ័យតាមប្រធានបទដែលត្រូវបាន ជ្រើសរើសដើម្បីផ្តោតទៅលើនោះ និងបញ្ជីសំណួរ ដូចនេះបញ្ជី ឈ្មោះមនុស្សដែលចេះដឹងគួរដាក់ បញ្ចូលនូវមនុស្សខាងក្រោមនេះ ៖

- គ្រូបង្រៀន
- នាយកសាលា
- វេជ្ជបណ្ឌិត
- មនុស្សវ័យចំណាស់ដែលទើបត្រឡប់មកកាន់សហគមវិញបន្ទាប់ពីគាត់បានធ្វើ ចំណាកស្រុក
- មេភូមិ
- បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល
- យុវជនដែលបានបោះបង់ចោលការសិក្សា
- មេដឹកនាំសាសនា (គ្រូគង្វាល ឬអាចារ្យ)

សូមពន្យល់ថា មិនចាំបាច់ឆ្លើយសំណួរទាំងអស់ទេ ។ ឧទាហរណ៍ ប្រសិនបើក្រុម ជ្រើសរើសបញ្ហា ដែលពាក់ព័ន្ធ ជាមួយនឹងការធ្វើចំណាកស្រុក នោះវាប្រហែលជាមិនអាចទៅរួចទេក្នុងស្វែងរកថាតើ មានមនុស្សចំនួនប៉ុន្មាននាក់ បានធ្វើចំណាកស្រុកពីសហគមរបស់អ្នកទៅធ្វើការជារៀងរាល់ឆ្នាំ នោះ ព្រោះថារដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋា ភិបាល មិនបានកត់ត្រាករណីនេះទេ ។ ហើយវាក៏ មានការពិបាកផងដែរ ក្នុងការរាប់ចំនួនមនុស្សដែលធ្វើចំណាក ស្រុក ដោយហេតុថាមានមនុស្ស តិចតួចណាស់ដែលធ្វើចំណាកស្រុកតាមផ្លូវស្របច្បាប់ ។ យ៉ាងនេះក្តី វាជាការសំខាន់ ណាស់ដែល ពួកគេត្រូវស្វែងរកចម្លើយឲ្យបានកាន់តែច្រើន ។

### ការគិតពិចារណាទៅលើផលប៉ះពាល់នៃការសម្ភាសន៍មនុស្ស

កង្វល់ចម្បងដែលបានលើកឡើងនៅក្នុងកញ្ចប់ឧបករណ៍នេះ គឺត្រូវធានាថាអ្នកចូលរួម និងមនុស្ស ដែល ពាក់ព័ន្ធនឹងសៀវភៅណែនាំនេះ ត្រូវបានការពារមិនឲ្យមានគ្រោះថ្នាក់ ។ ក្នុងនាមជាអ្នកសម្រប សម្រួល អ្នកត្រូវពិចារណា នូវគ្រោះថ្នាក់ណាមួយដែលអាចនឹងកើតមានឡើង ដោយសារការសម្ភាសន៍នេះ ។ សូមអានបញ្ជីឈ្មោះអ្នកដែលអាច ផ្តល់បទសម្ភាសន៍បាន ហើយធ្វើការពិចារណាថាតើ ការសម្ភាសន៍នេះអាចធ្វើឲ្យអ្នកសម្ភាសន៍/អ្នកផ្តល់បទសម្ភាសន៍ មានអារម្មណ៍មិនសប្បាយចិត្តដែរ ឬទេ ។ ឧទាហរណ៍ ប្រសិនបើអ្នកចូលរួមបានសម្ភាសន៍មនុស្សម្នាក់ ដែល ទទួលរងនូវការជួញដូរ រហូតធ្លាក់ទៅក្នុងស្ថានភាពត្រូវបានគេរំលោភបំពាន នោះការសម្ភាសន៍នេះ អាចធ្វើឲ្យអ្នក សម្ភាសន៍ និងអ្នកផ្តល់បទសម្ភាសន៍មិនសប្បាយចិត្ត។ ផ្អែកតាមវិធានទូទៅ ក្រុមមិនគួរធ្វើការសម្ភាសន៍ ៖

- កុមារ
- មនុស្សដែលមានប្រវត្តិប៉ះទង្គិចផ្លូវចិត្ត ប្រសិនបើពួកគេមិនទាន់ជាសះស្បើយទ ហើយមិនមានបំណង ចូល ពាក់ព័ន្ធជាមួយនឹងសកម្មភាពតស៊ូមតិនោះទេ ។

អ្នកសម្របសម្រួល ត្រូវសម្រេចចិត្តជាចុងក្រោយរបស់ខ្លួន ទាក់ទងនឹងថាតើនរណាត្រូវ គេសម្ភាសអ្នកសម្របសម្រួល ត្រូវធានាថាការធ្វើបទសម្ភាសន៍ នឹងបង្ករជាគ្រោះថ្នាក់ដល់អ្នកសម្ភាសន៍ និងដល់អ្នកផ្តល់បទសម្ភាសន៍ឡើយ ។ អ្នកសម្របសម្រួល ត្រូវប្រើប្រាស់នូវការវិនិច្ឆ័យរបស់ខ្លួន ក្នុងការជ្រើសរើសអ្នកផ្តល់បទសម្ភាសន៍ ដែលទំនេរ ហើយនិងដែលរីករាយអាចផ្តល់ការសម្ភាសន៍ បាន ។

### អនុវត្តការធ្វើបទសម្ភាសន៍ដ៏ល្អ

ចូរអានប័ណ្ណព័ត៌មាន IS២.៣កៈការធ្វើបទសម្ភាសន៍ដ៏ល្អ" រួចហើយសួរថាតើមាននរណាម្នាក់មានសំណួរអ្វីទេ ។

### អនុវត្តធ្វើសម្ភាសន៍

សុំឲ្យក្រុមបំបែកគ្នាជាក្រុមតូចៗចំនួនពីរក្រុម ។ ផ្តល់ឲ្យក្រុមនីមួយៗនូវសៀវភៅសរសេរមួយក្រុម មួយក្បាល ដែលមានបញ្ជីសំណួរនៅក្នុងនោះ ។ ក្រុមនីមួយៗ គួរស្វែរកអ្នកស្ម័គ្រចិត្តបីនាក់ ដោយ ម្នាក់ធ្វើជាអ្នកផ្តល់ បទសម្ភាសន៍ម្នាក់ទៀត ធ្វើជាអ្នកសម្ភាសន៍ និងម្នាក់ទៀតជាអ្នកកត់ត្រា ។ ក្រុម នីមួយៗ គួរអានប័ណ្ណព័ត៌មាន "IS២.៣ក ៖ ការធ្វើបទសម្ភាសន៍ដ៏ល្អ" មុននឹងចាប់ផ្តើមសម្ភាសហើយ គួរព្យាយាមអនុវត្តតាមគោលការណ៍ណែនាំទាំងអស់នេះ នៅក្នុងពេលអនុវត្តសាកល្បងនេះ ។អ្នក កត់ត្រា គួរកត់ត្រានៅក្នុងសៀវភៅសរសេរនៅថ្ងៃនេះ ពីព្រោះថាកំណត់ត្រានេះ នឹងត្រូវយកមក ប្រើប្រាស់សម្រាប់ការសម្ភាសន៍ពិតៗ ។ អ្នកស្ម័គ្រចិត្តចំនួនបីនាក់ គួរអនុវត្តសម នៅក្នុងការសម្ភា សន៍នេះ ។ ហើយប្រសិនបើមានពេវេលាគ្រប់គ្រាន់ ពួកគេគួរធ្វើសកម្មភាពនេះជាមួយនឹងអ្នកស្ម័គ្រ ចិត្តថ្មីផ្សេងទៀត ។

### ចុះសម្ភាសន៍

នៅពេលដែលសមាជិកក្រុម ត្រឡប់ទៅកាន់ផ្ទះនៅតាមសហគមរបស់ពួកគេវិញ នោះពួកគេនឹង រៀនមេរៀននេះឡើងវិញជាមួយនឹងសមាជិកក្លឹបរបស់ពួកគេ ។ អ្នកសម្របសម្រួលក្លឹបតាមមូល ដ្ឋាន នៅពេលនោះ នឹងរៀបចំ និងដឹកនាំការសម្ភាសមួយ ឬច្រើន យោងតាមការណែនាំនៅក្នុង កញ្ចប់ឧបករណ៍នេះ ។

សូមពន្យល់ថាមុននឹងធ្វើការសម្ភាសន៍ អ្នកសម្របសម្រួលក្លឹបតាមមូលដ្ឋាន គួរ ៖

- ជួយអ្នកចូលរួមនៅក្នុងមេរៀន សំដែងមតិ ជ្រើសរសើមនុស្សពីរនាក់ ដើម្បីធ្វើការសម្ភាសន៍ អ្នកទីមួយ ជាអ្នកសួរសំណួរ រីឯអ្នកទីពីរ ជាអ្នកកត់ត្រា ។
- រកមើលទីកន្លែងដែលស្ងាត់ មានលក្ខណៈឯកជន សម្រាប់ធ្វើការសម្ភាសន៍
- បញ្ជាក់ប្រាប់អ្នកចុះសម្ភាសន៍ និងអ្នកផ្តល់បទសម្ភាសន៍នៅកម្មវិធីសម្តែងមតិ អំពីពេល វេលា និងទីកន្លែង ឲ្យបានរយៈពេល ២៤ ម៉ោង មុននឹងពេលត្រូវសម្ភាសន៍ ។
- អានឡើងវិញនូវប័ណ្ណព័ត៌មាន "IS២.៣ក ៖ ការសម្ភាសន៍ដ៏ល្អ" ជាមួយនឹងអ្នកចុះសម្ភាសន៍របស់ កម្មវិធីសម្តែងមតិមុននឹងចាប់ផ្តើមសម្ភាសន៍ ។
- យកប័ណ្ណព័ត៌មានថតចម្លង "IS២.៣ខ ៖ ទម្រង់លិខិតយល់ព្រមសម្រាប់អ្នកផ្តល់បទសម្ភាសន៍" ដើម្បីឲ្យអ្នក ផ្តល់បទសម្ភាសន៍ចុះហត្ថលេខា និងបញ្ជីសំណួរដែលមាននៅក្នុងសៀវភៅសរសេរ ព្រមទាំងប៊ិច ដើម្បីធ្វើការកត់ត្រា ។

នៅក្នុងពេលសម្ភាសន៍ នោះអ្នកសម្របសម្រួល និងអ្នកសម្ភាសន៍របស់កម្មវិធី សម្តែងមតិ គួរ ៖

- គោរពតាមគោលការណ៍ណែនាំ ដែលមាននៅក្នុងប័ណ្ណព័ត៌មាន "IS២.៣កៈ ការសម្ភាសន៍ដ៏ល្អ"
- ចងចាំថាត្រូវអរគុណអ្នកផ្តល់បទសម្ភាសន៍ នៅពេលបញ្ចប់ការងារសម្ភាសន៍ ។

## ការបញ្ចប់មេរៀន

ប្រសិនបើមេរៀននេះ ត្រូវបានយកមកបង្រៀននៅក្នុងសិក្ខាសាលាបណ្តុះបណ្តាល ក្នុងលក្ខណៈជាមេរៀនមួយផ្នែកនៃមេរៀនដទៃទៀតនោះ នោះបុគ្គលិករបស់អង្គការទស្សនពិភពលោក អាចរៀបចំ ឲ្យមានការចុះតាមមូលដ្ឋានផ្ទាល់តែម្តងសម្រាប់អ្នកចូលរួម ដើម្បីអនុវត្តការចុះសម្ភាសន៍ ។

ប្រសិនបើមេរៀន ត្រូវបានយកមកបង្រៀននៅក្លឹបសម្តែងមតិនៅតាមមូលដ្ឋាន នោះអ្នកសម្របសម្រួលត្រូវធានាថានឹងមានការចុះសម្ភាសន៍ មួយដង ឬច្រើនដង បានធ្វើរួចរាល់ មុននឹងបន្តទៅ មេរៀនមួយទៀត ។

នៅចុងបញ្ចប់នៃមេរៀននេះ នោះសូមអរគុណអ្នកចូលរួមសម្រាប់ការងាររបស់ពួកគេរួចហើយសូមពន្យល់ថាព័ត៌មានដែលពួកគេបានជួយប្រមូលនោះ នឹងជួយពួកគេឲ្យក្លាយជាអ្នកតស៊ូមតិដ៏សកម្ម ម្នាក់ ។

### សង្ខេបមេរៀន

- អ្នកតស៊ូមតិ ត្រូវទទួលបាននូវរាល់ព័ត៌មានពាក់ព័ន្ធនឹងប្រធានបទដែលពួកគេត្រូវធ្វើការតស៊ូមតិ ។
- អ្នកតស៊ូមតិ អាចប្រមូលផ្តុំនូវព័ត៌មានតាមរយៈអ៊ិនធឺណិត និងការចុះសម្ភាសន៍ ។
- អ្នកតស៊ូមតិ គួរប្រើប្រាស់តែវែបសាយណាដែលគួរឲ្យជឿទុកចិត្តបានប៉ុណ្ណោះ ហើយ គួរអនុវត្តតាមគោលការណ៍ណែនាំការសម្ភាសន៍ ។
- អ្នកចូលរួម គួររៀបចំការធ្វើសម្ភាសន៍ជាមុន ហើយត្រូវប្រាកដថាការសម្ភាសន៍ នឹងមិនប៉ះ ពាល់ ឬធ្វើឲ្យអ្នកចុះសម្ភាសន៍ និងអ្នកផ្តល់បទសម្ភាសន៍ខឹង ឬម៉ួម៉ៅឡើយ ។

# IS ២.៣ក ៖ ការធ្វើបទសម្ភាសន៍ដ៏ល្អ
## គោលការណ៍ណែនាំពាក់ព័ន្ធនឹងសីលធម៌សម្រាប់ការសម្ភាសន៍

**ការពារអ្នកផ្តល់បទសម្ភាសន៍មិនឲ្យទទួលរងគ្រោះថ្នាក់**

ហាមសម្ភាសមនុស្សដែលធ្លាប់មានជំងឺបាក់ស្បាតដោយសារការធ្វើចំណាកស្រុកដោយ គ្មានសុវត្ថិភាព និង ដោយសារការជួញដូរ ។

ហាមសម្ភាសកុមារ ។

**ការពារអ្នកស្រាវជ្រាវ**

ហាមសម្ភាសមនុស្សដែលខឹងភ្លាមៗទៅនឹងសំណួរដែលអ្នកសួរ ។

ហាមទុកកុមារនៅក្នុងបន្ទប់តែម្នាក់ឯងជាមួយនឹងមនុស្សពេញវ័យដែលនៅតែម្នាក់ឯងដែរ ។

**រាល់ការចូលរួមក្នុងការស្រាវជ្រាវទាំងអស់ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត**

អ្នកផ្តល់បទសម្ភាសន៍ទាំងអស់ ត្រូវទទួលបាននូវការជូនដំណឹងអំពីមូលហេតុ ដែលអ្នកធ្វើ ការសម្ភាសពួកគេ ប្រធានបទដែលអ្នកនឹងសួរពួកគេ ហើយថាអ្នកនឹងប្រើប្រាស់នូវចម្លើយ របស់ពួកគេសម្រាប់យុទ្ធនាការតស៊ូមតិរបស់អ្នក ។

**ត្រូវគោរពមនុស្សដែលអ្នកកំពុងធ្វើសម្ភាសន៍**

ត្រូវមានឥរិយាបថបង្ហាញនូវការគោរពចំពោះមនុស្សដែលអ្នកកំពុងសម្ភាសនិងគោរពចំពោះ វប្បធម៌របស់ពួកគេ ។

**ចៀសវាងការរំពឹងទុកដែលមិនប្រាកដនិយម**

មនុស្សដែលអ្នកសម្ភាស គួរបានដឹងខ្លួនថាពួកគេនឹងមិនទទួលបានលុយ ឬអត្ថប្រយោជន៍ ណាមួយក្នុង ការចូលរួមនៅក្នុងការសម្ភាសន៍នេះទេ ។

**ការរក្សាការសំងាត់**

ហាមកត់ឈ្មោះ នៅពេលកត់ត្រាបទសម្ភាសន៍ទាំងនេះ ។ ហាមប្រាប់ឈ្មោះមនុស្សដែល អ្នកបានសម្ភាសនៅក្នុងរយៈពេលនៃការធ្វើយុទ្ធនាការតស៊ូមតិនេះ ។

## បច្ចេកទេសសម្ភាសន៍ល្អ

**ត្រូវចេះគួរសម**

សូមអរគុណអ្នកចូលរួមផ្តល់បទសម្ភាសន៍ ចំពោះការចំណាយពេលវេលារបស់ពួកគេ ។

**ហាមសម្រេចសេចក្តី**

ហាមសង្កត់សម្លេងក្នុងលក្ខណៈដូចជាសម្រេចសេចក្តី ដើម្បីចៀសវាងកុំឲ្យប៉ះពាល់ដល់ ចម្លើយឆ្លើយតប ។

**ត្រូវធ្វើជាអ្នកស្តាប់ដោយយកចិត្តទុកដាក់ដ៏សកម្ម**

ត្រូវបង្ហាញនូវសមានចិត្តជាមួយនឹងអ្នកឆ្លើយតប និងបង្ហាញការចាប់អារម្មណ៍ ស្វែងយល់ អំពីគំនិតរបស់ពួកគាត់ ។

ទុកឱកាសឲ្យអ្នកឆ្លើយតប និយាយបានច្រើនបំផុត ។

**សួរសំណួរដេញ**

សួរដេញ ប្រសិនបើអ្នកផ្តល់បទសម្ភាសន៍ ទើបនឹងឆ្លើយនូវចម្លើយគួរឲ្យចាប់អារម្មណ៍ ឬ ចម្លើយអ្វីមួយ ដែលអ្នកមិនយល់ ឬចម្លើយដែលចង់ដឹងបន្ថែមទៀត ។ អ្នកសម្ភាសន៍ដ៏ពូកែ ម្នាក់ នឹងសួរនូវសំណួរដេញជាច្រើន សំណួរនៅក្នុងការធ្វើសម្ភាសន៍ ។

**ធ្វើការកត់ត្រា**

កត់ត្រាទុកគ្រប់អ្វីៗទាំងអស់ដែលអ្នកផ្តល់បទសម្ភាសន៍ បាននិយាយ ។ សូមផ្ទៀងផ្ទាត់ការ កត់ត្រារបស់អ្នកជាមួយសមាជិកក្រុមដើម្បីប្រាកដថា អ្នកបានកត់ត្រាតែអ្វីៗដែលអ្នកផ្តល់ បទសម្ភាសន៍បាននិយាយតែប៉ុណ្ណោះ ។

**មើលនាឡិកា**

ត្រូវប្រាកដថាអ្នកមានពេលវេលាគ្រប់គ្រាន់ដើម្បីសម្ភាសន៍ ប៉ុន្តែមិនត្រូវឲ្យបទសម្ភាសន៍ មានរយៈពេលលើសមួយម៉ោងនោះឡើយ ។

# ប័ណ្ណព័ត៌មាន ២.៣ខ៖
# ទម្រង់លិខិតយល់ព្រម សម្រាប់អ្នកផ្ដល់បទសម្ភាសន៍

សូមអរគុណចំពោះការមកចូលរួមនៅក្នុងការសម្ភាសន៍នៅថ្ងៃនេះ ។ ខ្ញុំឈ្មោះ ______________________ (សូមដាក់ឈ្មោះ) ។

សូមកត់សម្គាល់ថា ៖

- ការចូលរួមរបស់អ្នក ធ្វើឡើងដោយស្ម័គ្រចិត្ត ។ អ្នកមិនចាំបាច់ចូលរួមក៏បានដែរ ប្រសិនបើ អ្នកមិនចង់ចូលរួម ។
- អ្នកមិនចាំបាច់ឆ្លើយនូវសំណួរណាមួយក៏បាន ប្រសិនបើអ្នកមិនចង់ ។ វាមិនមានចម្លើយ ណាដែលត្រូវ ឬ ខុសទេ ។
- ម្នាក់ក្នុងចំណោមពួកយើង នឹងធ្វើការកត់ត្រា ដើម្បីធានាថាពួកយើងបានកត់ត្រាទាំងអស់ នូវការយល់ឃើញរបស់អ្នកយ៉ាងត្រឹមត្រូវ ។
- របាយការណ៍នេះ នឹងមិនដាក់បញ្ចូលឈ្មោះអ្នកណាម្នាក់ឡើយ ។
- យើងលើកទឹកចិត្តអ្នកចូលរួមពិភាក្សាអំពីបញ្ហាដោយសេរី ។
- ព័ត៌មានដែលអ្នកផ្ដល់ជូននេះ នឹងត្រូវយកមកប្រើប្រាស់ដើម្បីជួយក្រុមក្នុងការរៀបចំ យុទ្ធ នាការតស៊ូមតិ ។
- យើងនឹងចែករំលែកនូវចម្លើយរបស់អ្នកជាមួយនឹងសមាជិកដទៃទៀតក្នុងក្រុម ហើយពួកគេ នឹងជូនដំណឹង អំពីយុទ្ធនាការតស៊ូមតិជាសាធារណៈរបស់ពួកយើង ។
- ប្រធានបទដែលយើងនឹងលើកយកមកពិភាក្សានៅថ្ងៃនេះ គឺស្ដីអំពី (សូមដាក់ប្រធានបទ) ។
- ខ្ញុំបានអាន និងយល់នូវរាល់ព័ត៌មានខាងលើ ។

ឈ្មោះ ________________________________________ កាលបរិច្ឆេទ ______________________

ហត្ថលេខា ______________________________________________________________________

# IS ២.៣គ ៖ វែបសាយ

មុននឹងប្រើប្រាស់នូវប័ណ្ណព័ត៌មាននេះ នោះអ្នកសម្របសម្រួល គួរស្រាវជ្រាវនៅលើអ៊ិនធឺណេត ដើម្បីរកមើលនូវវែបសាយដែលសរសេរជាភាសាដើមរបស់ខ្លួន ដើម្បីដាក់បញ្ចូលបន្ថែមទៅ ក្នុងបញ្ជីខាងក្រោមនេះ ។

ប្រសិនបើអ្នកសម្របសម្រួល សម្រេចជ្រើសរើសប្រើប្រាស់ ហ្គូហ្គល (Google) ដើម្បីស្រាវជ្រាវព័ត៌មាននោះ អ្នកសម្របសម្រួលគួរធានាឲ្យបាននូវការកំណត់នៅលើកុំព្យូទ័រដើម្បីកុំឲ្យអ្នកចូល រួមអាចចូលទៅមើលវែបសាយអាសអាភាស ឬមានរូបភាពហឹង្សា នៅពេលដែលពួកគេធ្វើការស្រាវ ជ្រាវ ។

- អង្គការទស្សនៈពិភពលោក (World Vision) ដែលមានវែបសាយ: www.wvi.org
- អង្គការ ECPAT International ដែលមានវែបសាយ: www.ecpat.net
- អង្គការ Plan International ដែលមានវែបសាយ: www.plan-international.org
- មូលនិធិ MTV ដែលមានវែបសាយ: www.mtvexit.org
- អង្គការ Save the Children ដែលមានវែបសាយ : www.savethechildren.net
- អង្គការ Terres des Hommes ដែលមានវែបសាយ www.terresdeshommes.org
- អង្គការ UNICEF ដែលមានវែបសាយ: www.unicef.org
- គំនិតផ្តួចផ្តើមជាសាកលរបស់អង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដែលមានវែបសាយ: www.ungift.org



# មេរៀន២.៤ ៖
# កំណត់វត្ថុបំណងនៃយុទ្ធនាការ ទស្សនិកជនគោលដៅ និងសារយុទ្ធនាការ

## វត្ថុបំណង ៖

អ្នកចូលរួមនឹងមានសមត្ថភាពរៀបរាប់អត្ថន័យនៃវត្ថុបំណង សកម្មភាព ទស្សនិកជនគោលដៅ និងសារយុទ្ធនាការ ។

## រយៈពេល ៖

៩០ នាទី

## ស្វាគមន៍

ប្រសិនបើមេរៀននេះ គឺមេរៀនមួយផ្នែកដែលបានយកមកបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលា នោះអ្នកចូលរួមបានស្វាគមន៍គ្នារួចហើយ ។ ប៉ុន្តែប្រសិនបើមេរៀននេះ ត្រូវយកមកបង្រៀននៅក្នុងក្លឹបយុវវ័យតាមភូមិ នោះសូមស្វាគមន៍យុវវ័យ ។ សូមលេង "ល្បែងបង្កភាពកក់ក្តៅ" ដោយអាចដកស្រង់ចេញពីបញ្ជីនៅក្នុងឯកសារគាំទ្របាន ។

## សម្ភារ ៖

- ប័ណ្ណព័ត៌មាន "IS ២.១ខ ៖ ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ"
- ប័ណ្ណព័ត៌មាន "IS ២.៤ក ៖ ផែនការតស៊ូមតិ ៖ (ចម្លងវានៅលើក្រដាសធំ)
- ប័ណ្ណព័ត៌មាន "IS២.៤ខ ៖ កំណត់វត្ថុបំណង កំណត់ទស្សនិក-ជនគោលដៅ សារយុទ្ធនាការ និងសកម្មភាព" (អ្នកចូលរួមទទួលបានឯកសារនេះម្នាក់មួយច្បាប់)
- សៀវភៅកត់ត្រាកាលពីរៀនមេរៀនលើកមុន ដែលបានប្រើប្រាស់សម្រាប់កត់ត្រាសំណួរ និងចម្លើយនៅពេលរៀនមេរៀនការស្រាវជ្រាវតាមអ៊ិនធឺណេត និងការធ្វើ បទសម្ភាសន៍ ។

## ចុះធ្វើការស្រាវជ្រាវឡើងវិញ

សុំឲ្យអ្នកចូលរួម ប្រាប់អ្នកត្រឡប់មកវិញអំពីចំណុចផ្តោតយកចិត្តទុកដាក់ជាក់លាក់នៅក្នុងការធ្វើ យុទ្ធនាការតស៊ូមតិនេះ ។ បន្ទាប់មកទៀត សុំឲ្យអ្នកចូលរួមយកសៀវភៅកត់ត្រារបស់ពួកគេចេញមក ។ ឲ្យពួកគេចែករំលែកនូវព័ត៌មានសំខាន់ៗ ដែលពួកគេបានដឹងពីការចុះសម្ភាសន៍ និងពីអ៊ិនធឺណេត ទាក់ទងនឹងចំណុចផ្តោតយកចិត្តទុកដាក់នៃយុទ្ធនាការតស៊ូមតិ ។

## ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិនានាសម្រាប់រៀបចំយុទ្ធនាការតស៊ូមតិ ៖ ជំហាន ៣-៥

- សូមចង្អុលទៅកាន់ "ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ" (ប័ណ្ណព័ត៌មាន IS ២.១ខ) និងសូម ធ្វើការពន្យល់ថាមេរៀននេះ នឹងផ្តោតយកចិត្តទុកដាក់ទៅលើជំហានទី ៣, ៤ និង ៥ ។
- ជំហានទី ៣. កំណត់នូវវត្ថុបំណងរបស់យុទ្ធនាការតស៊ូមតិ ៖ តើយើងចង់ឲ្យមានការផ្លាស់ ប្តូរ ឬ ដំណោះស្រាយអ្វីខ្លះ ?
- ជំហាន ៤. កំណត់នូវទស្សនិកជនគោលដៅ ៖ តើយើងចង់ឲ្យនរណា ទទួលរងនូវឥទ្ធិពល នេះដើម្បីសម្រេចនូវវត្ថុបំណងរបស់ពួកយើង ?
- ជំហាន ៥. រៀបចំនូវសារយុទ្ធនាការតស៊ូមតិ ៖ តើសារអ្វីខ្លះដែលយើងចង់បង្ហាញទៅទស្សនិកជនគោលដៅរបស់ពួកយើង ?

## ជំហាន ៣ ៖ កំណត់នូវវត្ថុបំណងរបស់យុទ្ធនាការតស៊ូមតិ ៖ តើយើងចង់ឲ្យមានការផ្លាស់ ប្តូរ ឬ ដំណោះស្រាយអ្វីខ្លះ ?

សូមពន្យល់ថាចម្លើយចំពោះសំណួរនៅក្នុងជំហានទី ៣-"តើយើងចង់ឲ្យមានការផ្លាស់ ប្តូរ ឬ ដំ ណោះស្រាយអ្វីខ្លះ ?" -គឺជាវត្ថុបំណងហើយ ។ វិធីងាយស្រួលបំផុតដើម្បីកំណត់នូវវត្ថុបំណង នៃ យុទ្ធនាការតស៊ូមតិ គឺត្រូវសម្រេចធ្វើអ្វីដែលវាពិត ។ វត្ថុបំណងនេះ នឹងកំណត់បាននូវការផ្លាស់ប្តូរ ក្នុងទ្រង់ទ្រាយធំណាមួយ ឬស្វែងរកឃើញនូវដំណោះស្រាយណាមួយ ។ ប៉ុន្តែវាមិនអាចកំណត់ បាននូវសកម្មភាពលំអិត ដែលជាប់ពាក់ព័ន្ធនោះទេ ។ ប្រសិនបើបញ្ហាដែលជាចំណុចផ្តោតការ យកចិត្តទុកដាក់ នៃយុទ្ធនាការតស៊ូមតិរបស់អ្នក គឺ "ការធ្វើចំណាកស្រុកដោយគ្មានព័ត៌មានក្នុង ចំណោមសិស្សនៅក្នុងសាលារៀនរបស់ពួកយើង" នោះវត្ថុបំណងនៃយុទ្ធនាការតស៊ូមតិរបស់អ្នក គឺថា "សាលារៀនត្រូវអប់រំសិស្សសាលាអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព មុននឹងពួកគេធ្វើ ដំណើរ" ។

សុំឲ្យសមាជិកក្រុមនឹករកនូវវត្ថុបំណងនៃយុទ្ធនាការតស៊ូមតិឆ្លើយតបទៅនឹងបញ្ហាដែលកើតមាន ។

អនុញ្ញាតឲ្យក្រុមនឹករកនូវវត្ថុបំណងមួយចំនួនទៀត ហើយបន្ទាប់មកសូមលើកទឹកចិត្តឲ្យមានការ ពិភាក្សា ។ ជាចុងក្រោយ សូមជួយក្រុម ដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋាន ។

នៅពេលដែលក្រុម បានព្រមព្រៀងគ្នាទៅលើវត្ថុបំណងរួចហើយ នោះសូមសរសេរវត្ថុបំណងនោះ នៅលើប័ណ្ណព័ត៌មានចម្លង IS ២.៤ក ៖ ផែនការតស៊ូមតិ"។

## ជំហានទី ៤. កំណត់ទស្សនិកជនគោលដៅ ៖ តើយើងត្រូវធ្វើឲ្យនរណាទទួលរងនូវឥទ្ធិពលនេះ ដើម្បីអាចសម្រេចនូវវត្ថុបំណងរបស់យើងបាន ?

ឥឡូវនេះ សូមពន្យល់ថាទស្សនិកជនគោលដៅ គឺជាមនុស្សដែលអ្នកចង់ឲ្យពួកគេរងនូវឥទ្ធិពល ពីការធ្វើយុទ្ធនាការតស៊ូមតិរបស់អ្នក ។ អ្នកទាំងនោះ គឺជាមនុស្សដែលអាចធ្វើឲ្យមានការផ្លាស់ប្តូរ គោលនយោបាយ ឬការអនុវត្តគោលនយោបាយ ពាក់ព័ន្ធនឹងបញ្ហាដែលអ្នកកំពុងផ្តោតយកចិត្ត ទុកដាក់ ។

សុំឲ្យអ្នកចូលរួម គិតមើលថាតើអ្នកណាខ្លះ ដែលអាចធ្វើឲ្យមានការផ្លាស់ប្តូរ ទាក់ទងនឹងបញ្ហានេះ ។ អ្នកទាំងនោះ អាចជាមនុស្សដែលធ្វើការនៅក្នុងមូលដ្ឋាននោះតែម្តង ដូចជាបុគ្គលិកសាលារៀន ឬ អាជ្ញាធរក្នុងស្រុក ឬមនុស្សដែលអាចមានឥទ្ធិពលធ្វើឲ្យមានការផ្លាស់ប្តូរ នៅក្នុងកម្រិតថ្នាក់ជាតិ ។

សុំឲ្យអ្នកចូលរួមម្នាក់ៗ គិតរកនូវវិធីល្អបំផុត ដើម្បីចូលជួបជាមួយនឹងអ្នកទាំងនោះ ។ ឲ្យអ្នកចូលរួម ធ្វើការពិចារណាថាតើទស្សនិកជនគោលដៅ អាចចូលជួបបានដែរ ឬក៏អត់ តាមរយៈ ៖

- កម្មវិធីផ្លូវការ ដូចជាចូលរួមក្នុងកិច្ចប្រជុំរបស់អាជ្ញាធរមូលដ្ឋាន ។
- ការណែនាំជាផ្លូវការតាមរយៈនរណាម្នាក់ ដែលធ្វើការជាមួយនឹងអ្នកទាំងនោះ ។
- យុទ្ធនាការសរសេរជាលិខិត (ប្រសិនបើសាធារណជន អាចដឹងនូវអាសយដ្ឋានរបស់ ទស្សនិកគោលដៅ) ។
- បញ្ចេញមតិនៅក្នុងទំព័រ ផ្តល់មតិ ជាសាធារណ (ប្រសិនបើទស្សនិកជនគោលដៅ គឺជា ក្រុមហ៊ុន) ។
- រំខាន ឆាឆៅនូវដំណើរការអាជីវកម្មរបស់ពួកគេ ដោយការធ្វើការរំខានអាជីវកម្មរបស់ពួកគេ តាមរយៈការតវ៉ាជាក្រុម ។

សុំឲ្យអ្នកចូលរួម បង្កើតគ្នាជាក្រុម ដែលមានគ្នាចាប់ពី ៤-៨ នាក់ ។ ចែកឲ្យក្រដាស និងហ្វឺត ដល់ ក្រុមនីមួយៗ ។ ឲ្យក្រុមទាំងអស់ ចំណាយពេលត្រឹមតែ ១០ នាទីប៉ុណ្ណោះ ដើម្បីពិភាក្សាបញ្ហានៃ យុទ្ធការតស៊ូមតិ ហើយនិងបញ្ជីឈ្មោះមនុស្សណាដែលមានឥទ្ធិពលទៅលើបញ្ហានេះ ។

នៅពេលដែលក្រុមនីមួយៗ បញ្ចប់ការសរសេរនូវបញ្ជីរបស់ពួកគេរួចហើយ នោះសូមទូរស័ព្ទហៅ មនុស្សគ្រប់គ្នា មកជួបជុំគ្នាឡើងវិញដើម្បីធ្វើការពិភក្សាជាក្រុម ។ ឲ្យក្រុមនីមួយៗចែករំលែកនូវ លទ្ធផលរបស់ពួកគេជាមួយនឹងក្រុមដទៃទៀត ។

## ជំហាន ៥. រៀបចំសារយុទ្ធនាការតស៊ូមតិ ៖ តើមានសារអ្វីខ្លះ ដែលយើងចង់ប្រាប់ដល់ទស្សនិកជនគោលដៅរបស់យើង ?

សូមពន្យល់ថាសារយុទ្ធនាការ គឺជាប្រយោគដែលរៀបរាប់អំពីវត្ថុបំណង ។ សារយុទ្ធនាការ គួរតែ ៖

- សង្ខេបនូវវត្ថុបំណង
- ខ្លី
- មានន័យល្អ
- សាមញ្ញ (ងាយស្រួលយល់)
- ប្រាប់ពលរដ្ឋឲ្យធ្វើអ្វីមួយ ។

សារយុទ្ធនាការ មិនចាំបាច់ក្តោបទៅលើរាល់ចំណុចលម្អិតនៃវត្ថុបំណងឡើយ ។ វាគួរនិយាយទូទៅ មិនជាក់លាក់ពេក ។ ឧទាហរណ៍ ៖

- "គ្រាន់តែសរសេរលិខិត ក៏អាចធ្វើឲ្យមានការផ្លាស់ប្តូរបានដែរ!"
- "សូមគិតមុននឹងអ្នកធ្វើចំណាកស្រុក សុវត្ថិភាពជាចម្បង!"
- "កុមារទៅសាលារៀន មានអនាគតល្អ"។

ឧទាហរណ៍ នៃសារយុទ្ធនាការតស៊ូមតិ ដែលគ្មានប្រសិទ្ធិភាព មានដូចជា "យើងចង់ឲ្យកុមារចំនួន ២០ នាក់សរសេរលិខិតទៅគ្រូបង្រៀនរបស់យើង ពីព្រោះយើងចង់ឲ្យមានផលប្រែប្រួលទៅលើ ការធ្វើចំណាកស្រុក។" ហេតុអ្វីបានជាគ្មានប្រសិទ្ធិភាព?

- វាវែងពេក ។
- វាពិបាកចាំ ។
- វាមានពាក្យច្រើនដែលមនុស្សគ្រប់គ្នាមិនអាចយល់បាន ។

សារដែលគ្មានប្រសិទ្ធិភាពមួយទៀត គឺមានដូចជា "អ្នកដែលគិតចង់ធ្វើចំណាកស្រុក គួរបំពេញបញ្ជី ផ្ទៀងផ្ទាត់សុវត្ថិភាពជាមុនសិន។" ហេតុអ្វីបានសារនេះ គ្មានប្រសិទ្ធិភាព?

- វាវែងពេក ។
- វាជាក់លាក់ពេក ។
- វាពិបាកចាំ ។

សារដែលល្អ គួរមានលក្ខណៈដូចនេះ "សូមធ្វើផែនការមុននឹងអ្នកធ្វើចំណាកស្រុក ៖ បញ្ជីផ្ទៀងផ្ទាត់ អាចជួយសង្គ្រោះជីវិតអ្នកបាន!"

សូមឲ្យអ្នកចូលរួម រកឧទាហរណ៍សារយុទ្ធនាការសម្រាប់បញ្ហា ដែលពួកគេបានសម្រេចចិត្តផ្តោត យកចិត្តទុកដាក់ ។ ខណៈពេលដែលពួកគេកំពុងគិត សូមសរសេរសារនោះ នៅលើក្រដាសផ្លិបឆាត ដែលសមាជិកក្រុមគ្រប់គ្នាអាចមើលឃើញបាន ។ នៅក្នុងពេលដែលពួកគេកំពុងគិតរកសារបន្ថែម ទៀតនោះ សូមពិនិត្យមើលថាតើមានសារណាដែលស្រដៀងគ្នា ដែលអាចបញ្ចូលគ្នាបានដែរ ឬទេ ។ ឲ្យក្រុមអានសារ ដើម្បីផ្ទៀងផ្ទាត់ថាតើសារនោះ វាខ្លី សាមញ្ញ សង្ខេបនូវវត្ថុបំណង និងប្រាប់ពលរដ្ឋ ឲ្យធ្វើអ្វីមួយដែរ ឬទេ ។ សុំឲ្យក្រុមធ្វើការពិភាក្សាតើសារមួយណាដែល ពួកគេគិតថាមានប្រសិទ្ធិ ភាពបំផុតនោះ ។ បន្ទាប់មក ធ្វើការសម្រេចជាក្រុមថាតើសារមួយណា ត្រូវកំណត់យកធ្វើជាសារ សម្រាប់យុទ្ធនាការ ។

សូមពន្យល់ថាសារព័ត៌មាន ដូចជាកាសែតក្នុងស្រុក ឬស្ថានីយទូរទស្សន៍ អាចជួយពួកគេក្នុងការ បង្កើននូវឥទ្ធិពលនៃយុទ្ធនាការតស៊ូមតិរបស់ពួកគេបាន ។ ប្រសិនបើពួកគេត្រូវរៀបចំព្រឹត្តិការណ៍ នៅក្នុងមូលដ្ឋាន នោះវារឹតតែមានប្រសិទ្ធិភាពប្រសិនបើកាសែតសរសេរអត្ថបទអំពីយុទ្ធនាការនោះ ។ កាសែតក្នុងស្រុក អាចចុះផ្សាយនូវអាសយដ្ឋានអ៊ីមែល ឬអាសយដ្ឋាននៅក្នុងការសែត របស់គេ ឬនៅតាមអិនធឺណេតនៅលើវែបសាយរបស់ពួកគេ ។ ប្រសិនបើអ្នកចូលរួម សម្រេចចិត្ត ចែករំលែកនូវព័ត៌មានលំអិតអំពីអ្វីដែលពួកគេកំពុងធ្វើ ទៅឲ្យកាសែតក្នុងស្រុក

នោះពួកគេគួរសរ សេរនូវសេចក្តីសង្ខេបអំពីអ្វីដែលពួកគេកំពុងធ្វើ ហើយឲ្យវាមកបុគ្គលិករបស់អង្គការទស្សនពិភពលោកជាមុនសិន ។ បន្ទាប់មក ក្នុងរយៈពេលពីរបីសប្តាហ៍មុននឹងថ្ងៃរៀបចំព្រឹត្តិការណ៍ នោះពួកគេ គួរផ្ញើរអត្ថបទសេចក្តីសង្ខេបនោះទៅកាសែតក្នុងស្រុក ឬប៉ុស្តិ៍ទូរទស្សន៍ ដើម្បីឲ្យមានពេលវេលា គ្រប់គ្រាន់សម្រាប់សារព័ត៌មានរៀបចំផែនការរបស់គេ ។ ក្រោយមកទៀត អ្នកចូលរួមគួរធ្វើការតាម ដាន ដោយមានអ្នករំឭកផងដែរ ។ ភារកិច្ចនេះគួរកត់ថាជាសកម្មភាពនៅក្នុងផែនការតស៊ូមតិ ។

## សិក្សាអំពីសកម្មភាពយុទ្ធនាការតស៊ូមតិ ពេលវេលា និងថវិការ ៖ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បី សម្រេចនូវវត្ថុបំណងរបស់យើង ?

សូមពន្យល់ថានៅពេលដែលក្រុមបានសម្រេចជ្រើសរើសវត្ថុបំណង និងសារយុទ្ធនាការរបស់ពួក គេរួចហើយ នោះគឺដល់ពេលដែលត្រូវគិតអំពីសកម្មភាព ពេលវេលា និងថវិកាម្តង ។ សូមពន្យល់ ថាសកម្មភាព គឺជាអំពើដែលក្រុមធ្វើឡើងក្នុងគោលបំណងសម្រេចនូវគោលដៅរបស់ខ្លួន ។

សូមពន្យល់ថាសកម្មភាព យើងអាចប្រើប្រាស់នូវវិធីសាស្រ្តផ្សេងៗគ្នាដើម្បីធ្វើសកម្មភាពទាំងនោះ បាន ។ ឧទាហរណ៍ ៖

- សរសេរលិខិតទៅកាន់បុគ្គលដែលមានឥទ្ធិពលទៅលើអ្នកធ្វើចំណាកស្រុក (អាជ្ញាធរ មូលដ្ឋាន, ក្រុមហ៊ុនដឹកជញ្ជូន, សាលារៀនជាដើម)។
- ជួបជាមួយប្រធានសហគម ដើម្បីស្នើសុំឲ្យគាត់ចាត់វិធានការទៅលើបញ្ហា ។
- សរសេរជាលិខិតទៅអាជីវកម្មតាមមូលដ្ឋានដោយស្នើពួកគេឲ្យផ្លាស់ប្តូរនូវគោលនយោបាយរបស់ពួកគេ ។
- រៀបចំការធ្វើបទបង្ហាញទៅដល់ក្រុមប្រឹក្សាភិបាលសាលារៀន ដើម្បីផ្លាស់ប្តូរគោល នយោបាយ ។
- ធ្វើជាស្លាកសញ្ញា ឬជាផ្ទាំងរូបភាព ដោយដាក់ព្យួរនៅក្នុងសហគមន៍ ដើម្បីឲ្យមានឥទ្ធិពល ទៅលើអ្នករៀបចំគោលនយោបាយ ។
- រៀបចំការសម្តែងនៅក្នុងព្រឹត្តការណ៍សហគមន៍ ដើម្បីបញ្ចុះបញ្ចូលសមាជិកដែលជាទស្ស និកជន ឲ្យចាត់វិធានការធ្វើឲ្យមានឥទ្ធិពលប្រែប្រួលទៅលើគោលនយោបាយ ។
- ចុះទៅតាមផ្ទះ ពីផ្ទះមួយទៅផ្ទះមួយ ដើម្បីចែករំលែកនូវព័ត៌មានជាមួយនឹងពលរដ្ឋក្នុង ភូមិ ដោយស្នើឲ្យពួកគេជួយដាក់សម្ពាធទៅលើអាជ្ញាធរមូលដ្ឋានឲ្យចាត់វិធានការដោះ ស្រាយបញ្ហា ។
- ចូលរួមក្នុងវេទិកាថ្នាក់ជាតិ ដើម្បីពិភាក្សាអំពីទស្សនរបស់យុវជនទៅលើបញ្ហា ។
- ប្រសិនបើអ្នកមានអ៊ិនធឺណេតប្រើប្រាស់ នោះសូមរៀបចំនូវយុទ្ធនាការតាមអ៊ិនធឺណេត ដោយប្រើប្រាស់នូវបណ្តាញសង្គមដូចជា Facebook, Yahoo ឬ YouTube ដើម្បីលើក ទឹកចិត្តអ្នកប្រើប្រាស់ឲ្យចាត់វិធានការធ្វើឲ្យមានឥទ្ធិពលប្រែប្រួលណាមួយទៅលើគោលនយោបាយ ។

## អនុវត្តការកំណត់វត្ថុបំណង, ទស្សនិកជនគោលដៅ, សារយុទ្ធនាការ និងសកម្មភាព

សូមចែកឲ្យនូវប័ណ្ណព័ត៌មាន "IS២.៤ខ ៖ អនុវត្តការកំណត់វត្ថុបំណង កំណត់ទស្សនិកជន សារយុទ្ធនាការ និងសកម្មភាព" ។ សូមឲ្យអ្នកចូលរួមបង្កើតជាក្រុម ដែលមានសមាជិកពី ៥-៨ នាក់ ។

សុំឲ្យក្រុមអានឧទាហរណ៍ទីមួយនៅលើប័ណ្ណព័ត៌មាន បន្ទាប់មកឲ្យបំពេញឧទាហរណ៍ផ្សេងៗទៀត នៅលើឯកសារប័ណ្ណព័ត៌មាននោះ ។

នៅពេលដែលពួកគេកំពុងធ្វើកិច្ចការនោះ សូមដើរទៅពិនិត្យមើក្រុមទាំងអស់ ដើម្បីប្រាកដថា ឧទាហរណ៍របស់ពួកគេ គឺពិតជាត្រឹមត្រូវ ។ សូមពន្យល់បន្ថែមទៀត ប្រសិនបើអ្នកចូលរួម មាន ការភ័ន្តច្រឡំ ។ នៅពេលដែលពួកគេធ្វើរួចរាល់ហើយ នោះសូមឲ្យក្រុមទាំងអស់ចែកគ្នាមើលនូវ លទ្ធផលកិច្ចការរបស់ពួកគេ ។

## ការបិទបញ្ចប់

សួររកមើលថាតើមាននរណាម្នាក់មានសំណួរចង់សួរដែរ ឬទេអំពីវត្ថុបំណង ទស្សនិកជនគោលដៅ សារយុទ្ធនាការ និងសកម្មភាពតស៊ូមតិ ។ សូមពន្យល់ថានៅមេរៀនបន្ទាប់ នោះនឹងនិយាយអំ ពីសកម្មភាពតស៊ូមតិ ដើម្បីធ្វើយុទ្ធនាការ ។

## សង្ខេបមេរៀន

- វត្ថុបំណងរៀបរាប់នូវអ្វីដែលអ្នកចង់សម្រេច ។
- ទស្សនិកជនគោលដៅ រួមមានដូចជាបុគ្គលដែលអ្នកចង់ធ្វើឲ្យមានឥទ្ធិពលទៅលើពួកគាត់ នៅក្នុងការធ្វើយុទ្ធនាការរបស់អ្នក ។
- សារយុទ្ធនាការ គឺជាប្រយោគដែលរៀបរាប់អំពីវត្ថុបំណង ។
- សកម្មភាព គឺជាអំពើដែលអ្នកធ្វើដើម្បីសម្រេចនូវវត្ថុបំណងរបស់អ្នក ។

# IS ២.៤ក ៖ ផែនការតស៊ូមតិ

សូមអានការណែនាំ រួចហើយឆ្លើយសំណួរខាងក្រោមនេះ

**១. វត្ថុបំណងយុទ្ធនាការតស៊ូមតិ** (តើអ្នកចង់ឲ្យមានការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីដោះស្រាយ បញ្ហា?)

**២. ទស្សនិកជនគោលដៅ** (តើអ្នកចង់ឲ្យមានឥទ្ធិពលទៅលើបុគ្គលណាខ្លះ ?)
សូមឆ្លើយសំណួរខាងក្រោមនៅក្នុងចន្លោះខាងក្រោមនេះ ។

**តើនរណាជាទស្សនិកជនគោលដៅរបស់អ្នក** ? (អាយុ, ភេទ, ទីកន្លែង, មុខរបរ, និងចំណាប់ ចំណូលចិត្ត ប្រសិនបើអ្នកស្គាល់ពួកគេ)

**៣. សារយុទ្ធនាការ** ( តើសារគន្លឹះអ្វីខ្លះ ដែលអ្នកចង់បង្ហាញជូនទស្សនិកជនគោលដៅរបស់ អ្នក?)

សារយុទ្ធនាការរបស់អ្នកគួរ ៖
- ពន្យល់ឲ្យបានច្បាស់លាស់នូវអ្វីដែលអ្នកចង់ឲ្យពលរដ្ឋចូលរួមធ្វើ ។
- ជាការអំពាវនាវឲ្យមានការចាត់វិធានការ (ឧទាហរណ៍ "សូមចែករំលែករឿងនេះជា មួយមិត្តភក្តិរបស់អ្នកឲ្យបានបីនាក់" ឬ "ចុចលើតំណភ្ជាប់នេះ ដើម្បីជាការចុះហត្ថ លេខាលើញត្តិ" ឬ "សូមអញ្ជើញចូលរួមក្នុងកម្មវិធីរបស់យើង") ។
- អាចសម្រេចបាន (ចែករំលែករឿងនេះជាមួយមិត្តភក្តិបីនាក់ មិនមែន ចែករំលែកជា មួយមិត្តភក្តិ ១០ នាក់ឯណា ។ សូមមើលវីដេអូបីនាទីនេះ មិនមែន មើលវីដេអូ ២០ នាទីឯណា) ហាមមានលក្ខណៈជាការសួរសំណួរច្រើនពេក ។
- ខ្លី
- ងាយចាំ ។

**សូមសរសេរនូវសារយុទ្ធនការរបស់អ្នក នៅក្នុងប្រអប់ខាងក្រោមនេះ ។**

## ៤. សកម្មភាព

យុទ្ធនាការនីមួយៗ គួរដាក់កាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបញ្ចប់ ។ យុទ្ធនាការ ដែលទទួលបានជោគជ័យបំផុតនោះ គឺជាទូទៅមានរយៈពេលចន្លោះពីមួយខែ ទៅដល់ បីខែ ។

ការធ្វើផែនការសកម្មភាព គួរដាក់បញ្ចូលថាតើនរណានឹងត្រូវធ្វើអ្វីខ្លះ ហើយការងារនោះ នឹងត្រូវបញ្ចប់នៅពេលណា ។

អ្នកត្រូវបំពេញឲ្យបានច្រើនបំផុតនូវខ្លឹមសារ (ផ្ទាំងរូបភាព ខិត្តប័ណ្ណ ។ល។) មុននឹងអ្នក ចាប់ផ្តើមយុទ្ធនាការតស៊ូមតិរបស់អ្នក ។

នៅពេលដែលអ្នកបានសម្រេចជាចុងក្រោយទៅលើផែនការរបស់អ្នករួចហើយ នោះសូម ចាប់ផ្តើមយុទ្ធនាការរបស់អ្នក ។

| សកម្មភាព | សម្ភារ /ឧបករណ៍/ ប្រដាប់ប្រដា | អ្នកគាំទ្រ | ការទទួលខុសត្រូវ | រយៈពេល (ពេលបញ្ចប់) |
|---|---|---|---|---|
| | | | | |

## ៥. ថវិកា (អាចខានបាន)

| សម្ភារ | ថ្លៃក្នុងមួយឯកតា | ចំនួនដែលត្រូវការ | សរុប |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

ចំណាយសម្ភារសរុប ៖ ____________________

# IS ២.៤ខ ៖ អនុវត្តការកំណត់វត្ថុបំណង កំណត់ទស្សនិកជន សារយុទ្ធនាការ និងសកម្មភាព

## ឧទាហរណ៍ ១



យុវជនមួយក្រុមដឹងថាកសិដ្ឋានចិញ្ចឹមបង្គារនៅមូលដ្ឋានរបស់ពួកគេមួយ បានកំពុងយកត្រីធ្វើជាចំណី របស់បង្គារ ។ ត្រីទាំងនោះ ត្រូវបានផ្គត់ផ្គង់ដោយទូកនេសាទមួយ ដែលមានសុទ្ធតែអ្នកធ្វើ ចំណាកស្រុកត្រូវបានគេជួញដូរ ។ ក្រុមនោះ ចង់ដាក់សម្ពាធទៅលើកសិដ្ឋានបង្គារនៅមូលដ្ឋាន នោះកុំឲ្យទិញត្រីពីទូកនេសាទដែលមានការជួញដូរកម្លាំងពលកម្ម ។

សមាជិកយុវវ័យមួយក្រុម បានអាននូវអត្ថបទមួយនៅលើអ៊ិនធឺណិត ដែលមានចំណងជើងថា ផ្សារទំនើបរីករាយ បានទិញបង្គារពីរោងចក្របង្គារ ។ ផ្សារទំនើបនេះ មានវែបសាយរបស់គេ ដែលមាន នូវទំព័រសម្រាប់ផ្តល់មតិ និងអាសយដ្ឋានអ៊ីមែលសេវាអតិថិជន ។ ក្រុមយុវជន បានសម្រេចចិត្ត រៀបចំនូវយុទ្ធនាការមួយ ដែលឲ្យមនុស្សវ័យក្មេងសរសេរជាលិខិត រួចហើយចុះផ្សាយនៅលើទំព័រផ្តល់ មតិនៃវែបសាយរបស់ផ្សារទំនើបនោះ ដោយនិយាយថានឹងមិនមាន នរណាទិញបង្គារពីផ្សារទំនើបនេះទេ រហូតដល់ផ្សារនេះ ឈប់ទិញបង្គារពីរោងចក្របកបង្គារដែលមានការជួញដូរកម្លាំងពលកម្ម។

**វត្ថុបំណង**

ខ្សែសង្វាក់របស់ផ្សារទំនើប នឹងមិនទិញបង្គារពីរោងចក្របកបង្គារទេ ដរាបណារោងចក្រនោះ នៅ តែបន្តទិញត្រីពីទូកនេសាទដែលជួញដូរកម្លាំងពលកម្ម ។

**ទស្សនិកជនគោលដៅ**

ផ្សារទំនើប ពលរដ្ឋដែលសរសេរលិខិត និងរោងចក្របកបង្គារ ។

**សារយុទ្ធនាការ**

ប្រាប់ផ្សារទំនើបរីករាយថា ៖ យើងនឹងមិនទិញបង្គារដែលកើតចេញពីកម្លាំងពលកម្មដែលត្រូវគេ ជួញដូរទេ!

**សកម្មភាព**

១. យុវវ័យ ចាប់ផ្តើមធ្វើយុទ្ធនាការតាមបណ្តាញសង្គម ។ ពួកគេបានបង្កើតជាហ្វេសបុក (Facebook) និងធ្វីតធឺ (Twitter) ដែលមានតំណភ្ជាប់ទៅនឹងទំព័រផ្តល់មតិរបស់ផ្សារទំនើប ។ ពួកគេបានប្រាប់ មិត្តភ័ក្តិរបស់ពួកគេឲ្យចូលទៅទំព័រនោះ រួចហើយឲ្យចុះផ្សាយនូវមតិរបស់ពួកគេដោយនិយាយថាពួក គេនឹងមិនទៅទិញបង្គារដែលនាំមកពីរោងចក្រ បកបង្គាដែលមានការជួញដូរកម្លាំងពលកម្មនោះទេ ។

២. ពួកគេក៏បានរៀបចំនូវសិក្ខាសាលាសរសេរជាលិខិតមួយផងដែរ ដោយបានអញ្ជើញប្រជាពលរដ្ឋមកចូលរួមសរសេរជាលិខិតទៅផ្សារទំនើបដោយនិយាយថាពួកគេនឹងមិនទិញបង្គារពីរោងចក្រនេះទេ ។ នៅក្នុងសិក្ខាសាលា ពួកគេបានផ្តល់នូវអាសយដ្ឋាន ត្រា ក្រដាស និងម្ហូបអាហារ ព្រមទាំងភេសជ្ជៈផងដែរ ។

## ឧទាហរណ៍ ២



យុវជនមួយក្រុមបានកត់សម្គាល់ឃើញថាមានកុមារជាច្រើន បានបោះបង់ចោលការសិក្សា ហើយ បានធ្វើចំណាកស្រុកជាមួយនឹងជំនាញបន្តិចបន្តួចប៉ុណ្ណោះរបស់ពួកគេ ។ យុវជនក្រុមនោះ ជឿជាក់ ថាប្រសិនបើសាលារៀនមានគោលនយោបាយតម្រូវឲ្យគ្រូបង្រៀនចុះទៅដល់ផ្ទះរបស់កុមារដែល បោះបង់ចោលការសិក្សាគ្រប់រូប ដើម្បីលើកទឹកចិត្តសិស្សទាំងនោះ ឲ្យត្រឡប់មកសិក្សាវិញរួចហើយ ចែករំលែកនូវតម្លៃនៃការសិក្សានៅសាលារៀនឲ្យសិស្ស និងក្រុមគ្រួសាររបស់ពួកគេបានដឹងនោះ ពិតជាមានកុមារក្នុងចំនួនតិចតួចប៉ុណ្ណោះដែលបោះបង់ចោលការសិក្សា ។

**វត្ថុបំណង**

សាលារៀន បានអនុវត្តនូវគោលនយោបាយមួយដែលថានៅពេលណាក៏ដោយ ដែលកុមារអវត្តមាន ពីសាលារៀនលើសពីមួយសប្តាហ៍ នោះគ្រូបង្រៀនត្រូវចុះទៅដល់ផ្ទះរបស់សិស្សនោះដើម្បី ចែករំលែកនូវព័ត៌មានអំពីតម្លៃនៃការសិក្សា ដើម្បីទប់ស្កាត់ការធ្វើចំណាកស្រុកទាំងវ័យក្មេងពេក ។

**ទស្សនិកជនគោលដៅ**

សាលារៀន និងគ្រូបង្រៀននៅតាមសាលារៀន ។

***សូមសរសេរសារយុទ្ធនាការ និងសកម្មភាព ដែលអ្នកត្រូវរៀបចំ ដើម្បីសម្រេចនូវវត្ថុបំណង នៅខាងក្រោមនេះ***

**សារយុទ្ធនការ ៖**

**សកម្មភាព ៖**

## ឧទាហរណ៍ ៣



យុវជនមួយក្រុម បានដឹងថានឹងមានគណកម្មាការថ្នាក់មូលដ្ឋានមួយរបស់ពួកគេ ដែលនឹងផ្តល់យោបល់ដល់អាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់ជាតិអំពីបញ្ហានានាពាក់ព័ន្ធទៅនឹងការធ្វើចំណាកស្រុក និងការជួញដូរ ។ ពួកគេចង់ធានាថាគណកម្មាការនេះ ចាំបាច់ត្រូវដាក់បញ្ចូលយ៉ាងតិចណាស់ សមាជិកយុវវ័យម្នាក់របស់ពួកគេ ។

***សូមសរសេរអំពី វត្ថុបំណង, ទស្សនិកជនគោលដៅ, សារយុទ្ធនាការ, និងសកម្មភាព នៅខាងក្រោម ។***

**វត្ថុបំណង ៖**

**ទស្សនិកជនគោលដៅ ៖**

**សារយុទ្ធនាការ ៖**

**សកម្មភាព ៖**



# មេរៀន ២.៥ ៖ ធ្វើផែនការសកម្មភាព ពេលវេលា និងថវិកាសម្រាប់យុទ្ធនាការតស៊ូមតិ

## វត្ថុបំណង ៖

ដើម្បីជួយអ្នកចូលរួមធ្វើផែនការតស៊ូមតិមួយ ។

## រយៈពេល ៖

៩០ នាទី

## សម្ភារៈ ៖

- ប័ណ្ណព័ត៌មាន "IS ២.៤ក ៖ ផែនការតស៊ូមតិ កាលពីមេរៀនមុន

## ស្វាគមន៍

ប្រសិនបើមេរៀននេះ គឺមេរៀនមួយផ្នែកដែលបានយកមកបណ្ដុះបណ្ដាលនៅក្នុងសិក្ខាសាលា នោះអ្នកចូលរួមបានស្វាគមន៍គ្នារួចហើយ ។ ប៉ុន្តែប្រសិនបើមេរៀននេះ ត្រូវយកមកបង្រៀននៅក្នុង ក្លឹបយុវវ័យតាមភូមិនោះ សូមស្វាគមន៍យុវវ័យ ។ សូមលេង "ល្បែងបង្កភាពកក់ក្ដៅ" ដោយអាចដកស្រង់ចេញពីបញ្ជីនៅក្នុងឯកសារគាំទ្របាន ។

## ការផ្ដើមមេរៀន

សូមចង្អុលទៅកាន់ប័ណ្ណព័ត៌មាន "IS ២.១២ ៖ ជំហាននានា ឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ" និងឯកសារ "IS ២.៤ក ៖ ផែនការតស៊ូមតិ" ដែលអ្នកបានចាប់ផ្ដើមបង្រៀនកាលពីមេរៀនលើក មុន ។ សូមពន្យល់ថាជំនាញធ្វើផែនការដែលអ្នកចូលរួមរៀននៅថ្ងៃនេះ អាចមានសារប្រយោជន៍ នៅក្នុងផ្នែកផ្សេងទៀតនៃជីវិតរបស់ពួកគេ ។

សូមពន្យល់ថានៅក្នុងមេរៀននេះ ពួកគេត្រូវនឹកគិតរកសកម្មភាពផ្សេងៗ ដើម្បីសម្រេចនូវវត្ថុបំណង របស់អ្នក ។ សុំឲ្យអ្នកចូលរួមប្រាប់អ្នកនូវ ៖

- វត្ថុបំណងនៃយុទ្ធនាការតស៊ូមតិ
- ទស្សនិកជនគោលដៅនៃយុទ្ធនាការតស៊ូមតិនេះ ។
- សារយុទ្ធនាការតស៊ូមតិ ។

## រៀបចំសកម្មភាពតស៊ូមតិ ដើម្បីធ្វើយុទ្ធនាការនេះ

សុំឲ្យមនុស្សម្នាក់កំណត់នូវសកម្មភាពតស៊ូមតិ ។ (ចម្លើយ ៖ សកម្មភាពតស៊ូមតិ គឺជាអំពើ ដែល អ្នកចូលរួមត្រូវធ្វើដើម្បីសម្រេចនូវវត្ថុបំណង) ។

សូមរំឭកក្រុមថាសកម្មភាព រាប់បញ្ចូលនូវវិធីជាច្រើន ។ សូមពិនិត្យនូវឧទាហរណ៍ខាងក្រោម កាលពីរៀននៅក្នុងមេរៀនលើកមុន ជាមួយនឹងអ្នកចូលរួមឡើងវិញ ៖

- យុទ្ធនាការសរសេរលិខិត ទៅកាន់បុគ្គលដែលមានឥទ្ធិពលទៅលើបញ្ហា ។
- ជួបប្រជុំជាមួយនឹងសហគមន៍ ។
- ចុះទៅជួបជាមួយនឹងទស្សនិកជនគោលដៅដោយផ្ទាល់ ឬធ្វើសិក្ខាសាលានៅតាម សហគមន៍ ឬចាប់ផ្ដើមដំណើរការក្លឹប ឬជួបជាមួយនឹងអ្នកចាស់ទុំ នៅក្នុងសហគមន៍ ដើម្បីធ្វើឲ្យមានឥទ្ធិពលទៅលើគំនិតរបស់ទស្សនិកជនគោលដៅ ។

- ប្រើប្រាស់នូវបណ្តាញសង្គម (ប្រសិនបើអ្នកចូលរួម និងទស្សនិកជនគោលដៅមាន ប្រើ ប្រាស់បណ្តាញសង្គម នោះ ក្រុមអាចជ្រើសរើសប្រើ Facebook, Twitter ឬ YouTube ដើម្បីដាក់សំពាធទៅលើអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងគោលបំណងដើម្បីឲ្យមានការ ផ្លាស់ប្តូរគោលនយោបាយ ។)
- ធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរគោលនយោបាយ
- ជួបប្រជុំជាមួយនឹងនាយកសាលារៀននៅតាមមូលដ្ឋានដើម្បីបញ្ចុះបញ្ចូលពួកគេឲ្យ ផ្លាស់ប្តូរគោលនយោបាយ ។
- ជួបប្រជុំជាមួយនឹងបុគ្គលនៅក្នុងរដ្ឋាភិបាល ដើម្បីធ្វើឲ្យមានឥទ្ធិពលដល់គោលនយោ បាយ ។
- ប្រើប្រាស់នូវវិធីសាស្ត្រច្នៃប្រឌិត ដូចជាការសម្តែង ឬការគូរផ្ទាំងរូបភាព ដើម្បីគាំទ្រដល់ កិច្ចខិតខំប្រឹងប្រែងដោយផ្ទាល់ (ដូចជាការសរសេរជាលិខិត) ដើម្បីធ្វើឲ្យមានឥទ្ធិពល ទៅលើការកែប្រែក្នុងចំណោមអ្នករៀបចំគោលនយោបាយ ។
- ផ្ទាំងរូបភាព ខិត្តប័ណ្ណ ឬផ្ទាំងគំនូរលើជញ្ជាំង ។

សុំឲ្យអ្នកចូលរួម បង្កើតជាក្រុមដែលមានគ្នាចាប់ពី ៦- ១០ នាក់ ។ ឲ្យក្រុមនីមួយៗ "ធ្វើសកម្មភាព តាមផែនការ" ដើម្បីពិនិត្យមើលរកសកម្មភាពតស៊ូមតិ ដែលក្រុមនីមួយៗអាចធ្វើបាននៅក្នុងយុទ្ធនា ការតស៊ូមតិ ។ សុំឲ្យអ្នកចូលរួមសរសេរនូវគំនិតរបស់ពួកគេនៅលើក្រដាសស្អិត នៅពេលធ្វើសកម្ម ភាពតាមផែនការនោះ ។ (ប្រាប់ពួកគេឲ្យសរសេរបានស្អាត ដើម្បីឲ្យអ្នកចូលរួមផ្សេងទៀតអាច អានបាន ។)

ឥឡូវនេះ សូមឲ្យអ្នកចូលរួម ដើរជុំវិញថ្នាក់រៀន រួចហើយឲ្យទៅមើលការងាររបស់ក្រុមដទៃទៀត ។

សូមព្យួរក្រដាសផ្លិបឆាតនៅលើជញ្ជាំង ។ សុំឲ្យអ្នកចូលរួមជ្រើសរើសគំនិតចំនួនពីរដែលពួកគេ ចូលចិត្តបំផុតពីក្រុមណាមួយក៏បាន រួចហើយឲ្យបិតក្រដាសស្អិតនៅលើក្រដាសផ្លិបឆាតនេះ ។ អ្នកចូលរួម ដែលចូលចិត្តគំនិតដែលមានគេចូលចិត្តដែរនោះ គួរបន្ថែមឈ្មោះរបស់គាត់ នៅក្នុងក្រ ដាសស្អិតនោះ ដើម្បីបង្ហាញថាមានសម្លេងឆ្នោតលើសពីមួយ ។ នៅពេលដែលពួកគេគ្រប់គ្នា បាន ជ្រើសរើសគំនិតទាំងនោះរួចហើយ នោះសូមជ្រើសរើសគំនិតចំនួនបី ដែលមានការចូលចិត្តបំផុត ចេញពីក្រដាសផ្លិបឆាត ។

**សូមបង្កើតជាបញ្ជីសម្រាប់គំនិតដែលមានការចូលចិត្តបំផុត ផ្សេងទៀត ព្រោះថាអ្នកចូលរួម អាចត្រូវការប្រើនូវគំនិតទាំងនេះនៅក្នុងព្រឹត្តិការណ៍តស៊ូមតិនៅក្នុងពេលអនាគតបាន ។**

សូមពិភាក្សាសំណួរទាំងបីនេះ (ជាពិសេស ប្រសិនបើពួកគេមានបញ្ហាក្នុងការសម្រេចចិត្តជ្រើស រើសគំនិត) ៖

- តើគំនិតមួយណាដែលមានប្រសិទ្ធិភាពបំផុត ?
- តើគំនិតមួយណា ដែលអាចអនុវត្តទៅបាន ដោយប្រើប្រាស់ថវិការ និងពេលវេលាដែល យើងមាននេះ ?
- តើគំនិតមួយណា ដែលមានភាពសប្បាយរីករាយបំផុត ?

បន្ទាប់មកទៀត សូមឲ្យក្រុមឈានដល់ការព្រមព្រៀងគ្នារួមមួយ ដើម្បីឲ្យពួកគេគ្រប់គ្នា មានអារម្មណ៍ ប្តូរផ្តាច់ក្នុងការដោះស្រាយបញ្ហារួមគ្នា ។ ប្រសិនបើការព្រមព្រៀងរួមមួយ មិនអាចធ្វើទៅបានទេ នោះសូមចែកឲ្យក្រដាសមួយចំរៀកតូចទៅពួកគេម្នាក់ៗ រួចហើយឲ្យពួកគេបោះឆ្នោត ។

នៅពេលដែលអ្នកចូលរួម បានជ្រើសរើសនូវសកម្មភាពសំខាន់ៗ សម្រាប់ផែនការតស៊ូមតិរបស់ ពួកគេរួចហើយ នោះពួកគេអាចត្រូវការជំនួយខ្លះៗ ពេលធ្វើការពិចារណាជំហានមូលដ្ឋាន ដែល ពាក់ព័ន្ធជាមួយនឹងសកម្មភាពនីមួយៗ ។

ឧទាហរណ៍ ៖ សកម្មភាពសំខាន់ គឺឡើងធ្វើបទបង្ហាញដល់ប្រធានភូមិ ដើម្បីស្នើសុំពួកគាត់ឲ្យរក្សា ទុកនូវសៀវភៅមួយក្បាលដែលអ្នកធ្វើចំណាកស្រុកត្រូវចុះហត្ថលេខា ទុកលេខទូរស័ព្ទរបស់ពួកគេ និងគោលដៅដែលពួកគេចង់ទៅ មុននឹងពួកគេធ្វើចំណាកស្រុក ។ ជំហានសំខាន់ៗ នៃសកម្មភាព នេះ មានដូចជា ៖

- រកមធ្យោបាយដ៏ត្រឹមត្រូវក្នុងការទំនាក់ទំនងជាមួយប្រធានភូមិ ។
- សរសេរលិខិតដើម្បីស្នើសុំឲ្យមានការប្រជុំមួយ ។
- បង្កើតជាបទបង្ហាញជាលាយលក្ខណ៍អក្សរមួយ ស្តីពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដោយ គ្មានផែនការ និងអំពីអត្ថប្រយោជន៍នៃការទុកលេខទូរស័ព្ទ និងគោលដៅដែលចង់ទៅ ។
    - ស្រាវជ្រាវ និងសរសេររបាយការណ៍ ។
    - ពិនិត្យកែសម្រួលរបាយការណ៍ ។
    - ថតរូប ឬស្វែងរករូភាព ដើម្បីដាក់អមជាមួយនឹងរបាយការណ៍ ។
    - អនុវត្តការឡើងអានរបាយការណ៍ ។
- ទាក់ទងជាមួយនឹងអង្គការទស្សនពិភពលោកដើម្បីចែករំលែកនូវផែនការរបស់អ្នក ។
- ទាក់ទងជាមួយនឹងបណ្តាញសារព័ត៌មានដើម្បីជម្រាបពួកគេអំពីផែនការរបស់អ្នក ។
- ចែកបទបង្ហាញឲ្យប្រធានភូមិ ។
- តាមដានក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់មកទៀត ដើម្បីស្វែងយល់ពីលទ្ធផល ។
- ប្រសិនបើទទួលបានជោគជ័យ នោះសូមចែករំលែកនូវរឿងរ៉ាវនេះជាមួយនឹងមិត្តរួមការងារ ហើយបើសមស្រប អាចចែកជូនដល់សារព័ត៌មានបាន ។

សុំឲ្យអ្នកចូលរួមគិតអំពីប្រភេទនៃសកម្មភាពលំអិតទាំងនេះ សម្រាប់គម្រោងផ្ទាល់របស់ពួកគេ ។ បន្ទាប់មកទៀត សុំឲ្យអ្នកស្ម័គ្រចិត្តម្នាក់ សរសេរសំណូមពរ នៅលើផែនការតស៊ូមតិដែលបានលើក យកមកបង្ហាញនោះ ។

## ពិភាក្សាសម្ភារ

សុំអ្នកចូលរួមឲ្យមើលទៅលើសកម្មភាពនៅលើផែនការតស៊ូមតិ ។ សូមពន្យល់ថា បន្ទាប់មកទៀត នេះ ពួកគេត្រូវការគិតថាតើពួកគេត្រូវការសម្ភារអ្វីខ្លះ ដើម្បីបញ្ចប់សកម្មភាពទាំងនេះ ។

សូមពន្យល់ថាសម្ភារ គឺជារបស់របរដែលក្រុម ត្រូវការដើម្បីធ្វើនូវសកម្មភាពរបស់ពួកគេ ។ ឧទាហរណ៍ ប្រសិនបើក្រុមមួយ កំពុងធ្វើបទបង្ហាញដល់មន្ត្រីសាលារៀនអំពីការធ្វើចំណាកស្រុក នោះ ក្រុមអាចត្រូវការនូវសម្ភារដូចខាងក្រោម ៖

- ឯកសារចែកឲ្យ ដែលជាបទបង្ហាញសរសេរជាអក្សរសម្រាប់មន្ត្រីសាលារៀនម្នាក់ៗ ។
- រូបថតសម្រាប់អមជាមួយនឹងបទបង្ហាញរបស់ពួកគេ ។
- ម៉ាស៊ីនហ្វូតូកូពី ។

ក្រុមដែលរៀបចំការប្រគុំតន្ត្រី អាចនឹងត្រូវការ ៖

- សម្លៀកបំពាក់
- ម៉ាញេ
- មេក្រូ/ធុងបាស
- ខ្សែភ្លើង
- ក្រណាត់ផ្ទាំងធំ
- ដែកវ៉ាយស៍សុវត្ថិភាព

សុំឲ្យសមាជិកក្រុម រិះគិតអំពីសម្ភារ ដែលពួកគេត្រូវការដើម្បីធ្វើសកម្មភាពនីមួយៗ ដែលពួកគេ បានជ្រើសរើសនោះ ។

## ពិភាក្សាអំពីអ្នកគាំទ្រ

អ្នកគាំទ្រ គឺជាមនុស្សនៅក្នុងសហគមន៍ ដែលប្រហែលជាអាចជួយដល់គម្រោងបាន ។ ខាងក្រោមនេះ គឺជាឧទាហរណ៍ ៖

- ប្រសិនបើអ្នកព្យាយាមធ្វើឲ្យមានការផ្លាស់ប្តូរណាមួយដល់គោលនយោបាយនៅក្នុង សាលារៀននោះ គ្រូបង្រៀនអាចណែនាំក្រុមអ្នកឲ្យជួបជាមួយមន្ត្រីសាលារៀនបាន ។
- ប្រសិនបើអ្នកដើរចែកខិត្តប័ណ្ណ នោះអង្គការមិនមែនរដ្ឋាភិបាល អាចអនុញ្ញាតឲ្យអ្នក ប្រើប្រាស់នូវម៉ាស៊ីនថតចម្លងរបស់ពួកគេបាន ដោយឥតគិតថ្លៃ ។
- ប្រសិនបើអ្នកត្រូវរៀបចំយុទ្ធនាការសរសេរលិខិត នោះអង្គការមិនមែនរដ្ឋាភិបាល អាច ជួយអ្នកក្នុងការចែកលិខិតរបស់អ្នកបាន ។
- ប្រសិនបើអ្នកត្រូវរៀបចំវេទិកាយុវវ័យ នោះអង្គការមិនមែនរដ្ឋាភិបាល អាចជួយអ្នក ស្វែងរកទីកន្លែងសម្រាប់រៀបចំព្រឹត្តិការណ៍បាន ឬទាក់ទងជាមួយនឹងមនុស្សវ័យក្មេង ផ្សេងទៀត ។
- ប្រសិនបើអ្នកចង់ធ្វើឲ្យមានការផ្លាស់ប្តូរគោលនយោបាយរបស់ក្រុមហ៊ុនរថយន្តក្រុង នោះត្រូវមាននរណាម្នាក់ដែលអាចណែនាំអ្នកឲ្យស្គាល់ម្ចាស់ក្រុមហ៊ុនបាន ។
- ប្រសិនបើអ្នកត្រូវរៀបចំនូវយុទ្ធនការសារព័ត៌មានសង្គម នោះអង្គការ អាចអនុញ្ញាតឲ្យ អ្នកប្រើប្រាស់នូវកុំព្យូទ័រ និងអ៊ិនធឺណិតរបស់ពួកគេបានដោយឥតគិតថ្លៃ ។

សុំឲ្យក្រុមចំណាយពេលប្រហែលជាមួយនាទីដើម្បីធ្វើ "សកម្មភាពតាមផែនការ" រិះរកអ្នកគាំទ្រ ។

រួចហើយ សួរក្រុមឲ្យសម្រេចចិត្តថាតើអ្នកគាំទ្រទាំងនេះ អាចជួយដល់ពួកគេបានដែរ ឬក៏អត់ ។ សុំឲ្យពួកគេជ្រើសរើសអ្នកគាំទ្រណា ដែលពួកគេត្រូវទៅរកដើម្បីសុំជំនួយ ។

## ថវិការ( អាចខានបាន )

(ជំហាននេះ គួរធ្វើតែនៅពេលណាដែលអ្នកសម្របសម្រួលគិតថាសមាជិកក្រុម មានជំនាញក្នុងការបំពេញវាតែប៉ុណ្ណោះ ។)

សុំឲ្យអ្នកចូលរួម មើលចំណងជើងតូច នៅខាងចុងប័ណ្ណព័ត៌មាន "IS ២.៤ក៖ ផែនការតស៊ូមតិ" ដែលសរសេរចំណងជើងថា "ថវិការ" ។

**ជម្រើសអាចធ្វើក៏បាន មិនធ្វើក៏បាន ៖** សូមពន្យល់ថាអង្គការទស្សនពិភព លោក មានកញ្ចប់ថវិការបន្តិចបន្តួចដើម្បីផ្តល់ជូនក្លឹបក្នុងការគាំទ្រនូវគម្រោង តស៊ូមតិរបស់ពួកគេ ។ សូមពន្យល់ថាប្រសិនបើអ្នកចូលរួមចង់ដាក់ពាក្យសុំ ថវិការទាំងនេះ នោះពួកគេអាចដាក់ពាក្យតាមរយៈអ្នកសម្របសម្រួលរបស់ ពួកគេបានដោយភ្ជាប់ជាមួយនូវផែនការតស៊ូមតិពេញលេញរបស់ពួកគេ ព្រមទាំងតម្រូវការថវិការ ជូនទៅបុគ្គលិករបស់អង្គការទស្សនពិភពលោក ដែលទទួលបន្ទុកត្រួតពិនិត្យក្លឹបយុវវ័យ ។

សុំឲ្យអ្នកចូលរួមចម្លងពីបញ្ជីសម្ភារ នូវគ្រប់គុឡោន ដែលមានចំណងជើងថា "សម្ភារ" នៅលើផែនការតស៊ូមតិ ។ បន្ទាប់មកសុំឲ្យអ្នកចូលរួមសរសេរថាតើរបស់របរទាំងអស់នោះ មានតម្លៃប៉ុន្មាន នៅគុឡោនបន្ទាប់ ដែលសរសេរថា "ថ្លៃក្នុងមួយឯកតា" ។ ប្រសិនបើអ្នកចូលរួមមិនចេះធ្វើវាទេ នោះអ្នកសម្របសម្រួល អាចសុំឲ្យពួកគេយកទម្រង់វិក្កយបត្រនេះ ទៅកាន់ហាងទំនិញ រួចហើយ ឲ្យសួរពីថ្លៃទំនិញ រួចហើយប្រគល់វិក្កយបត្រនេះ នៅក្នុងមេរៀនលើកក្រោយ ។

បន្ទាប់មកទៀត នៅក្នុងកូឡោន ដែលសរសេរថា "ចំនួននៃមុខទំនិញដែលត្រូវការ" នោះសូមឲ្យអ្នកចូលរួមសរសេរ អំពីចំនួនដែលពួកគេត្រូវការ ។

ជាចុងក្រោយ នៅក្នុងកូឡោន ដែលសរសេរថា "សរុប" នោះសូមឲ្យអ្នកចូលរួមគណនាអំពីថ្លៃទំនិញ ទាំងអស់ដោយគុណថ្លៃក្នុងមួយឯកតា ជាមួយនឹង ចំនួនមុខទំនិញដែលត្រូវការ ។

ឧទាហរណ៍ ៖

| សម្ភារ | ថ្លៃក្នុងមួយឯកត្តា | ចំនួននៃមុខទំនិញដែលត្រូវការ | សរុប |
|---|---|---|---|
| ក្ដារសម្រាប់បិត | $1.50 | 10 | $15 |
| ប៊ិច | $0.50 | 50 | $25 |
| សរុប | | | $40 |

សូមធ្វើវាម្ដងទៀត ដោយប្រើប្រាស់នូវសម្ភារទាំងអស់វិញម្ដង ។ បន្ទាប់មក បន្ថែមចំនួនឲ្យច្រើន ទៅក្នុងកូឡោន ដែលមានសរសេរអក្សរថា "សរុប" រួចហើយសរសេរចម្លើយរបស់ពួកគេ នៅលើបន្ទាត់ខាងក្រោម ដែលសរសេរថា "សរុបថ្លៃសម្ភារ" ។

## ពន្យល់ការទទួលខុសត្រូវ

សូមពន្យល់ថាការទទួលខុសត្រូវ គឺមានន័យថា តើនរណា ត្រូវធ្វើការមួយណា ។ សួរក្រុមថាតើនរណាត្រូវទទួលខុសត្រូវធ្វើការងារអ្វីខ្លះ ។ សួររកអ្នកស្ម័គ្រចិត្តម្នាក់ ដើម្បីធ្វើការងារផ្សេងៗទៀត ។ សូមរំឭកអ្នកចូលរួមថា ប្រសិនបើពួកគេមានអារម្មណ៍មិនសប្បាយចិត្តក្នុងការធ្វើការនេះទេនោះពួកគេ មិនចាំបាច់ធ្វើវាទេ ។ សូមចងចាំថា ត្រូវបញ្ចូលការស្វែងរក អ្នកគាំទ្រដើម្បីជួយការងារជាផ្នែក មួយនៃការងាររបស់ក្រុមផងដែរ ។

## ពិភាក្សាអំពីពេលវេលាតាមដំណាក់កាលនីមួយៗ

សូមពន្យល់ថា ពេលវេលាតាមដំណាក់កាលនីមួយៗ គឺជាបញ្ជីរៀបរាប់អំពីកាលបរិច្ឆេទដែលមាន ការពន្យល់ថាការងារនឹងត្រូវបញ្ចប់នៅពេលណា ។

សូមពន្យល់ថាក្រុមអាចសម្រេចចិត្តរៀបចំព្រឹត្តិការណ៍តស៊ូមតិជាក្រុមក៏បាន ឬជាបុគ្គលក៏បាន ។ ក្រុមនឹងធ្វើការសម្រេច ថាតើនៅពេលណា និងនៅទីកន្លែងណា ដែលត្រូវយកជំហាននីមួយៗ ទៅ អនុវត្ត ។

សួរក្រុម "តើនៅពេលណាដែលសមាជិកម្នាក់ៗ បញ្ចប់ជំហាននីមួយៗ?" សូមឲ្យពួកគេសរសេរ ចម្លើយរបស់ពួកគេ នៅក្បែរឈ្មោះពួកគេ នៅលើផែនការតស៊ូមតិ ។

## ការបញ្ចប់មេរៀន

សូមពន្យល់ថា នៅមេរៀនបន្ទាប់ ពួកយើងនឹងធ្វើការពិចារណាអំពីហានិភ័យដែលអាចកើតឡើង បានពាក់ព័ន្ធជាមួយនឹងផែនការ និងការកែសម្រួលផែនការ ប្រសិនបើចាំបាច់ ។

### សន្ខេបមេរៀន

សូមឲ្យអ្នកចូលរួម អានឮៗ នូវផែនការតស៊ូមតិ រួមមានវត្ថុបំណង សកម្មភាព ទស្សនិកជនគោលដៅសារ យុទ្ធនាការ សម្ភារ ការទទួលខុសត្រូវ និងពេលវេលាតាមដំណាក់កាលនីមួយៗ ។



# មេរៀន ២.៦ ៖ ធ្វើការវាយតម្លៃ និងកាត់បន្ថយហានិភ័យ (គ្រោះថ្នាក់) នៅពេលធ្វើផែនការតស៊ូមតិ

## វត្ថុបំណង ៖

ដើម្បីវាយតម្លៃ និងកាត់បន្ថយហានិភ័យដែលកើតឡើងចំពោះយុវវ័យ បណ្តាលមកពីការចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិ ។

## រយៈពេល ៖

៩០ នាទី

## សម្ភារៈ ៖

- ប័ណ្ណព័ត៌មាន "IS ២.១ក ៖ គំរូការតស៊ូមតិ"
- ឯកសារថតចម្លងនៃផែនការតស៊ូមតិ
- ឯកសារនោះសម្រាប់អ្នកចូលរួមម្នាក់ៗ
  - ប័ណ្ណព័ត៌មាន "IS២.៦ក ៖ សំណួរសុវត្ថិភាព" ឯកសារចម្លងសម្រាប់ក្រុមនីមួយៗ ដែលមានសមាជិកអ្នកចូលរួមពី៦-៨ នាក់ ។
  - ប័ណ្ណព័ត៌មាន "IS ២.៦ខ ៖ ធ្វើចំណាត់ថ្នាក់ហានិភ័យ" ថតចម្លងដាក់ក្រដាសផ្លិបឆាតសម្រាប់ក្រុមទាំងអស់ ។
  - ប័ណ្ណព័ត៌មាន "IS ២.៦គ ៖ ទម្រង់លិខិតយល់ព្រមចូលរួមក្នុងយុទ្ធនាការតស៊ូមតិ "សម្រាប់អ្នកចូលរួម"
  - ប័ណ្ណព័ត៌មាន "IS ២.៦ឃ ៖ ទម្រង់លិខិតយល់ព្រមឲ្យចូលរួមក្នុងយុទ្ធនាការតស៊ូមតិ "សម្រាប់អាណាព្យាបាល"

## ស្វាគមន៍

ប្រសិនបើមេរៀននេះ គឺមេរៀនមួយផ្នែកដែលបានយកមកបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលា នោះអ្នកចូលរួមបានស្វាគមន៍គ្នារួចហើយ ប៉ុន្តែប្រសិនបើមេរៀននេះត្រូវយកមកបង្រៀននៅក្នុង ក្លឹបយុវជនតាមភូមិ នោះសូមស្វាគមន៍យុវជន។សូមលេង"ល្បែងបង្កភាពកក់ក្តៅ" ដោយអាចដកស្រង់ចេញពីបញ្ជីនៅក្នុងឯកសារគាំទ្របាន ។

## ផ្តើមមេរៀន

ស្វាគមន៍ អ្នកចូលរួមចំពោះការមកចូលរួមនៅក្នុងមេរៀននេះ ។ សូមចង្អុលទៅកាន់ផែនការតស៊ូមតិ ដែលពួកគេបានបំពេញកាលពីរៀនមេរៀនលើកមុន ផែនការនោះ មាននិយាយអំពីវត្ថុបំណងក្រុមគោលដៅ យុទ្ធនាការតស៊ូមតិ សកម្មភាព ពេលវេលា និងថវិការ ។ (នៅក្នុងករណី មួយចំនួន) ។ សុំឲ្យអ្នកស្ម័គ្រចិត្តអានផែនការតស៊ូមតិ ព្ទ១ ។

សូមពន្យល់ថានៅថ្ងៃនេះ យើងនឹងធ្វើការរិះគិតទាំងអស់គ្នាអំពី "ជំហានទី ៧. វាយតម្លៃហានិភ័យដែលកើតមានចំពោះយុវវ័យ នៅក្នុងការធ្វើយុទ្ធនាការតស៊ូមតិ ៖ តើយើងត្រូវធ្វើដូចម្តេចដើម្បីប្រាកដ ថាយុទ្ធនាការតស៊ូមតិមានសុវត្ថិភាពសម្រាប់ពួកយើង? ដែលដកស្រង់ចេញពីប័ណ្ណព័ត៌មាន "IS២.៩ខ ៖ ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ" ។ ***(ឯកសារចម្លងផ្ទាំងធំ នៃប័ណ្ណព័ត៌ មាននេះ គួរយកដាក់បង្ហាញនៅគ្រប់មេរៀនទាំងអស់នៅក្នុងម៉ូឌីលនេះ ។ )***

## ជំហាន ៦ ៖ វាយតម្លៃហានិភ័យដែលកើតមានឡើងចំពោះយុវជន នៅក្នុងការធ្វើយុទ្ធនាការតស៊ូមតិ ៖ តើយើងត្រូវធ្វើដូចម្តេច ដើម្បីប្រាកដថាយុទ្ធនាការតស៊ូមតិមានសុវត្ថិភាពសម្រាប់ពួកយើង?

សុំឲ្យអ្នកចូលរួមបង្កើតគ្នាជាក្រុមដែលមានសមាជិកចាប់ពី៦-៨ នាក់ ។ ចែកឯកសារថតចម្លង នៃផែនការតស៊ូមតិ ឲ្យក្រុមនីមួយៗ និងប័ណ្ណព័ត៌មាន "IS២.៦ក ៖ សំណួរសុវត្ថិភាព" ។

សុំឲ្យក្រុមនីមួយៗអាននូវសកម្មភាពដែលមានរៀបរាប់នៅក្នុងផែនការតស៊ូមតិ ។ សុំឲ្យអ្នកចូលរួមប្រើប្រាស់នូវសំណួរដែលមាននៅក្នុងប័ណ្ណព័ត៌មាន "IS២.៦ក ៖ សំណួរសុវត្ថិភាព" ដើម្បីវាយតម្លៃសកម្ម ភាពដែលបានរៀបរាប់ពីខាងលើនោះ ។ សម្រាប់សកម្មភាពនីមួយៗ ដែលមាននៅក្នុងផែនការតស៊ូ មតិនោះ នោះអ្នកចូលរួមត្រូវឆ្លើយសំណួរ បាទ/ចាស ឬទេ ដើម្បីកំណត់ថាតើនេះជាហានិភ័យ ឬក៏ អត់ ។ នៅពេលណាដែលអ្នកចូលរួមឆ្លើយ បាទ/ចាស នោះពួកគេគួរសរសេរហានិភ័យនៅលើក្រដាសស្អិត ។ យើងហៅក្រដាសស្អិតដែលយើងសរសេរចម្លើយនេះថា "ក្រដាសស្អិតហានិភ័យ"។

ឧទាហរណ៍នៃក្រដាសស្អិតហានិភ័យ ៖

- ការចូលរួមនៅក្នុងផែនការតស៊ូមតិនេះ អាចនឹងបណ្តាលឲ្យអ្នកចូលរួម គ្មានសុវត្ថិភាពនៅពេលយប់ ។
- ការចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិនេះ អាចបណ្តាលឲ្យអ្នកចូលរួមខឹងឪពុកម្តាយ របស់ពួកគេ ។

ប្រសិនបើចម្លើយគឺ ទេ នោះពួកគេមិនត្រូវសរសេរអ្វីឡើយនៅលើក្រដាសស្អិតនោះ ។

ត្រូវធានាថាអ្នកចូលរួម បានធ្វើការពិចារណាគ្រប់ហានិភ័យទាំងអស់ ដែលមាននៅលើបញ្ជីសកម្មភាព។ ត្រូវទុកពេលឲ្យពួកគេ ធ្វើការពិចារណា។ នៅពេលដែលក្រុមបញ្ចប់សកម្មភាពរបស់ពួកគេ រួចហើយ នោះសុំឲ្យពួកគេចែករំលែកនូវលទ្ធផលដែលគេរកឃើញ។សុំឲ្យពួកគេយកក្រដាសស្អិតនោះទៅបិតនៅលើក្រដាសផ្លីបឆាត ។

បន្ទាប់មកទៀត សូមឲ្យអ្នកចូលរួមចែករំលែកនូវគំនិតរបស់ពួកគេអំពីវិធីសាស្រ្តខ្លះៗ ដើម្បីកាត់បន្ថយនូវហានិភ័យ។ សុំឲ្យក្រុមស្វែងរកមធ្យោបាយមួយដើម្បីចៀសវាង ឬកាត់បន្ថយហានិភ័យ ដែលបានរៀបរាប់នៅក្នុងបញ្ជីពីខាងលើនោះ ។ សូមសរសេរមធ្យោបាយទាំងនោះនៅលើក្រដាសផ្លីបឆាត។ រួចហើយឲ្យពួកគេមើលបញ្ជី និងធ្វើការព្រមព្រៀងរួមមួយថាតើត្រូវផ្លាស់ប្តូរផែនការដោយរបៀបណា ដើម្បីធ្វើឲ្យការធ្វើសកម្មភាពកាន់តែមានសុវត្ថិភាព ។

អ្នកចូលរួម ក៏អាចមានលទ្ធភាពបង្កើតនូវមធ្យោបាយខ្លះៗ ដើម្បីធ្វើឲ្យផែនការតស៊ូមតិកាន់តែមាន សុវត្ថិភាពបានដែរដើម្បីកុំឲ្យសល់មានក្រដាសស្អិត។ ប្រសិនបើអាចធ្វើបែបនេះបាន នោះសូមរំលងទៅ "ជំហានចុងក្រោយ" ខាងក្រោម ។

ទោះជាដូច្នេះក៏ដោយ ប្រសិនបើមាននៅសល់ក្រដាសស្អិតមួយចំនួនទៀត ដែលនៅមិនទាន់សរសេរដំណោះស្រាយនៅលើនោះនៅឡើយ នោះសូមចែកប័ណ្ណព័ត៌មាន "IS២.៦ខ ៖ ធ្វើចំណាត់ថ្នាក់ហា និភ័យ" ។ សូមពន្យល់ថាអ្នកចូលរួម ត្រូវតម្រៀបហានិភ័យដែលនៅសេសសល់នៅលើឆាត ។ សូមពន្យល់ថាសម្រាប់ក្រដាសស្អិតនីមួយៗ អ្នកចូលរួមត្រូវសម្រេចថាតើហានិភ័យនោះ មានកម្រិតធ្ងន់ធ្ងរប៉ុណ្ណា ហើយលទ្ធភាពអាចកើតឡើងកម្រិតណាដែរ ។

ឧទាហរណ៍ ប្រសិនបើក្រដាសស្អិតសរសេរថា "ការចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិ អាចបណ្តាលឲ្យអ្នកចូលរួមត្រូវរងនូវការវាយដំពីឪពុករបស់ពួកគេ" នោះអ្នកចូលរួមអាចគិតថារឿងនេះ "ប្រាកដ ជាអញ្ចឹង" ហើយជារឿងដែល "ធ្ងន់ធ្ងរបំផុតហើយអាចកើតឡើងបាន" ។ ដូច្នេះ ពួកគេនឹងដាក់ក្រដាសស្អិតនៅលើជ្រុងខាងលើខាងស្តាំដៃនៃតារាងមិនខាន។ ប្រសិនបើក្រដាសស្អិតមានសរសេរថា"ការចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិ អាចតម្រូវឲ្យអ្នកចូលរួមធ្វើដំណើរតាមរថយន្តក្រុងទៅកាន់ខេត្តមួយទៀត" នោះអ្នកចូលរួម ប្រហែលឯកភាពថាហានិភ័យ គឺ "ប្រាកដជាអញ្ចឹង" ប៉ុន្តែ វាមាន"ភាពធ្ងន់ធ្ងរបន្តិចបន្តួច" តែប៉ុណ្ណោះ ដែលនៅក្នុងករណីនេះ ពួកគេនឹងយកក្រដាសស្អិតទៅ ដាក់នៅជ្រុងខាងក្រោមខាងស្តាំដៃ ។

សុំឲ្យអ្នកចូលរួមគ្រៀមក្រដាសស្អិតដែលរៀបរាប់អំពីហានិភ័យនោះ នៅលើផាត ។ បន្ទាប់មកឲ្យពួកគេមើលមកផាត ។ ផ្ទៃពណ៌ក្រហម បង្ហាញអំពីសកម្មភាពដែលមានហានិភ័យខ្ពស់ ។ ផ្ទៃពណ៌ លឿង បង្ហាញពីសកម្មភាពដែលមានហានិភ័យមធ្យម ឬទាប ។ ប្រសិនបើក្រដាសស្អិតទាំងអស់ ស្ថិតនៅលើផ្ទៃពណ៌ស នោះក្រុមទាំងអស់ នឹងមានសុវត្ថិភាពបន្តសកម្មភាពរបស់ពួកគេ ។ យ៉ាងនេះក្តី ប្រសិនបើមានហានិភ័យនៅសេសសល់នៅក្នុងផ្ទៃពណ៌ក្រហម នោះក្រុមត្រូវធ្វើការកែសម្រួលនូវផែនការតស៊ូមតិម្តងទៀតមុននឹងបន្តសកម្មភាពរបស់ពួកគេ ។ ផែនការតស៊ូមតិអាចនឹងមិនត្រូវបានផ្លាស់ប្តូរប្រសិនបើហានិភ័យស្ថិតនៅក្នុងផ្ទៃពណ៌លឿងប៉ុន្តែពួកគេត្រូវផ្តល់ជាគំនិតថាតើត្រូវកាត់បន្ថយហានិភ័យនោះ ដោយរបៀបណា ឬត្រូវចៀសវាងវាដោយរបៀបណា និងត្រូវធ្វើអ្វីខ្លះ ប្រសិនបើហានិភ័យកើតឡើង ជាដើម នោះត្រូវសរសេររឿងទាំងអស់នេះ ទុកជាលំហាត់មួយ របស់ពួកគេ ។ សំណូមពរមួយចំនួនសម្រាប់កែសម្រួលផែនការតស៊ូមតិ មានដូចជា ៖

- ធ្វើដំណើរតាមមធ្យោបាយយានយន្តសាធារណជាជាងធ្វើដំណើរដោយម៉ូតូ
- កាន់ទូរស័ព្ទដៃ និងបញ្ជីលេខទូរស័ព្ទសម្រាប់គ្រាបន្ទាន់
- រៀបចំឡើងវិញនូវភារកិច្ច ឬពេលវេលា ដើម្បីឲ្យអ្នកចូលរួមដែលកំពុងធ្វើការរកលុយ ឬសិស្សសាលាមិនចាំបាច់ខកខានមិនបានទៅធ្វើការ ឬទៅសាលារៀន ។
- ហាមរៀបចំកិច្ចប្រជុំនៅពេលយប់; កំណត់ពេលវេលារៀបចំព្រឹត្តិការណ៍តស៊ូមតិឡើងវិញ និងធ្វើនៅទីកន្លែងដែលមានសុវត្ថិភាព ឬពេលវេលាដែលមានសុវត្ថិភាព ពេលថ្ងៃ ។
- ធ្វើដំណើរជាក្រុមជាមួយនឹងមនុស្សពេញវ័យ ឬជាមួយនឹងមិត្តភក្តិ
- ស្នើសុំឲ្យអង្គការក្រៅរដ្ឋាភិបាល ឬមនុស្សពេញវ័យដែលគួរឲ្យគោរព ផ្តល់យោបល់ដល់ក្រុម អំពីរបៀបទំនាក់ទំនងជាមួយនឹងអាជ្ញាធរ
- មានពាក់ព័ន្ធជាមួយនឹងក្រុមគ្រួសារ និងសមាជិកសហគមដែលគួរឲ្យគួរពចាប់តាំងពីដើម ដំបូងមេរៀនដើម្បីឲ្យពួកគេអាចផ្តល់យោបល់ដល់ក្រុមអំពីយុទ្ធនាការ និងប្រគល់ជូនរឿង នេះជូនអាជ្ញាធររបស់ពួកគេ ។
- ស្វែងរកតួនាទីដែលមិនមែនស្ថិតក្នុងវិស័យសាធារណ សម្រាប់អ្នកចូលរួមដែលអាចប្រឈម មុខទៅនឹងហានិភ័យដោយសារត្រូវបានកត់សម្គាល់ឃើញថាមានវត្តមាននៅក្នុងយុទ្ធនាការ តស៊ូមតិសាធារណ
- លាក់ទុកជាការសម្ងាត់នូវអត្តសញ្ញាណរបស់អ្នកចូលរួម ។

## ជំហានចុងក្រោយ

នៅពេលដែលក្រុម បានធ្វើការកែសម្រួលនូវផែនការ ដើម្បីកុំឲ្យមានហានិភ័យបន្តទៀតនៅក្នុងផ្ទៃក្រហមនោះ នោះអ្នកសម្របសម្រួលគួរអនុវត្តតាមជំហានខាងក្រោមនេះ ៖

- សរសេរឡើងផែនការយុទ្ធនាការតស៊ូមតិនោះ ។
- ថតចម្លងប័ណ្ណព័ត៌មាន "IS២.៦គ ៖ ទម្រង់លិខិតយល់ព្រមចូលរួមក្នុងយុទ្ធនាការតស៊ូមតិ" សម្រាប់អ្នកចូលរួម" ឬ "IS ២.៦឵ឃ ៖ ទម្រង់លិខិតយល់ព្រមចូលរួមក្នុងយុទ្ធនាការតស៊ូមតិ" សម្រាប់ ឪពុកម្តាយ/អ្នកថែទាំរបស់អ្នកចូលរួម ដែលមានអាយុក្រោម ១៨ ឆ្នាំ (នៅពេលដែលពាក់ព័ន្ធ) រួចហើយភ្ជាប់ទម្រង់លិខិតយល់ព្រមនេះ ជាមួយនឹងឯកសារថតចម្លងយុទ្ធនាការតស៊ូ មិត ។
- ស្នើសុំឲ្យអ្នកចូលរួម (ឬឪពុកម្តាយ/អ្នកថែទាំរបស់ពួកគេ ប្រសិនបើអ្នកចូលរួមមានអាយុ ក្រោម១៨ឆ្នាំ) ឲ្យចុះហត្ថលេខាលើទម្រង់លិខិតយល់ព្រម ។
- ផ្ញើរឯកសារ នៃផែនការធ្វើយុទ្ធនាការតស៊ូមតិនោះ ទៅកាន់អង្គការទស្សនពិភពលោកដើម្បី ស្នើសុំការអនុញ្ញាតបន្តធ្វើយុទ្ធនាការតស៊ូមតិ ដែលបានគ្រោងទុកនោះ ។

## ការបិទបញ្ចប់

ត្រូវប្រាកដថាអ្នកចូលរួមទាំងអស់ (ឬឪពុកម្តាយ/អ្នកថែទាំរបស់ពួកគេ ប្រសិនបើពួកគេមានអាយុក្រោម ១៨ ឆ្នាំ) ពិតជាបានចុះហត្ថលេខាទៅលើទម្រង់លិខិតយល់ព្រមមុននឹងបន្តផែនការសកម្មភាពតស៊ូមតិ ។

ប្រើប្រាស់ផែនការតស៊ូមតិដើម្បីកំណត់ពេលវេលាសម្រាប់មេរៀននៅពេលអនាគតដើម្បីបញ្ចប់សកម្មភាពដែលបានរៀបរាប់ ។ ត្រូវប្រាកដថាអ្នកចូលរួម បានដឹងច្បាស់អំពីទីកន្លែង និងពេលវេលា ដែលត្រូវជួបជុំគ្នា តើនរណានឹងត្រូវផ្តល់នូវសម្ភារ និងថាតើមានសកម្មភាពណាមួយនៃសកម្មភាពទាំងនេះអាចធ្វើបញ្ចប់ក្រៅម៉ោងរៀននៅក្នុងក្លឹបបានដែរ ឬទេ ។ សូមបញ្ជាក់អំពីផែនការនេះ ជាមួយនឹងសមាជិកក្លឹបគ្រប់រូប មុននឹងពួកគេចាកចេញត្រឡប់ទៅវិញ ។

## សង្ខេបមេរៀន

- យុទ្ធនាការតស៊ូមតិ មិនគួរដាក់ឲ្យអ្នកចូលរួមប្រឈមនឹងហានិភ័យធ្ងន់ធ្ងរ ដែលអាចនឹងកើតឡើងនោះឡើយ ។
- សកម្មភាពយុទ្ធនាការតស៊ូមតិ គួរមានភាពបត់បែនដើម្បីធ្វើឲ្យសកម្មភាពទាំងនោះ មានលក្ខណៈផ្តល់សុវត្ថិភាពប្រសិនបើអ្នកចូលរួមជឿជាក់ថាវានឹងធ្វើឲ្យក្រុមណាមួយប្រឈម នឹងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដែលអាចនឹងកើតឡើងនោះ ។
- យុទ្ធនាការតស៊ូមតិ អាចបន្តធ្វើបាន តែក្នុងករណីដែលអ្នកចូលរួមចាត់ទុកថាយុទ្ធនាការនេះ មានសុវត្ថិភាពបង្គួរ ។ អ្នកចូលរួម (ឬអាណាព្យាបាលប្រសិនបើពួកគេមានអាយុក្រោម ១៨ ឆ្នាំ) បានចុះហត្ថលេខាលើទម្រង់លិខិតយល់ព្រម ហើយបុគ្គលិកត្រួតពិនិត្យរបស់អង្គការទស្សនពិភពលោកបានផ្តល់ការអនុញ្ញាត ។

# IS ២.៦ក ៖ សំណួរសុវត្ថិភាព

តើការចូលរួមនៅក្នុងសកម្មភាពតស៊ូមតិ ឬផែនការនេះ...

| | បាទ/ចាស | ទេ |
|---|---|---|
| បណ្តាលឲ្យអ្នកចូលរួមខកខានចូលរៀននៅសាលារៀន? | | |
| បណ្តាល់ឲ្យអ្នកចូលរួមខកខានមិនបានទៅធ្វើការ និងមិនបានរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ ? | | |
| ពាក់ព័ន្ធជាមួយនឹងការធ្វើដំណើរនៅពេលយប់ ? | | |
| ពាក់ព័ន្ធការធ្វើដំណើរតាមមធ្យោបាយយានជំនិះគ្រោះថ្នាក់ (ដូចជាម៉ូតូ) ? | | |
| ទុកឲ្យអ្នកចូលរួមជាកុមារនៅតែម្នាក់ឯងជាមួយនឹងមនុស្សពេញវ័យតែម្នាក់? | | |
| បណ្តាលឲ្យមានការកំណត់បាននូវអត្តសញ្ញាណរបស់អ្នកចូលរួម លេចឮដឹងដល់ពួកជួញដូរ ឬមនុស្សផ្សេងទៀតដែលជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ? | | |
| តម្រូវឲ្យអ្នកចូលរួមដេកនៅឆ្ងាយពីផ្ទះ? | | |
| កើតឡើងនៅពេលយប់? | | |
| កើតឡើងនៅទីកន្លែងដែលគ្មានសុវត្ថិភាព? | | |
| ធ្វើឲ្យអ្នកចូលរួមក្លាយជាគោលដៅនៃការប្រើអំពើហឹង្សាដែលប្រព្រឹត្តិឡើង ដោយអ្នកជួញដូរ ឬដោយបុគ្គលផ្សេងទៀត? | | |
| ធ្វើឲ្យប៉ះពាល់ ឬមានការខឹងសម្បារដល់ ៖<br>• មិត្តភក្តិ<br>• ក្រុមគ្រួសារ<br>• សមាជិកសហគម<br>• អាជ្ញាធរមូលដ្ឋាន<br>• អ្នកផ្សេងទៀត | | |

# IS ២.៦ខ ៖ ចាត់ចំណាត់ថ្នាក់ហានិភ័យ

| | ទំនងជាអាច | ប្រហែលនឹង កើតឡើង | ទំនងនឹង កើតឡើង | ប្រាកដ |
|---|---|---|---|---|
| ធ្ងន់ធ្ងរខ្លាំង ហើយអាចកើត ឡើងបាន | | | | |
| ធ្ងន់ធ្ងរ | | | | |
| ធ្ងន់ធ្ងរបង្គួរ | | | | |
| មិនសូវធ្ងន់ធ្ងរ | | | | |

# IS ២.៦គ ៖ ទម្រង់លិខិតយល់ព្រមសម្រាប់យុទ្ធនាការតស៊ូមតិ - អ្នកចូលរួម

- ខ្ញុំបានអានផែនការតស៊ូមតិនេះ ។
- ខ្ញុំយល់ថាខ្ញុំ មិនចាំបាច់ចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិនេះក៏បាន ។
- ខ្ញុំយល់ថាខ្ញុំ អាចសម្រេចចិត្តចូលរួមនៅក្នុងផ្នែកជាក់លាក់ណាមួយ នៃយុទ្ធនាការតស៊ូមតិនេះបាន ។
- ខ្ញុំយល់ថាខ្ញុំ អាចសម្រេចចិត្តចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិនេះ ដោយមិនចាំបាច់បង្ហាញឲ្យដឹងនូវអត្តសញ្ញាណរបស់ខ្ញុំទៅកាន់សាធារណជនឡើយ ។

**សូមអាន និងចុះហត្ថលេខានៅលើទម្រង់លិខិតនេះ មុននឹងអ្នកចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិ។**

ខ្ញុំបានអាន និងយល់នូវព័ត៌មានខាងលើ ។

ខ្ញុំសម្រេចចិត្តចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិនេះ ។

ខ្ញុំយល់ថាខ្ញុំអាចឈប់នៅពេលណាមួយក៏បាន ។

ឈ្មោះ ________________________________________ កាលបរិច្ឆេទ __________________

ហត្ថលេខា________________________________________________________________________

# IS ២.៦យ ៖ ទម្រង់លិខិតយល់ព្រមសម្រាប់ឪពុកម្តាយ ឬអ្នកថែទាំអ្នកចូលរួមដែលមានអាយុ ក្រោម ១៨ ឆ្នាំ

- ខ្ញុំបានអានផែនការតស៊ូមតិនេះ ។
- ខ្ញុំយល់ថាកូនរបស់ខ្ញុំ មិនចាំបាច់ចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិនេះទេ ។
- ខ្ញុំយល់ថាកូនរបស់ខ្ញុំ អាចសម្រេចចិត្តចូលរួមនៅក្នុងផ្នែកជាក់លាក់ណាមួយ នៃយុទ្ធនាការតស៊ូមតិនេះបាន ។
- ខ្ញុំយល់ថាកូនរបស់ខ្ញុំ អាចសម្រេចចិត្តចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិនេះ ដោយមិនចាំ បាច់ចែកបង្ហាញឲ្យដឹងនូវអត្តសញ្ញាណរបស់គាត់ទៅកាន់សាធារណជនឡើយ ។

**សូមអាន និងចុះហត្ថលេខានៅលើទម្រង់លិខិតនេះ មុននឹងកូនរបស់អ្នក ចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិ ។**

ខ្ញុំបានអាន និងយល់នូវព័ត៌មានខាងលើ ។

ខ្ញុំសម្រេចចិត្តអនុញ្ញាតឲ្យកូនរបស់ខ្ញុំចូលរួមនៅក្នុងយុទ្ធនាការតស៊ូមតិនេះ ។

ខ្ញុំយល់ថាកូនរបស់ខ្ញុំអាចឈប់នៅពេលណាមួយក៏បាន ។

ឈ្មោះ ______________________________ កាលបរិច្ឆេទ__________________

ហត្ថលេខា ______________________________________________



# មេរៀន ២.៧ ៖ អនុវត្តផែនការយុទ្ធនាការតស៊ូមតិ

## វត្ថុបំណង ៖

បំពេញភារកិច្ចសម្រាប់ធ្វើយុទ្ធនាការតស៊ូមតិ ។

## ពេលវេលា ៖

អ្នកសម្របសម្រួល និងអ្នកចូលរួម នឹងសម្រេចអំពីពេលវេលានេះ ផ្អែកតាមសកម្មភាពតស៊ូមតិ ដែលមានរៀបរាប់នៅក្នុងផែនការ ។

## សម្ភារ ៖

- ផែនការតស៊ូមតិ ដែលមានចំណុចលំអិតសម្រាប់សកម្មភាពតស៊ូមតិ

## រៀបចំ ៖

ប្រសិនបើអ្នកចូលរួម មកចូលរួមនៅក្នុងសិក្ខាសាលាបណ្ដុះបណ្ដាលលើកដំបូង នេះ នោះសម្របសម្រួល ត្រូវអាន និងពិភាក្សាមេរៀននេះជាមួយនឹងអ្នកចូលរួម ប៉ុន្តែ ពួកគេមិនចាំបាច់រៀនរហូតដល់ចប់មេរៀននេះទេ ។ ប្រសិនបើអ្នកចូលរួម ចូលរួមរៀននៅក្នុងក្លឹបយុវជនតាមមូលដ្ឋាន និងបង្កើតនូវយុទ្ធនាការតស៊ូមតិផ្ទាល់ របស់ពួកគេ នោះក្រុមត្រូវរៀនឲ្យចប់មេរៀននេះ ។ រៀនមេរៀននេះ ឲ្យបានច្រើនដងយោងតាមភាពចាំបាច់ ខណៈពេលដែលក្រុម កំពុងដំណើរការរៀនរបស់ពួកគេអំពី ផែនការតស៊ូមតិ ។

## សូមស្វាគមន៍ ៖

ប្រសិនបើមេរៀននេះ គឺមេរៀនមួយផ្នែកដែលបានយកមកបណ្ដុះបណ្ដាលនៅក្នុងសិក្ខាសាលា នោះអ្នកចូលរួមបានស្វាគមន៍គ្នារួចហើយ ។ ប៉ុន្តែប្រសិនបើមេរៀននេះ ត្រូវយកមកបង្រៀននៅក្នុង ក្លឹបយុវជនតាមភូមិ នោះសូមស្វាគមន៍យុវជន។ សូមលេង "ល្បែងបង្កភាពកក់ក្ដៅ" ដោយអាចដកស្រង់ចេញពីបញ្ជីនៅក្នុងឯកសារគាំទ្របាន ។

## ការណែនាំ ៖

ស្វាគមន៍អ្នកចូលរួម ចំពោះការបង្កើតជាក្រុម ។ លើកបង្ហាញនូវផែនការតស៊ូមតិ ដែលមានចំណុចលំអិតអំពីយុទ្ធនាការតស៊ូមតិរបស់ក្រុម។ សុំឲ្យក្រុមអាននូវផែនការតស៊ូមតិ រួមមានសកម្មភាព និងការទទួលខុសត្រូវ។ បំភ្លឺថាតើនរណាត្រូវធ្វើសកម្មភាពអ្វី តើពួកគេត្រូវការសម្ភារអ្វីខ្លះហើយសកម្មភាពនឹងត្រូវបញ្ចប់នៅពេលណា ។

ខណៈពេលដែលអ្នកចូលរួម ដំណើរការទៅលើសកម្មភាពរបស់ពួកគេ នោះសូមលើកទឹកចិត្តឲ្យមានការសហការ និងផ្ដល់ជាការរិះគន់ស្ថាបនា និងការគាំទ្រ ។

ប្រសិនបើអ្នកចូលរួម បានសម្រេចចិត្តរួចហើយថាត្រូវធ្វើសកម្មភាពមួយចំនួនណានោះដោយឯកពាជ្យ នៅក្រៅពេលរៀននៅក្នុងក្លឹប នោះអ្នកសម្របសម្រួល ត្រូវរៀបចំឲ្យមានការជួបប្រជុំជាទៀង ទាត់មួយដើម្បីតាមដានដំណើរវិវត្តន៍ ។

## ធ្វើការកែសម្រួលផែនការតស៊ូមតិតាមសភាពការណ៍ /សង្ខេបមេរៀន ៖

នៅចុងបញ្ចប់នៃមេរៀន នោះសូមសុំឲ្យក្រុមមើលទៅលើសកម្មភាព និងពេលវេលាតាមដំណាក់ទីមួយៗ ដើម្បីពិនិត្យមើលថាតើភារកិច្ច ត្រូវបានបញ្ចប់ទាន់ពេលវេលាដែរ ឬក៏អត់ ។ ប្រសិនបើចាំ បាច់នោះក្រុមអាចកែសម្រួលពេលវេលាបាន ។

សួរក្រុមថាតើមានសកម្មភាពណាមួយ ដែលអាចនឹងកើតឡើងបាន ដែលយើងមិនទាន់សរសេរចូលទៅក្នុងផែនការនៅឡើយ ។ ប្រសិនបើមាន នោះសូមសុំឲ្យអ្នកចូលរួមបន្ថែមវាចូល ។

បញ្ជាក់ថាតើនរណានឹងត្រូវធ្វើសកម្មភាពដែលនៅសេសសល់ ហើយថាពួកគេត្រូវបញ្ចប់វានៅពេលណា ។

## ការបញ្ចប់មេរៀន ៖

សូមបញ្ចប់ការប្រជុំ ដោយត្រូវធ្វើការបញ្ជាក់អំពីពេលវេលាដែលក្រុមត្រូវជួបជុំគ្នាម្តងទៀតកាងារអ្វីខ្លះនឹងត្រូវធ្វើឲ្យហើយ ហើយនរណានឹងត្រូវធ្វើការងារអ្វីខ្លះ ។

ប្រសិនបើនេះ គឺជាលើកចុងក្រោយដែលក្រុមជួបជុំគ្នា មុននឹងពួកគេធ្វើសកម្មភាពតស៊ូមតិនោះ សូមធ្វើការបញ្ជាក់ថាពួកគេរាល់គ្នា ត្រូវរៀបចំខ្លួនឲ្យរួចរាល់ មានជំនឿចិត្ត និងដឹងអំពីពេលវេលា និងទីកន្លែង ។ ត្រូវកំណត់ពេលរៀនអនុវត្តលើកចុងក្រោយមួយសារទៀត ប្រសិនបើអ្នកយល់ថា វាចាំបាច់ ។

សួររកមើលថា តើមាននរណានៅមានសំណួរ ឬការព្រួយបារម្ភណាមួយទេ ។

## យុទ្ធនាការតស៊ូមតិ ៖

នៅពេលដែលពួកគេបានបំពេញបញ្ចប់រាល់ជំហានទាំងអស់នៅក្នុងផែនការតស៊ូមតិរួចរាល់អស់ហើយ នោះក្រុម នឹងរៀបចំនូវព្រឹត្តិការណ៍តស៊ូមតិរបស់ពួកគេ ។



# មេរៀន២.៨ ៖ វាយតម្លៃយុទ្ធនាការតស៊ូមតិ

## វត្ថុបំណង ៖

ដើម្បីវាយតម្លៃយុទ្ធនាការតស៊ូមតិ និងរៀបចំផែនការសម្រាប់ពេលអនាគត ។

## ពេលវេលា ៖

៣០ នាទី។

## សម្ភារៈ ៖

- ប័ណ្ណព័ត៌មាន "IS២.៨ ៖ ការវាយតម្លៃ" ចម្លងឯកសារនេះ សម្រាប់ក្រុមនីមួយៗ ដែលមានសមាជិកក្រុមចាប់ពី ៦-១០ នាក់ ។
- "វិញ្ញាបនប័ត្រចូលរួម" សម្រាប់អ្នកចូលរួមម្នាក់ ។

## រៀបចំ ៖

ការវាយតម្លៃ គួរបំពេញឲ្យបានលឿនបំផុត បន្ទាប់ពីរៀបចំព្រឹត្តិការណ៍តស៊ូមតិ ។ ត្រូវប្រាកដច្បាស់ថាប័ណ្ណព័ត៌មាន "IS ២.១២ ៖ ជំហាននានាឆ្ពោះទៅរកការរៀបចំនូវ យុទ្ធនាការតស៊ូមតិ" បានយកមកដាក់បង្ហាញ ។

## សូមស្វាគមន៍ ៖

ប្រសិនបើមេរៀននេះ គឺមេរៀនមួយផ្នែកដែលបានយកមកបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលា នោះអ្នកចូលរួមបានស្វាគមន៍គ្នារួចហើយ ។ ប៉ុន្តែប្រសិនបើមេរៀននេះ ត្រូវយកមកបង្រៀននៅក្នុងក្លឹបយុវវ័យតាមភូមិ នោះសូមស្វាគមន៍យុវវ័យ ។ សូមលេង "ល្បែងបង្កភាពកក់ក្តៅ" ដោយអាចដក ស្រង់ចេញពីបញ្ជីនៅក្នុងឯកសារគាំទ្របាន ។

## វាយតម្លៃយុទ្ធនាការតស៊ូមតិ ៖

សូមចង្អុលបង្ហាញថាការពិភាក្សានេះ ក្តោបទៅលើជំហានទាំង ១០ សម្រាប់រៀបចំយុទ្ធនាការតស៊ូមតិ "វាយតម្លៃយុទ្ធនាការតស៊ូមតិ ៖ តើយុទ្ធនាការ ទទួលបានជោគជ័យកម្រិតណា? តើបញ្ហា ប្រឈមអ្វីខ្លះ ដែលយើងជួបប្រទះ?" សូមពន្យល់ថាការវាយតម្លៃ មានន័យថាជាការមើលរកនូវ បញ្ហាប្រឈម និងជោគជ័យនៃយុទ្ធនាការ ហើយថាបញ្ហាប្រឈម គឺជារឿងដែលយើងពិបាកអនុវត្ត ឬសម្រេចឲ្យបាន ឬក៏រឿងដែលយើងបានអនុវត្តហើយ ប៉ុន្តែវាបរាជ័យ ដោយសារមូលហេតុនេះ ឬ មូលហេតុនោះ ។

សុំឲ្យអ្នកចូលរួមបង្កើតគ្នាជាក្រុមដែលមានសមាជិកចាប់ពី ៦-១០ នាក់ ។

ចែកឲ្យក្រុមនីមួយៗនូវប័ណ្ណព័ត៌មានចម្លង "IS ២.៨ ៖ការវាយតម្លៃ"។ សូមឲ្យសមាជិកក្រុមឆ្លើយសំណួរដែលមាននៅលើឯកសារនោះរួមគ្នា។

មុននឹងពួកគេចាប់ផ្តើម សូមលើកទឹកចិត្តឲ្យអ្នកចូលរួម មានភាពស្មោះត្រង់ជាទីបំផុត ទាំងទៅលើភាពជោគជ័យ និងបញ្ហាប្រឈម ។ វាជាការសំខាន់ណាស់ដែលត្រូវទទួលស្គាល់ថាគ្មានអ្វីដែលវា ល្អឥតខ្ចោះនោះឡើយ ។ វាតែងតែមានរឿងដែលយើងអាចធ្វើប្រសើរជាងនេះតែប៉ុណ្ណោះ ។ ការរៀនពីកំហុសខ្លួនឯង គឺជារឿងសំខាន់ណាស់សម្រាប់អ្នកចូលរួម ។

បន្ទាប់ពីរយៈពេល ១៥ នាទីនេះ សូមឲ្យអ្នកចូលរួមជួបជុំគ្នា ជាក្រុមតែមួយ រួចហើយឲ្យចែករំលែកនូវចម្លើយរបស់ពួកគេ។ សូមលើកទឹកចិត្តឲ្យមានការពិភាក្សាខណៈពេលដែលពួកគេ ធ្វើ ការពិភាក្សា។

## សង្ខេបមេរៀន

- សង្ខេបពីកត្តាជោគជ័យ និងបញ្ហាប្រឈមក្នុងការធ្វើយុទ្ធនាការតស៊ូមតិ។
- សង្ខេបពីការរៀបចំផែនការអនាគត។

# IS ២.៨ ៖ ការវាយតម្លៃ

## សូមសរសេរវត្ថុបំណងនៃយុទ្ធនាការតស៊ូមតិនៅទីនេះ ៖

## ឆ្លើយទៅនឹងសំណួរខាងក្រោម ៖

1. តើសកម្មភាពដំណើការតាមផែនការដែរឬទេ ?

2. តើអ្នកគិតថាយុទ្ធនាការតស៊ូមតិ អាចផ្លាស់ប្តូរការយល់ឃើញ ឬអាកប្បកិរិយារបស់ទស្សនិកជនគោលដៅដែរ ឬទេ ? ប្រសិនបើអាចផ្លាស់ប្តូរ តើរបៀបណា? ប្រសិនបើមិនអាច តើហេតុអ្វី ?

3. តើអ្នកជួបប្រទះនូវបញ្ហាប្រឈមដែលមិនបានរំពឹងទុកណាមួយទេ ? ប្រសិនបើជួបប្រទះ នោះសូមរៀបរាប់។ តើអ្នកអាចផ្លាស់ប្តូរដោយរបៀបណានៅលើកក្រោយ ដើម្បីចៀសវាងការលំបាកទាំងនោះដែរ ឬទេ

4. តើមានអ្វីកើតឡើងល្អៗ ឬអាក្រក់ ដែលអ្នកមិនបានរំពឹងទុក ដែរ ឬទេ ។ ប្រសិនបើមាន សូមរៀបរាប់ ។

World Vision®

# វិញ្ញាបនបត្រ បញ្ជាក់ការសិក្សា

សូមបញ្ជាក់ថា

បានទទួលជោគជ័យ

វគ្គបណ្ដុះបណ្ដាល ការសម្ដែងមតិដើម្បីឲ្យមានការផ្លាស់ប្ដូរ

ប្រព្រឹត្តទៅ______________________________,ថ្ងៃទី_____________________

ទីកន្លែង　　　　　　　　　　　　　　កាលបរិច្ឆេទ

អ្នកសម្របសម្រួលគ្រឹះបនារីកវៃឆ្លាត

ហត្ថលេខា:___________________________________

បុគ្គលិកអង្គការទស្សនៈពិភពលោក (ETIP)

ហត្ថលេខា:___________________________________



# មេរៀន២.៩ ៖
# ការធ្វើផែនការតស៊ូមតិ សម្រាប់ពេលអនាគត

## វត្ថុបំណង ៖

អ្នកចូលរួមនឹងធ្វើផែនការសម្រាប់ព្រឹត្តិការណ៍តស៊ូមតិនៅពេលអនាគត ។

## ពេលវេលា ៖

៩០ នាទី។

## សម្ភារៈ ៖

- ប័ណ្ណព័ត៌មាន "IS ២.៩ ៖ ការធ្វើផែនការតស៊ូមតិសម្រាប់ពេលអនាគត"
- ក្រដាសសរសេរអត្ថបទមួយសន្លឹក។

## រៀបចំ ៖

អ្នកត្រូវមានម៉ាស៊ីនថតចម្លងមួយសម្រាប់ប្រើប្រាស់នៅចុងបញ្ចប់នៃមេរៀននេះ។

រៀបចំពិធីមួយ ដើម្បីប្រារព្ធការបញ្ចប់យុទ្ធនាការចែកវិញ្ញាបនប័ត្រចូលរួមនិងអរគុណអ្នកចូលរួម។

## សូមស្វាគមន៍ ៖

ស្វាគមន៍អ្នកចូលរួមដែលមកចូលរួមរៀននៅក្នុងមេរៀនចុងក្រោយនៃការបណ្តុះបណ្តាលនេះ ។ លេងល្បែងបង្កភាពកក់ក្តៅ ដែលអាចដកស្រង់ចេញពីបញ្ជីសម្ភារសម្រាប់គាំទ្របាន ។

## ណែនាំប្រធានបទថ្ងៃនេះ ៖

ប្រសិនបើអ្នកចូលរួម មកចូលរួមរៀននៅក្នុងមេរៀននេះ ដែលជាមេរៀនមួយផ្នែកដែរនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលនោះសូមពន្យល់ថានៅក្នុងរយៈពេលធ្វើសិក្ខាសាលានេះ អ្នកចូលរួមនឹងទទួលបានជំនាញដែលអាចជួយពួកគេរៀបចំព្រឹត្តិការណ៍នៅក្នុងពេលអនាគតបាន ។ អង្គការទស្សនពិភពលោក សង្ឃឹមថាអ្នកចូលរួមនឹងត្រឡប់ទៅកាន់សហគមរបស់ពួកគេ ហើយអាចបណ្តុះបណ្តាលសមាជិកនៅក្លឹបយុវវ័យរបស់ពួកគេ នូវមេរៀនដែលមាននៅក្នុងកញ្ចប់ឧបករណ៍នេះដើម្បីឲ្យក្លឹបយុវវ័យនៅតាមមូលដ្ឋានអាចមានសមត្ថភាពរៀបចំនូវព្រឹត្តិការណ៍តស៊ូមតិដោយខ្លួនរបស់ពួកគេបាន។

ប្រសិនបើអ្នកចូលរួម បានចូលរួមរៀននៅក្នុងមេរៀន បញ្ចេញមតិរបស់អ្នក ដែលជាផ្នែកមួយនៃមេរៀនសម្រាប់ក្លឹបយុវវ័យនៅតាមសហគមរបស់ពួកគេ នោះសូមពន្យល់ថាមេរៀននេះ នឹងជួយ ពួកគេឲ្យចេះធ្វើផែនការយុទ្ធនាការតស៊ូមតិនៅពេលអនាគត ។

## សូមពិភាក្សាការគាំទ្រ និងការផ្តល់ថវិកាសម្រាប់ការរៀបចំ ៖

សូមពន្យល់ថាសំណួរទីមួយដែលអ្នកចូលរួមតែងតែសួរ នៅពេលដែលអ្នកគិតអំពីព្រឹត្តិការណ៍តស៊ូ មតិ គឺ "តើយើងត្រូវធ្វើដូចម្តេចដើម្បីបានទទួលការគាំទ្រ និងការផ្តល់ជាថវិការ?"

សូមពន្យល់ថាការឧបត្ថម្ភជាថវិការ និងការគាំទ្រ អាចទទួលបានពីកន្លែងជាច្រើន ដូចជាអង្គការមិនមែនរដ្ឋាភិបាល និងអង្គការផ្សេងៗទៀត ។

### ប្រភពដែលអាចផ្តល់ថវិការ៖អង្គការទស្សនពិភពលោក និងអង្គការផ្សេងៗទៀត

- សូមពន្យល់ថាគម្រោងបញ្ចប់ការជួញដូរមនុស្សរបស់អង្គការទស្សនពិភពលោកដំណើរការ រហូតដល់ឆ្នាំ ២០១៦។ ដូច្នេះប្រសិនបើអ្នកចូលរួមរៀបចំយុទ្ធនការតស៊ូមតិមុនពេលនោះ ពួកគេអាចដាក់ពាក្យស្នើសុំការគាំទ្រជាហិរញ្ញវត្ថុពីអង្គការទស្សនពិភពលោកបាន ។
- សូមពន្យល់ថានៅចុងបញ្ចប់នៃកម្មវិធីបញ្ចប់ការជួញដូរមនុស្ស នោះអង្គការទស្សនពិភព លោកនឹងណែនាំសមាជិកក្លឹបឲ្យស្គាល់អង្គការនានា ដែលអាចផ្តល់ជាថវិការដល់សកម្មភាពរបស់ពួកគេបាន ។

## ព្រឹត្តិការណ៍ក្រុមយុវវ័យ

ក្រុមយុវវ័យមួយចំនួន បានរៀបចំព្រឹត្តិការណ៍ដើម្បីរៃអង្គាសប្រាក់ ដើម្បីឧបត្ថម្ភសកម្មភាពតស៊ូមតិ។ ព្រឹត្តិការណ៍ទាំងនោះ មានដូចជា ៖

- ពិធីជប់លៀង ឬពិធីរាំរែក ដែលយកលុយពីអ្នកចូលរួម ។
- ថ្ងៃដែលអ្នកលាងរថយន្ត ឬសេវាផ្សេងៗទៀតដើម្បីរកលុយ ។

## នៅរកអ្នកឧបត្ថម្ភ

ពេលខ្លះ វាអាចទៅរួចដែរក្នុងការស្នើសុំក្រុមហ៊ុនអាជីវកម្ម ឲ្យបរិច្ចាកនូវថវិការរបស់ពួកគេដើម្បីគាំទ្រគម្រោង ។ ក្រុមហ៊ុនអាជីវកម្មទាំងនោះ អាចផ្តល់អំណោយជាថវិការ ឬជាសម្ភារ ។ ឧទាហរណ៍ អំណោយទាំងនោះ មានដូចជា ៖

- ហាងថតចម្លងដែលអាចបោះពុម្ពកូនសៀវភៅនាវិកវៃឆ្លាត ដោយឥតគិតថ្លៃ
- ហាង ដែលអាចផ្តល់ជូនអ្នកជាស្ករគ្រាប់នៅក្នុងតម្លៃថោកដូច្នេះអ្នកអាចលក់យកចំណេញ ដើម្បីប្រមូលថវិការសម្រាប់យុទ្ធនាការរបស់អ្នក ។
- ហាងកាហ្វេដែលអាចអនុញ្ញាតឲ្យអ្នករៀបចំពិធីជប់លៀងខារ៉ាអូខេ នៅក្នុងហាងរបស់ពួកគេ ហើយយកលុយសម្រាប់ការច្រៀងមួយបទៗ ដែលលុយប្រមូលបាននេះសម្រាប់ធ្វើ យុទ្ធនាការរបស់អ្នក ។

- អាជីវកម្មក្នុងមូលដ្ឋាន ដែលផ្តល់ថវិកាឲ្យអ្នកសម្រាប់យុទ្ធនាការរបស់អ្នក ប្រសិនបើអ្នក ពាក់អាវយឺតដែលមានឈ្មោះរបស់អាជីវកម្មនៅលើអាវយឺតនោះ ដោយបានបង្ហាញថាអាជីវកម្មនោះ យកចិត្តទុកដាក់ទៅលើបញ្ហាដែលក្រុមតស៊ូមតិរបស់អ្នក បានសម្រេចចិត្តជ្រើសរើសដោះស្រាយ ។

## រៀបចំផែនការសម្រាប់ពេលអនាគត

សុំឲ្យអ្នកចូលរួមបង្កើតជាក្រុមដែលមានសមាជិកចាប់ពី ៦-១០ នាក់ ។ សុំឲ្យអ្នកចូលរួមដែល មកពីក្លឹបយុវជនដដែលនោះ ចូលរួមបង្កើតក្រុមដដែលនោះដែរ ។

សូមពន្យល់ផងដែរថាអង្គការទស្សនពិភពលោក សង្ឃឹមថាអ្នកចូលរួមនឹងត្រឡប់ទៅកាន់ក្លឹបរបស់ ពួកគេវិញ ហើយដោយមានជំនួយពីបុគ្គលិករបស់អង្គការទស្សនពិភពលោក នោះពួកគេនឹងធ្វើការដឹកនាំក្លឹបយុវវ័យរបស់ពួកគេតាមរយៈដំណើរការរៀបចំនូវយុទ្ធនាការតស៊ូមតិរបស់ពួកគេ ។

ចែកឲ្យពួកគេនូវប័ណ្ណព័ត៌មាន "IS២.៩ ៖ ផែនការតស៊ូមតិនៅពេលអនាគត" និងសុំឲ្យសមាជិកក្រុមបំពេញឯកសារនោះ ។ សូមលើកទឹកចិត្តឲ្យមានការពិភាក្សាជាក្រុម នៅក្នុងពេលដែលសមាជិក ក្រុមកំពុងធ្វើកិច្ចការរបស់ពួកគេ ។

នៅពេលដែលក្រុម បានបញ្ចប់រួចរាល់ហើយ នោះសូមឲ្យពួកគេជួបជុំគ្នា រួចហើយឲ្យចែករំលែកនូវចម្លើយរបស់ពួកគេ ។

ជាចុងក្រោយ សូមសង្ខេបចម្លើយនៅលើក្រដាសផ្លីបឆាត ។ សុំឲ្យមានអ្នកស្ម័គ្រចិត្តម្នាក់ចម្លងចម្លើយ នៅលើក្រដាស letter ។ នៅចុងបញ្ចប់នៃមេរៀន សូមធ្វើការចម្លងនូវសេចក្តីសង្ខេបសម្រាប់អ្នកចូលរួមទាំងអស់ យកទៅសហគមរបស់ពួកគេវិញនៅពេលពួកគេត្រឡប់ទៅវិញ ។

## ការបិទបញ្ចប់

សូមអរគុណអ្នកចូលរួមចំពោះការប្តេជ្ញាចិត្ត និងការលះបង់របស់ពួកគេមកចូលរួមនៅក្នុងការធ្វើឲ្យគម្រៀងនេះដំណើរការ ។ សូមរំឭកពួកគេថាគម្រោងនេះ វាមានសារសំខាន់ប៉ុណ្ណាដើម្បីទប់ស្កាត់ការជួញដូរ និងការលើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ។ សូមលើកទឹកចិត្តអ្នកចូលរួម ឲ្យបន្តនូវការងារល្អរបស់ពួកគេតទៀតទៅពេលអនាគត ។

## សង្ខេបមេរៀន

- សង្ខេបអំពីភាពជោគជ័យ និងបញ្ហាប្រឈមដែលជួបប្រទះនៅក្នុងការធ្វើយុទ្ធនាការតស៊ូមតិ។
- សង្ខេបផែនការនៅពេលអនាគតណាមួយ ។

# IS ២.៩ ៖ ផែនការតស៊ូមតិនៅពេលអនាគត ៖

តើនរណាអាចជួយអ្នកក្នុងការរៀបចំនូវយុទ្ធនាការតស៊ូមតិនៅក្នុងសហគមរបស់អ្នកបាន?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

- តើមានយុវវ័យនៅក្នុងក្លឹបយុវវ័យរបស់អ្នក ដែលអាចមកចូលរួមបានដែរ ឬទេ ? តើជានរណា?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

- តើមានមនុស្សពេញវ័យ ឬអ្នកគាំទ្រដែលអាចជួយអ្នកបានដែរឬទេ? តើជានរណា?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

តើអ្នកអាចជួបជុំគ្នានៅទីកន្លែងណាដើម្បីរៀបចំយុទ្ធនាការតស៊ូមតិរបស់អ្នក?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

តើពេលណាដែលជាពេលវេលាដ៏ល្អបំផុត សម្រាប់សមាជិកនៅក្នុងសហគមរបស់អ្នកជួបជុំគ្នារៀបចំយុទ្ធនាការតស៊ូមតិ?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

តើអ្នកចាប់ផ្តើមធ្វើយុទ្ធនាការតស៊ូមតិរបស់អ្នកនៅពេលណា? តើអ្នកនឹងបញ្ចប់វានៅពេលណា?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

តើការគាំទ្រប្រភេទអ្វីខ្លះ ដែលអ្នកត្រូវការអង្គការទស្សនពិភពលោក ដើម្បីរៀបចំនូវយុទ្ធនាការតស៊ូមតិរបស់អ្នក?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

សូមសរសេរទុកនូវព័ត៌មានលំអិតសម្រាប់ទំនាក់ទំនង (លេខទូរស័ព្ទ ឬអាសយដ្ឋានអ៊ីមែល) របស់សមាជិកក្រុមទាំងអស់ និងសមាជិកបុគ្គលិករបស់អង្គការទស្សនពិភពលោក ដែលអាចជួយគាំទ្រ និងលើកទឹកចិត្តអ្នកបាន ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

**នៅពេលអ្នកត្រឡប់ទៅកាន់សហគមរបស់អ្នកវិញ នោះត្រូវចងចាំអនុវត្តតាមប័ណ្ណព័ត៌មាន □IS ២.១ខ ៖ ជំហាននានាឆ្ពោះទៅរកការរៀបចំនូវយុទ្ធនាការតស៊ូមតិ□ នៅពេលដែលអ្នករៀបចំយុទ្ធនាការតស៊ូមតិរបស់អ្នក ។**

# វាក្យស័ព្ទ

| | |
|---|---|
| **ការចាប់ពង្រត់**<br>**Abduct** | ការចាប់ពង្រត់ ឬការឃុំឃាំងដោយល្មើសច្បាប់នៅបុគ្គល ឬមនុស្សមួយ ក្រុមដែលតាមធម្មតាធ្វើឡើងក្នុងបំណងជំរិត ដើម្បីទាមទារយកប្រយោជន៍ខាងសេដ្ឋកិច្ច ឬនយោបាយពីជនរងគ្រោះ ដែលរងការចាប់ពង្រត់នោះ ឬភាគីទី៣។ តាមធម្មតាការចាប់ពង្រត់មានចែងក្នុងច្បាប់ព្រហ្មទណ្ឌរបស់រដ្ឋនិមួយៗ ទោះបីជាយ៉ាងណាក៏ដោយក៏ការចាប់ពង្រត់ខ្លះក៏ស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃច្បាប់អន្តរជាតិផងដែរ ( ដូចជាការប្លន់តាមសមុទ្រ ) |
| **មនុស្សធ្លាប់ស្គាល់ Acquaintance** | មនុស្សដែលអ្នកធ្លាប់ស្គាល់ និងបានជួបគ្នាពីមុនមក |
| **អ្នកតស៊ូមតិ**<br>**Advocate** | អ្នកគាំទ្រ ក្នុងការនិយាយ ឬធ្វើសកម្មភាពជំនួសអោយអ្នកណាម្នាក់ ឬសកម្មភាពអ្វីមួយ។ |
| **ការប្រាស្រ័យទាក់ទងផ្លាស់ប្តូរការប្រព្រឹត្ត**<br>**BCC (Behavior Change Communication)** | ការប្រាស្រ័យទាក់ទងផ្លាស់ប្តូរការប្រព្រឹត្ត / ទង្វើ / ឥរិយាបថ ជាការប្រើប្រាស់ការប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរឥរិយាបថ និង/ឬ អកប្បកិរិយារបស់អ្នកណាម្នាក់ (ឧទាហរណ៍ : ការធ្វើសកម្មភាព ដើម្បីផ្លាស់ប្តូរអកប្បកិរិយា ចំពោះការជួញដូរមនុស្ស) |
| **ឈ្មួញកណ្តាល មេខ្យល់ មេអណ្តើក**<br>**Broker** | ឈ្មួញកណ្តាលគឺជាភាគីមួយដែលធ្វើជាអន្តរការីរវាងអ្នកទិញ និងអ្នកលក់។ |
| **ពលកម្មកុមារក្នុងទាសភាព បំណុល**<br>**Bonded child labour** | កុមារដែលធ្វើការដោះបំណុល ដោយសារខ្លួនគាត់ ឬសមាជិកគ្រួសារ ឬធ្វើការដើម្បីកាតព្វកិច្ចសង្គម (ឧទាហរណ៍: កត្តាសង្គម និង ការប្រព្រឹត្តតាមពូជសាសន៍ និងសាសនា) ដោយគ្មានការព្រមព្រៀង ពីកុមារ ក្រោមល័ក្ខខ័ណ្ឌដែលបំបិទសិទ្ធិសេរីភាព ក្នុងការអភិវឌ្ឍន៍ ការអោយតំលៃទៅលើរាងកាយ និងទម្រង់នៃការរំលោភបំពានផ្សេងទៀត និងបដិសេធសិទ្ធិជាមូលដ្ឋានរបស់ពួកគាត់។ |
| **យុទ្ធនាការ**<br>**Campaign** | ការអនុវត្ត និងសកម្មភាពផ្សេងៗគ្នាដែលបង្កើតឡើងដើម្បីសម្រេច បាននូវគោលបំណងរួមមួយ។ |
| **សិទ្ធិកុមារ**<br>**Child rights** | សិទ្ធមនុស្សរបស់កុមារ/យុវវ័យ ដែលផ្តោតទៅលើការយកចិត្តទុក ដាក់ទៅលើការការពារ និងថែទាំជាពិសេស ដែលរួមមានដូចជាសិទ្ធិ ទទួលបានការការពារ ការអភិវឌ្ឍន៍ ការចូលរួម និងការជួយសង្គ្រោះ។ |
| **ប្រជាពលរដ្ឋ Citizen** | មនុស្សម្នាក់ដែលមានសិទ្ធិ និងកាតព្វកិច្ចនៅក្នុងរដ្ឋមួយ |
| **ចាប់បង្ខំ/បង្ខិតបង្ខំ Coerce** | បង្ខំ ឬគំរាមកំហែងឲ្យបុគ្គលណាម្នាក់ធ្វើអ្វីមួយ |
| **ការសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋ មន្ត្រីប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ COMMIT** | ការសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងការជួញដូរ មនុស្សនៅមហាអនុតំបន់មេគង្គៈ ក្រុមការងារប្រឆាំងការជួញដូរមនុស្សដែលអនុវត្តដោយរដ្ឋាភិបាលនៃ៦ប្រទេសនៅក្នុងមហា អនុតំបន់មេគង្គ |
| **អនុសញ្ញា**<br>**Convention** | គឺជាព្រមព្រៀងជាលក្ខណៈអន្តរជាតិ ទៅលើប្រធានបទមួយ។ ឧទាហរណ៍: អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីអំពីសិទ្ធិកុមារ ។ |
| **ការកេងប្រវ័ញ្ចលើអាជីវកម្មផ្លូវភេទរបស់កុមារ CSEC (Commercial Sexual Exploitation of children)** | ការកេងប្រវ័ញ្ចលើអាជីវកម្មផ្លូវភេទរបស់កុមារ |
| **ប្រទេសគោលដៅ**<br>**Destination country** | ប្រទេសដែលមនុស្សផ្លាស់ទៅក្នុងគោលបំណងស្វែងរកការងារធ្វើ ។ |
| **បញ្ឈប់ការជួញដូរមនុស្ស ETIP** | បញ្ឈប់ការជួញដូរមនុស្ស |

1 South Asian Task Force on Bonded Child Labour.

| | |
|---|---|
| **ការកេងប្រវ័ញ្ច**<br>**Exploitation** | ការប្រើប្រាស់អ្នកណាម្នាក់ដើម្បីផលប្រយោជន៍ផ្សេងៗ។ ការកេងយកប្រយោជន៍ដោយទម្រង់រំលោភបំពានឃោរឃៅ លើបុគ្គលណាម្នាក់ដើម្បីអត្ថប្រយោជន៍បុគ្គល។ ដូចជាការបង្ខំអោយកុមារធ្វើការដោះបំណុលឪពុកម្តាយ ឬបង្ខំឲ្យកុមារធ្វើការ ( បេស្យាចារកុមារ ) ឬធ្វើឲ្យបុគ្គលណាម្នាក់បាត់បង់ផលប្រយោជន៍។ |
| **មហាអនុតំបន់មេគង្គ**<br>**GMSGreater Mekong Sub-Region** | មហាអនុតំបន់មេគង្គ ប្រទេសមហាអនុតំបន់មេគង្គទាំង៦ មានដូចជាកម្ពុជា ចិន ឡាវ មីយ៉ាន់មា ថៃ និងវៀតណាម |
| **ផ្តល់ជម្រក (ខុសច្បាប់)** **Harbour** | ផ្តល់ជម្រកឲ្យអ្នកណាម្នាក់ ឬលាក់បុគ្គលណាម្នាក់ក្នុងបំណងប្រព្រឹត្តល្មើសច្បាប់ |
| **គ្រោះថ្នាក់** **Hazardous** | គ្រោះថ្នាក់/គ្រោះអាសន្ន |
| **សិទ្ធិមនុស្ស**<br>**Human rights** | គឺជាសិទ្ធិរបស់បុគ្គលម្នាក់ៗ ពីព្រោះពួកគេជាមនុស្ស ដោយរួមមានដូចជាសិទ្ធិទទួលបានសេរីភាពជាមូលដ្ឋាន និងសិទ្ធិមានអ្វីដែលពួកគេចង់បានដើម្បីចិញ្ចឹមជីវិត សិទ្ធិអភិវឌ្ឍន៍ និងសិទ្ធិចូលរួមនៅក្នុងសង្គម ។ មនុស្សពេញវ័យ និងយុវវ័យមានសិទ្ធិដូចគ្នា ។ |
| **ការរត់ពន្ធមនុស្ស** | គឺជាការសម្រួលដល់ការដឹកជញ្ជូន ឬការចូលដោយខុសច្បាប់របស់មនុស្សម្នាក់/ច្រើននាក់ដោយឆ្លងកាត់ ព្រំដែនអន្តរជាតិ នៅក្នុងទម្រង់ជាការរំលោភបំពានច្បាប់របស់ប្រទេស។ |
| **អង្គការការងារអន្តរជាតិ**<br>**ILO (International Labour Organization)** | អង្គការការងារអន្តរជាតិ ជាផ្នែកមួយនៃអង្គការសហប្រជាជាតិដែលធ្វើទៅលើបញ្ហាការងារ |
| **ច្បាប់អន្តរជាតិ**<br>**Innternational Law** | ច្បាប់អន្តរជាតិ ជាច្បាប់ទាំងឡាយដែលប្រទេសជាច្រើនបានចុះហត្ថលេខា និងយល់ព្រមអនុវត្ត |
| **តារាងព័ត៌មាន IS(Information Sheet)** | តារាងព័ត៌មាន |
| **LI CPIPP(Child Protection Incident Preparedness Plan)** | ផែនការត្រៀមទុកចំពោះឧបទ្ទវហេតុក្នុងការការពារកុមារកម្រិត១ |
| **ចំណាកស្រុកដោយគ្មានឯកសារស្របច្បាប់**<br>**Migration - undocumented** | នាពលេដលៃបុគ្គលម្នាក់បំលាស់ទីទាប្រទេសផ្សេងទៀតដាយគ្មានឯកសារស្របច្បាប់ និងឆ្លងកាត់ព្រំដែនដោយគ្មានលិខិតអនុញ្ញាតិត្រឹមត្រូវពីប្រទេសនោះ។ |
| **អនុសារណៈយោគយល់គ្នា**<br>**MoU(Memoradom of Understanding)** | អនុសារណៈយោគយល់គ្នាលើកិច្ចព្រមព្រៀងរវាងប្រទេសពីរ ឬប្រទេស/ក្រុម/អង្គការច្រើន |
| **អង្គការមិនមែនរដ្ឋាភិបាល**<br>**NGO(Non-Government Organization)** | អង្គការមិនមែនរដ្ឋាភិបាល |
| **ពិធីសារប៉ាឡឺម៉ូ**<br>**Protocol to Prevent, Suppress and Punish Trafficking in Persons Especially Women and Children, Suppementing the United Nations Convention against Transnational Organization Crime** | គឺជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលការពារ និងបញ្ឈប់ការជួញដូរមនុស្ស និងជួយប្រទេសដទៃទៀតដោយធ្វើការសហការគ្នា ក្នុងការបញ្ឈប់ការជួញដូរមនុស្ស។ វារួមបញ្ចូលទាំងគំនិតដែលបង្ហាញអំពីសកម្មភាព ដែលប្រទេសផ្សេងៗទៀតអាចយកទៅប្រើប្រាស់ ដើម្បីបញ្ឈប់អ្នកជួញដូរ និងរបៀបជួយជនរងគ្រោះ។ |
| **ផ្តល់សច្ចាប័ន**<br>**Ratify** | ការចុះហត្ថលេខាលើច្បាប់មួយ ដើម្បីនិយាយថាប្រទេសរបស់អ្នកនឹងទទួលយកមកអនុវត្តតាមច្បាប់នោះ និងអោយប្រាកដថាប្រជាពលរដ្ឋទាំងអស់គោរពច្បាប់នោះ។ |

2 មជ្ឈមណ្ឌលស្រាវជ្រាវ Innocenti របស់អង្គការយូនីសែហ្វ (UNICEF), Handbook on the Optional on the Sale of Children, Child Prostitution and Child Pomography (Florence, Italy; UNICEF. February 2009), 6. Available at www.unicef-irc.org/publicatios/pdf/optional_protocal_eng.pdf.

| | |
|---|---|
| **អ្នកជ្រើសរើស**<br>**Ricruter** | បុគ្គលម្នាក់ដែលត្រូវបានគេជួលឲ្យស្វែងរកមនុស្ស ដើម្បីធ្វើការសម្រាប់អាជីវកម្មរបស់គេ |
| **ភ្នាក់ងារជ្រើសរើសពលករ**<br>**Labour Recruitment Agency** | ក្រុមមនុស្សដែលក្រុមហ៊ុនបានជួលឲ្យស្វែងរកកម្លាំងពលរកម្មដើម្បីធ្វើការឲ្យម្ចាស់អាជីវកម្មជាច្រើន |
| **ចុះហត្ថលេខា**<br>**Sign** | អនុម័ត ឬយល់ព្រមទៅលើខ្លឹមសារដែលបានរ៉ាយរ៉ាប់ក្នុងឯកសារមួយហើយ យើងត្រូវចុះហត្ថលេខា និងសរសេរឈ្មោះនៅខាងចុងសន្លឹកនៃឯកសារ |
| **ទាសករ**<br>**Slave** | បុគ្គលម្នាក់ដែលត្រូវបានគេបង្ខំឲ្យធ្វើការដោយគ្មានជំរើស ឬដោយមិនបានទទួលប្រាក់កំរៃឬបុគ្គលដែលកើតមកក្នុងត្រកូលទាសករត្រូវគេបង្ខំឲ្យរស់នៅក្នុងទាសភាព ឬត្រូវបានគេលក់ក្នុងទាសភាព |
| **រើសអើងពីសង្គម**<br>**Stigmatise** | រើសអើង ឬមើលងាយបុគ្គលម្នាក់ ឬច្រើននាក់ពីព្រោះតែពួកគាត់ជាក្រុមដែលសង្គមរើសអើង ឬពីព្រោះតែពួកគាត់ជាបុគ្គល/ក្រុមដែលសង្គមមិនរាប់រក។ |
| **យុទ្ធសាស្រ្ត**<br>**Strategy** | ផែនការនៃវិធីធ្វើអ្វីមួយ |
| **ទស្សនិកជន/ទស្សនិកជនគោលដៅ**<br>**Target/target audience** | ក្រុមមនុស្សដែលយុទ្ធនាការតស៊ូមតិមានបំណងផ្តោតទៅលើ |
| **ការជួញដូរកុមារ/យុវជន**<br>**Trafficking (Child)** | ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការឃាត់ទុក ឬការផ្តល់ជម្រក ក្នុងគោលបំណងកេងប្រវ័ញ្ច នឹងត្រូវបានចាត់ទុកថាជាការជួញដូរ ទោះបីជាមិនមានការពាក់ព័ន្ធនិងនិយមន័យដែលបានកំណត់ នៅក្នុងការផ្តល់និយមន័យស្តីពីកាជួញដូរមនុស្សយ៉ាងណាក៏ដោយ ឬក៏ដោយមិនគិតពីរបៀបដែលវាកើតឡើង ពោលគឺមិនថាជាការស្ម័គ្រចិត្ត ឬជាការបង្ខិតបង្ខំនោះឡើយ[1] |
| **បញ្ជូន**<br>**Transfer** | បំលាស់ទីពីកន្លែងមួយទៅកន្លែងមួយ |
| **អង្គការសហប្រជាជាតិ**<br>**UN** | អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើងបន្ទាប់ពីសង្គ្រាមលោកលើកទី២ ក្នុងគោលបំណងផ្តល់នូវយន្តការសម្រាប់ប្រទេសស្ទើរតែទាំងអស់ នៅក្នុងពិភពលោកដើម្បីពិភាក្សានិងដោះស្រាយបញ្ហាដែលប៉ះពាល់និងជះឥទ្ធិពលដល់ប្រទេសទាំងនោះ (គ្រប់សមាជិកទាំងអស់ ត្រូវបានអញ្ជើញឲ្យចូលក្នុងអង្គមហាសន្និបាទអង្គការសហប្រជាជាតិ) ។ ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែមអំពីអង្គការសហប្រជាជាតិ សូមទៅគេហទំព័រ: http://www.un.org |
| **អនុសញ្ញាស្តីពីសិទ្ធិកុមារ**<br>**UNCRC** | គឺជាច្បាប់អន្តរជាតិ ដែលការពារកុមារ/យុវវ័យ ។ |
| **ពលករឥតជំនាញ**<br>**Unskilled Labour** | ការងារដែលមិនតម្រូវឲ្យមានការបណ្តុះបណ្តាល ឬការអប់រំជាលក្ខណៈផ្លូវការនោះទេ។ |

# Appendix A

## WVI Child Protection Policy

**(ថ្ងៃទី២៦ ខែមករា ឆ្នាំ ២០០៧)**

**គោលបំណង :** ដើម្បីបង្កើត និងរៀបចំគម្រោងគោលនយោបាយអង្គការទស្សនៈពិភពលោកអន្តរជាតិស្តីពីការទទួលខុសត្រូវរបស់ខ្លួន និងប្តេជ្ញាចិត្តក្នុងការការពារគ្រួសារ និងកុមារ ដែលរងគ្រោះ។ ដើម្បីថែរក្សារកម្លាំងការងារ ដែលផ្តោតដល់សុខមាលភាពកុមារជុំវិញពិភពលោក។

**ទំហំ :** គោលនយោបាយនេះអនុវត្តន៍ទៅលើគ្រប់បុគ្គលិករបស់អង្គការសហប្រជាជាតិ (គ្រប់ប្រភេទបុគ្គលិកទាំងអស់ រួមបញ្ចូលដោយគ្មានការកំណត់ថា ជាការងារពេញម៉ោង ក្រៅម៉ោង រយៈពេលខ្លី បណ្តោះអាសន្ន និងនិយោជិតជាប់កិច្ចសន្យា) អ្នកម៉ៅការឯករាជ្យ (ទីប្រឹក្សា) បុគ្គលិកសាកល្បង និងស្ម័គ្រចិត្តនៅការិយាល័យជាដៃគូរ។

**គោលនយោបាយ :** គោលនយោបាយនេះ គឺអាស្រ័យលើគោលនយោបាយក្រុមប្រឹក្សាភិបាលនៃអង្គការសហប្រជាជាតិ ដែលមានចំណងជើងថា: គោលនយោបាយជាដៃគូរបស់អង្គការសហប្រជាជាតិស្តីពីការការពារកុមារ អនុម័តនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០០០។

**ចំពោះគោលបំណងនៃគោលនយោបាយនេះ និងការងាររបស់អង្គទស្សនៈពិភពលោក គឺជាការផ្តល់និយមន័យលើកុមារថាជាមនុស្សដែលមានអាយុក្រោម ១៨ឆ្នាំ។**

អង្គការទស្សនៈពិភពលោកអន្តរជាតិ គឺជាដៃគូអន្តរជាតិ ដែលអនុវត្តន៍ផ្តោតទៅលើសុខមាលភាពកុមារជុំវិញ ពិភពលោក។ អង្គការនេះនឹងធ្វើការប្រឆាំងគ្រប់ទម្រង់ទាំងអស់នៃការកេងប្រវ័ញ្ចនិងការរំលោភបំពានលើកុមារ។ នរណាម្នាក់ដែលមានចំនេះដឹងខ្លាំងទៅលើបញ្ហាការពារកុមារ ដែលមានការពាក់ព័ន្ធនិងអង្គការទស្សនៈពិភពលោក សូមទំនាក់ទំនងជាបន្ទាន់មកការិយាល័យជាដៃគូនាយកធនធានមនុស្ស ដែលនឹងធ្វើការជាមួយអ្នកសម្របសម្រួលការការពារកុមារ។

## ១. បង្កើនការយល់ដឹង និងការទទួលខុសត្រូវចំពោះការការពារកុមារ

អង្គការទស្សនៈពិភពលោក នឹងបង្ហាញពីវគ្គ/សិក្ខាសាលាបណ្តុះបណ្តាលតម្រង់ផ្លូវមានកាលកំណត់សម្រាប់បុគ្គលិកការិយាល័យជាដៃគូទាំងអស់ ដើម្បីលើកកម្ពស់ការយល់ដឹង ទៅលើបញ្ហាពាក់ព័ន្ធនិងការការពារកុមារ ពីកេងប្រវ័ញ្ច។ ការបណ្តុះបណ្តាលនេះ នឹងណែនាំដល់បុគ្គលិកគ្រប់ប្រភេទទាំងអស់។ ការបណ្តុះបណ្តាលនេះនឹងរួមបញ្ចូល: ការយល់ដឹង និងការចង្អុលបង្ហាញពីការរំលោភបំពានលើកុមារ ការចាត់នីតិវិធីផ្សេងៗប្រសិនបើមានការរំលោភបំពាន ដែលត្រូវបានគេចោទប្រកាន់ ឬត្រូវបានសង្ស័យ និងសុវត្ថិភាពព័ត៌មាន។ ការិយាល័យនាយកធនធានមនុស្សជាដៃគូស្របច្បាប់ នឹងធ្វើការសហការជាមួយអ្នកសម្របសម្រួលដល់ការការពារកុមារ ដើម្បីធ្វើត្រួតពិនិត្យឡើងវិញនូវគោលនយោបាយ និងបន្តតាមដាន និងពិនិត្យទៅលើវគ្គបណ្តុះបណ្តាលស្តីពីតម្រូវការជាមូលដ្ឋាន។

គ្រប់និយោជិតរបស់អង្គការទស្សនៈពិភពលោក ដូចជាបុគ្គលិកស្ម័គ្រចិត្ត បុគ្គលិកសាកល្បង អ្នកប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សា ដែលពាក់ព័ន្ធនិងការិយាល័យជាដៃគូរ/ការិយាល័យអន្តរជាតិរបស់អង្គការទស្សនៈពិភពលោក ត្រូវបានស្នើសុំឲ្យចុះហត្ថលេខាលើការប្តេជ្ញាគាំទ្រគោលនយោបាយការពារកុមារ

និងការចូលរួមវគ្គបណ្តុះបណ្តាល។ សំណុះបែបបទដែលបានបំពេញចប់សព្វគ្រប់ នឹងត្រូវបញ្ជូនត្រឡប់ទីស្នាក់ការអង្គការទស្សនៈពិភពលោកអន្តរជាតិ។

## ២. សេចក្តីណែនាំស្តីពីធីសារអាកប្បកិរិយារបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ

គ្រប់និយោជិក បេក្ខជន បុគ្គលិកស្ម័គ្រចិត្ត បុគ្គលិកសាកល្បង អ្នកប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សារបស់អង្គការទស្សនៈពិភពលោកអន្តរជាតិទាំងអស់ ត្រូវគោរពតាមសេចក្តីណែនាំ ស្តីអាកប្បកិរិយានេះ។

ក. ប្រព្រឹត្តទៅកាន់ក្មេងៗទាំងអស់ ដោយការគោរព និងភាពថ្លៃថ្នូ (ស្តាប់)

ខ. រាល់ចូលទស្សនៈកិច្ច និងបុគ្គលិកស្ម័គ្រ ដែលចូលទៅក្នុងគម្រោងរបស់អង្គការទស្សនៈពិភពលោក ត្រូវតែទៅជាមួយបុគ្គលិកដែលបានចាត់តាំងរបស់អង្គការ។

គ. ត្រូវចេះទទួលយកបទដ្ឋានក្នុងស្រុក ឬតាមតំបន់ ដូចជាភាសារ ការសន្ទនា ភាពស្និទស្នាល និងការពិនិត្យកត់សម្គាល់ពួកគេ ។

ឃ. បញ្ឈប់ការធ្វើអន្តរកម្មជាមួយក្មេង ប្រសិនបើក្មេងនោះនិយាយថាឈប់ ឬក៏ក្មេងនោះមានអារម្មណ៍ មិនល្អជាមួយនិងការធ្វើអន្តរកម្មនេះ ។

ង. ត្រូវសុំការអនុញ្ញាតិពីកុមារ និងឪពុកម្តាយ/អាណាព្យាបាលជាមុន ប្រសិនបើអ្នកចង់ថតរូប ជាមួយគេ

ច. មិនត្រូវប៉ះពាល់ទីកន្លែងភេទនៅលើរាងកាយ និង/ឬ រួមភេទជាមួយកុមារ។

ឆ. មិនត្រូវបង្ហាញសម្ភារៈផ្លូវភេទទៅកាន់ពួកគេ ឬ រំលោភបំពានលើពួកគេតាមរយៈសកម្មភាពផ្លូវភេទមិនផ្ទាល់។

ជ. ត្រូវនៅជាមួយមនុស្សពេញវ័យផ្សេងទៀត ពេលនៅជាមួយកុមារ ពោលគឺមិនត្រូវចំណាយពេលតែឯងជាមួយកុមារ។ នេះជាការការពារដល់កុមារ និងខ្លួនអ្នកផ្ទាល់ពីការចោទប្រកាន់ផ្សេងៗ។

ឈ. បុគ្គលិកអង្គការទស្សនៈពិភពលោក មិនត្រូវជួលកុមារ ដូចជាការជួយផ្តល់ទីកន្លែងស្នាក់នៅ ឬរក្សាកុមារក្នុងគោលបំណងកេងប្រវ័ញ្ចកម្លាំងពលកម្ម។ កុមារមានសិទ្ធិទទួលបានការអប់រំ និងលេងកំសាន្ត។

ញ. មិនត្រូវទះកំផ្លៀង ឬវាយដំកុមារ ឬ ការរំលោភបំពានរាងកាយកុមារ។

ដ. មិនត្រូវរំលោភបំពានលើកុមារ តាមរយៈចិត្តសាស្ត្រ និងពាក្យសម្តី។

ឋ. មនុស្សពេញវ័យ ត្រូវទទួលខុសត្រូវចំពោះអាកប្បកិរិយារបស់ពួកគេ ជាមួយកុមារ ប្រសិនបើកុមារបញ្ចេញអាការៈគួរឲ្យស្រឡាញ់។

## ៣. បទដ្ឋានរបស់អង្គការទស្សនៈពិភពលោក ស្តីពីការការពារ អ្នកទទួលផលប្រយោជន៍

គោលការណ៍អាកប្បកិរិយាផ្លូវភេទ ខាងក្រោមបង្ហាញពីបទដ្ឋានអន្តរជាតិស្តីពីការការពារផលប្រយោជន៍អ្នកទទួលផល (មនុស្សពេញវ័យ និង/ឬ ក្មេង) ហើយត្រូវបានចាត់ចូលទៅក្នុងផ្នែកទាំងមូលនៃគោលនយោបាយនេះ។

ក.ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានដោយបុគ្គលិកអង្គការទស្សនៈពិភពលោក ឬបុគ្គលិកមនុស្សធម៌ណាមួយ ទៅលើអ្នកទទួលផលប្រយោជន៍ (មនុស្សពេញវ័យ ឬកុមារ) តាមរយៈការប្រព្រឹត្តមិនត្រឹមត្រូវ ដែលជាមូលហេតុសម្រាប់ការបញ្ឈប់ពីការងារ។

ខ. សកម្មភាពផ្លូវភេទ រវាងបុគ្គលិកអង្គការទស្សនៈពិភពលោក ឬ បុគ្គលិកមនុស្សធម៌ និងកុមារ (អាយុក្រោម ១៨ឆ្នាំ) ឬ អ្នកទទួលផលប្រយោជន៍ណាមួយ គឺត្រូវបានហាមឃាត់យ៉ាងតឹងរឹង ដោយមិនគិតអាយុ ឬ អាយុដែលក្នុងស្រុកទទួលយក។ នៅក្នុងករណីនេះ កំហុសដែលចាត់ទុកដោយ អង្គការទស្សនៈពិភពលោកអន្តរជាតិ ឬអង្គការមនុស្សធម៌ ពាក់ព័ន្ធនឹងអាយុរបស់កុមារ គឺមិនមែនជាការការពារទប់ទល់នឹងវិធានការកែប្រែ ឬការបញ្ឈប់ពីការងារនោះទេ។

គ. ការដោះដូរជាលុយ ការងារ ទំនិញ ឬសេវាកម្ម សម្រាប់សេវាកម្មផ្លូវភេទ (ប្លុករួមការលំអៀងទៅរកផ្លូវភេទ ឬ ក្នុងទម្រង់ជាការបង្អាប់ ការបន្ទាបបន្ថោក ឬការកេងប្រវ័ញ្ចដទៃទៀត) គឺត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង ហើយនេះជាមូលហេតុ សម្រាប់ការបញ្ឈប់ពីការងារ រាប់បញ្ចូលទាំងការផ្លាស់ប្តូជំនួយគ្នាដែលបានជាប់ជម្លាក់នឹងអ្នកទទួលផលផ្សេងទៀតផងដែរ ។

ឃ. ទំនាក់ទំនងផ្លូវភេទ រវាងបុគ្គលិកអង្គការទស្សនៈពិភពលោក ឬ បុគ្គលិកមនុស្សធម៌ និង អ្នកទទួលផលប្រយោជន៍ណាមួយ គឺមិនអាចទទួលយក និងមិនអាចអត់ឱនឲ្យបាននោះទេ នឹងមិនត្រូវបានលើកលែងឲ្យទេ ដោយសារតែវាផ្អែកលើថាមភាពអណាចមិនស្មើគ្នាដែលប្រកាន់ខ្ជាប់មិនបោះបង់ចោល។ ការទំនាក់ទំនងបែបនេះ ធ្វើឲ្យ ប៉ះពាល់ដល់ កិត្តិយស និងភាពថ្លៃថ្នូនៃបុគ្គលិកជំនួយមនុស្សធម៌ របស់អង្គការទស្សនៈពិភពលោក។

ង. ទីកន្លែងដែលបុគ្គលិកអង្គការទស្សនៈពិភពលោក ឬ បុគ្គលិកមនុស្សធម៌ បង្កឲ្យមានការព្រួយបារម្ភ ឬ ការសង្ស័យណាមួយ ពាក់ព័ន្ធនិងការរំលោភបំពានផ្លូវភេទ ឬការកេងប្រវ័ញ្ចផ្លូវភេទ ដោយបុគ្គលិកគ្នាឯង មិនថាជាភ្នាក់ងារដូចគ្នា ឬ មិនមែនក៏ដោយ ក៏នាង/គាត់ ត្រូវតែរាយការណ៍ អំពីបញ្ហានោះ តាមរយៈយន្តការរាយការណ៍របស់អង្គការទស្សនៈពិភពលោក។

ច. រាល់បុគ្គលិកអង្គការទស្សនៈពិភពលោក ត្រូវមានកាតព្វកិច្ច បង្កើត និងថែរក្សាបរិយាកាស ដែលការពារការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ និងជំរុញឲ្យមានការអនុវត្តន៍ក្រមសីលធម៌របស់អង្គការទស្សនៈពិភពលោកឲ្យបានល្អ។ អ្នកគ្រប់គ្រងរបស់អង្គការទស្សនៈពិភពលោក គ្រប់លំដាប់ជាន់ថ្នាក់ មានការទទួលខុសត្រូវជាពិសេស ក្នុងការគាំទ្រ និងអភិវឌ្ឍន៍ប្រព័ន្ធថែរក្សានូវបរិយាកាសនេះ។

## ៤. ទស្សនៈកិច្ចគម្រោងរបស់អង្គការទស្សនៈពិភពលោក

បុគ្គលិក សមាជិកក្រុមប្រឹក្សា ឬអ្នកចូលទស្សនៈកិច្ច របស់អង្គការទស្សនៈពិភពលោក ដែលនឹងមកទស្សនៈកិច្ចគម្រោងរបស់អង្គការ ត្រូវតែត្រូវបានផ្តល់ដំបូន្មានស្តីពីពិធីសារអាកប្បកិរិយាក្នុងស្រុក ដែលរួមមានដូចជា:

ក. ការមកទស្សនៈកិច្ចគម្រោងរបស់អង្គការទស្សនៈពិភពលោក ត្រូវមានការរៀបចំ និងយល់ព្រមជាមុន។

ខ. នៅពេលបុគ្គលិករបស់អង្គការ ទស្សនៈពិភពលោកមកធ្វើការទស្សនៈកិច្ច (ឧបត្ថម្ភ, ផ្តល់ជំនួយ) មកកាន់គម្រោង អ្នកមកទស្សនៈកិច្ច ត្រូវមកជាមួយបុគ្គលិករបស់អង្គការរៀងរាល់ពេល។

គ. អ្នកមកទស្សនៈកិច្ចដែលពុំមានការផ្តល់ដំណឹង ឬ គម្រោងជាមុន មិនត្រូវបានអនុញ្ញាតិឲ្យចូលទៅនោះទេ។

ឃ. អង្គការទស្សនៈពិភពលោកអន្តរជាតិ មិនសម្របសម្រួលចំពោះការសុំជួបផ្ទាល់ពីសំណាក់កុមារទៅកាន់ម្ចាស់ជំនួយ អ្នកផ្តល់ការគាំទ្រ ឬមូលដ្ឋាននៅក្នុងប្រទេសឡើយ។

ង. អង្គការទស្សនៈពិភពលោកអន្តរជាតិ មិនជួយសម្រួលដំការសុំកូនទេ។

ច. បុគ្គលិកអង្គការទស្សនៈពិភពលោកអន្តរជាតិ មិនត្រូវស្នាក់នៅរំលងថ្ងៃ តែឯងជាមួយក្មេងដែលមិនមានការជាប់ពាក់ព័ន្ធ មិនថានៅក្នុងផ្ទះរបស់បុគ្គលិក ឬ ទីណានោះទេ។

ឆ. បើទោះបីជាបាគួរចាត់ទុកជាករណីលើកលែងច្រើនជាងក្រិត្យក្រមក៏ដោយ ក៏ក្នុងកាលៈទេសៈខ្លះផងដែរដែលនៅពេលវាអាចមានភាពសម្របសម្រាប់បុគ្គលិករបស់អង្គការទស្សនៈពិភពលោកអន្តរជាតិក្នុងការចំណាយពេលតែឯងនៅជាមួយនឹងកុមារតែពីរនាក់។ បុគ្គលិករបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ត្រូវតែជូនដំណឹងដល់អ្នកត្រួតពិនិត្យសមស្របរបស់ខ្លួនអំពីការចំណាយពេលតែពីរនាក់នៅជាមួយកុមារបែបនេះនៅក្នុងស្ថានភាពដែលមិនមានការត្រួតពិនិត្យណាមួយ ដោយមានការអនុញ្ញាតិជាលាយលក្ខណ៍អក្សរពីឪពុកម្តាយ ឬអណាព្យាបាលរបស់កុមារ។

ជ. មនុស្សពេញវ័យ២ ឬច្រើននាក់ ត្រូវតែត្រួតពិនិត្យរាល់សកម្មភាព នៅកន្លែងដែលគម្រោងមានការពាក់ព័ន្ធនិងក្មេងៗ។

## ៥. ការទំនាក់ទំនងអំពីក្មេងៗ

ក. រាល់ការទំនាក់ទំនងដោយចក្ខុ អំពីក្មេងៗ ត្រូវតែប្រើប្រាស់រូបភាពដែលត្រឹមត្រូវ និងដោយក្តីគោរព។ មិនត្រូវបង្ហាញដល់ពួកគេ ដូចពួកគេជាជនរងគ្រោះនោះទេ។ កុមារគួរមានសម្លៀកបំពាក់សមស្រប និងដើម្បីជៀសវាងមិនមានការរំលោភ ដែលផ្តោតលើផ្លូវភេទ។ ភាសាដែលមានបង្កប់ន័យទំនាក់ទំនងជាអំណាចត្រូវតែចៀសវាង។

ខ. គេហទំព័ររបស់អង្គការទស្សនៈពិភពលោក នឹងមិនប្រើប្រាស់រូបភាពដែលបានស្គែន របស់ក្មេងៗ ដោយមិនភាពផ្លូវការ ការអនុញ្ញាតិជាលាយល័ក្សអក្សរ របស់ការិយាល័យជាតិ ដែលទទួលខុសត្រូវលើគម្រោង និងលើក្រុមគ្រួសារ/សហគមន៍ របស់ក្មេង។

គ. ព័ត៌មានផ្ទាល់ខ្លួនរបស់ក្មេង ដែលអាចយកមកប្រើប្រាស់ ដើម្បីបង្ហាញពីទីកន្លែង របស់ក្មេងនៅក្នុងប្រទេស មិនត្រូវបានយកមកប្រើប្រាស់នៅក្នុងគេហទំព័ររបស់អង្គការទស្សនៈពិភពលោកទេ ឬក៏នៅក្នុងទម្រង់នៃការទំនាក់ទំនងអំពីក្មេងដទៃទៀត។

ឃ. អង្គការទស្សនៈពិភពលោកអន្តរជាតិ ទាមទារឲ្យ ចំពោះការទំនាក់ទនងជាមួយប្រព័ន្ធផ្សព្វផ្សាយស្តីពីការបញ្ហានៃការការពារកុមារ ត្រូវមានការសម្របសម្រួលដោយ លោកអនុប្រធាន ការទំនាក់ទំនងជាមួយអ្នកសម្របសម្រួលការពារកុមារ របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ។

ង. ការប្រើប្រាស់អ៊ីនធឺណែតខុសគោលដៅ ដែលផ្តល់ដោយអង្គការ ត្រូវបានហាមឃាត់។ ការប្រើប្រាស់ខុសគោលដៅ កើតមានដូចជាការបើកគេហទំព័រ ការដោនឡូត និងបញ្ជូនព័ត៌មាន និងដទៃទៀតដូចជាការដំណើរការ ឬចែកចាយព័ត៌មាន ដែលមានការជាប់ពាក់ព័ន្ធនិងក្មេង ដែលមានដូចជារូបអាសអាភាស ការបរិហាកេរ្តិ៍ ការនិយាយយាយី ការគំរាមគំហែង ពាក្យពាក់ព័ន្ធនិងផ្លូវភេទ ឬ ពូជសាសន៍ ឬ រឿងដទៃទៀតដែលមានលក្ខណៈមិនសមរម្យ នៅក្នុងបរិបទនៃទំនៀមទំលាប់គ្រីស្តរបស់អង្គការទស្សនៈពិភពលោក និងតម្លៃស្នូលរបស់អង្គការ។

ច. អង្គភាព ក្រុម ឬបុគ្គលខាងក្រៅ ស្នើសុំប្រើប្រាស់ធនធានរបស់អង្គការទស្សនៈពិភពលោក ដូចជាវីដេអូ ឬរូបថត ត្រូវតែចុះហត្ថលេខាព្រមព្រៀងជាមួយការិយាល័យជាដៃគូស្របច្បាប់របស់អង្គការទស្សនៈពិភពលោក ដើម្បីមានសិទ្ធិប្រើប្រាស់ឯកសារទាំងនោះ។ កិច្ចព្រមព្រៀងនេះ នឹងបូកបញ្ចូលទាំងរបាយការណ៍ប្រើប្រាស់ឯកសារ សម្រាប់គោលបំណងដទៃទៀត លើសពីអ្វីដែលបានព្រមព្រៀងគ្នា នឹងត្រូវចាត់ទុកជាការខ្វីពីអង្គការ ក្រុម ឬបុគ្គលចំពោះវិធានការផ្លូវច្បាប់។ បន្ថែមលើនេះទៀត ការខកខានមិនបានអនុវត្តតាមការប្រើប្រាស់ដែលបានព្រមព្រៀងគ្នារួចនៃឯកសារនេះអាចនឹងឈានដល់ការបញ្ឈប់ការអនុញ្ញាតិភ្លាមៗពីអង្គការទស្សនៈពិភពលោកចំពោះការប្រើប្រាស់នូវឯកសារ និង/ឬ ត្រូវប្រគល់ត្រឡប់វិញភ្លាមៗនូវរាល់សម្ភារៈទាំងអស់ដែលបានផ្តល់ឲ្យដោយអង្គការ អស្សនៈពិភពលោក។ ក៏ដូចជាច្បាប់ថតចម្លងណាមួយនៃឯកសារនោះដែរ។

## ៦. សេចក្តីណែនាំ ស្តីពីការត្រួតពិនិត្យ និង ជ្រើសរើស

ដើម្បីការពារកុមារ អង្គការទស្សនៈពិភពលោកអន្តរជាតិ នឹងត្រួតពិនិត្យរាល់និយោជិតសក្តានុពល និយោជិតធម្មតា បុគ្គលិកស្ម័គ្រចិត្ត បុគ្គលិកសាកល្បង អ្នកប្រឹក្សា និងសមាជិកក្រុមប្រឹក្សាទាំងអស់ ដោយស្របទៅតាមច្បាប់ស្តីពីការរាយការណ៍ពីឥណទានយុត្តិធម៌ (FCRA) និងច្បាប់ស្តីពីការស៊ើបអង្កេតលើអ្នកប្រើប្រាស់របស់រដ្ឋកាលីហ្វរញ៉ា។ ការត្រួតពិនិត្យនេះ នឹងមានតែការត្រួតពិនិត្យលើប្រវត្តិរូប សម្រាប់ការបញ្ជាក់សម្គាល់ភិនភាគ (ឧ. ត្រួតពិនិត្យសន្តិសុខសង្គម និងអាស័យដ្ឋាន) និងការកាត់ទោសពាក់ព័ន្ធនិង

ឧក្រិដ្ឋកម្ម (ឧ. បទឧក្រិដ្ឋ ឬ បទមជ្ឈឹម) ដែលជាប់ពាក់ព័ន្ធនិងការរំលោភបំពាន អំពើអនាចារលើកុមារ -ល-។ ការត្រួតពិនិត្យលើប្រវត្តិរូប នឹងត្រូវបានបញ្ចប់ តាមរយៈការជួលភ្នាក់ងាររាយការណ៍ពីអ្នកប្រើប្រាស់ ។ ប្រសិនបើប្រទេសកំណើតរបស់និយោជិត តម្រូវឲ្យមានការត្រួតពិនិត្យប្រវត្តិរូប សម្រាប់ខ្លួនគេផ្ទាល់ នោះនិយោជិតនឹងត្រូវទទួលខុសត្រូវរាល់សំណុំឯកសារថតចំលងសំខាន់ៗ ។

## ក. បេក្ខជនថ្មី ៖

រាល់បេក្ខជនទាំងអស់ នឹងត្រូវបានស្នើឲ្យចុះហត្ថលេខាលើសំណុំបែបបទស្ដីពីកាអនុញ្ញាតិ ឲ្យត្រួតពិនិត្យលើប្រវត្តិរូប ដែលជាផ្នែកមួយនៃដំណើរការដាក់ពាក្យស្នើសុំរបស់ពួកគេ។ បេក្ខជនទាំងអស់ត្រូវបានពិចារណាទៅលើមុខដំណែង និងតួនាទីដោយផ្អែកទៅលើការត្រួតពិនិត្យប្រវត្តិរូប ដែលជាអាទិភាពចំបងសម្រាប់ការងារ នៅក្នុងអង្គការទស្សនៈពិភពលោកអន្តរជាតិ។ ប្រសិនបើបេក្ខជនរំពឹងទុក បដិសេដមិនព្រមបញ្ជូនសំណុំឯក សារត្រួតពិនិត្យប្រវត្តិរូប របស់ខ្លួនមកកាន់អង្គការ នោះបញ្ជាក់ថាបេក្ខជននោះមិនមានលក្ខណៈសម្បត្តិ ដើម្បី ទទួលបានការងារនៅក្នុងការអង្គការទស្សនៈពិភពលោកអន្តរជាតិទេ។ បេក្ខជនថ្មីនឹងត្រូវបានផ្ដល់ព័ត៌មានមុនគេ ក្នុងចំនោមព័ត៌មានដទៃទៀត ថាអង្គការទស្សនៈពិភពលោកអន្តរជាតិលើកយកបញ្ហារការការពារកុមារ ជាបញ្ហាសំខាន់ដើម្បីធ្វើការដោះស្រាយ ហើយការត្រួតពិនិត្យលើបេក្ខជនថ្មី ក៏រួមបញ្ចូលនូវសមត្ថភាពនិយោជកជាបឋម និងដំណើរការការងារដទៃទៀតតាមបែបបុរាណ។

១. ការជ្រើសរើសបុគ្គលិកជាទូទៅ : ការជម្រះបញ្ជីដើម្បីបន្តទៅដំណាក់កាលបន្ទាប់ទៀតជាមួយនឹងការដាក់ការងារឲ្យធ្វើនៃបេក្ខជនដែលជោគជ័យ នឹងត្រូវអាស្រ័យលើលទ្ធផលនៃការត្រួតពិនិត្យសាវតារនេះ។

២. ការជ្រើសរើសបុគ្គលិកឆ្លើយតបនិងភាពបន្ទាន់ : បេក្ខជននៅតែត្រូវការឲ្យមាននូវលក្ខខ័ណ្ឌការងារ គឺត្រូវមានការត្រួតពិនិត្យបញ្ជាក់ពីអត្តសញ្ញាណ ភិនភាគ និងប្រវត្តិរូបច្បាស់លាស់ ដើម្បីទទួលយកជាជានិយោជិត ដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ។ ក្នុករណីមានការពន្យារពេលក្នុងការទទួលបាននូវការត្រួតពិនិត្យរបស់នគរបាលនៅក្រៅពីការត្រួតពិនិត្យរបស់អង្គការ ទស្សនៈពិភពលោកបេក្ខជនអាចនឹងត្រូវចាត់តាំងភ្លាមៗ ដោយផ្អែកលើមូលដ្ឋានតាមខេត្ត បានតែក្នុងករណីបន្ទាបពីឆ្លងកាត់នូវលក្ខខណ្ឌខាងក្រោមប៉ុណ្ណោះ ។

- ការិយាល័យក្នុងប្រទេស/ថ្នាក់ជាតិ ត្រូវបានបញ្ជាក់ប្រាប់ថា ការត្រួតពិនិត្យប្រវត្តិរូបស្ដីពីការការពារ កុមារ មិនទាន់ត្រូវបានបញ្ចប់នោះទេ ហើយការងាររបស់បេក្ខជន គឺអាស្រ័យលើការទទួលបានការត្រួតពិនិត្យប្រវត្តិរូប ក្នុងកំឡុងពេល ៩០ថ្ងៃ ឲ្យជាក់ច្បាស់ជាមុនសិន។
- ការត្រួតពិនិត្យទៅលើឯកាសារយោង ស្ដីពីការការពារកុមារ និងព័ត៌មានទូទៅដែលបានរៀបចជាឯកសារ គឺត្រូវបញ្ចប់ត្រឹមបេក្ខជន។
- ការសម្ភាសន៍បេក្ខជនទៅលើការការពារកុមារ ដែលបានរៀបចំចាឯកសារ ត្រូវបានត្រួតពិនិត្យដោយមន្ត្រីការពារកុមារ ឬ អ្នកជំនាញផ្នែកធនធានមនុស្ស។
- ការត្រួតពិនិត្យលើសំណៅឯកសារយោង ការធ្វើបទសម្ភាសន៍ និងព័ត៌មានពាក់ព័ន្ធដទៃទៀត ដែលសរសេរជាលាយល័ក្ខអក្សរទាំងអស់ ត្រូវរក្សាទុកហ្វាល
- បែបបទស្ដីពីសេចក្ដីប្រកាសអនុសញ្ញ ដែលមានការចុះហត្ថលេខា គឺត្រូវបានផ្ដល់ឲ្យដោយបេក្ខជន (សូមមើលខាងក្រោម)

៣. អង្គការទស្សនៈពិភពលោកអន្តរជាតិ ត្រូវតែទទួលបាននូវការត្រួតពិនិត្យប្រវត្តិរូប និងអត្តសញ្ញាណឲ្យបានច្បាស់លាស់ ក្នុងកំឡុងពេល ៩០ថ្ងៃ បន្ទាប់ពីបេក្ខជនបានទទួលយកការងារ។ កំឡុងពេលកំពុងរងចាំ ទទួលបានការត្រួតពិនិត្យប្រវត្តិរូបទៅលើការការពាកុមារ អង្គការទស្សនៈពិភពលោកអន្តរជាតិ ឬ ការិយាល័យក្នុងប្រទេស/ថ្នាក់ជាតិ មានសិទ្ធក្នុងការកំណត់ការងាររបស់បេក្ខជន។ ការបរាជ័យ

ក្នុងការផ្តល់/ពិនិត្យ ប្រវត្តិរូប និងអត្តសញ្ញាណ ក្នុងកឡុងពេល ៩០ថ្ងៃ នោះបេក្ខជនត្រូវបានដកចេញពីការចាត់តាំងការងារ និងឈានដល់ ការបញ្ចប់កិច្ចសន្យាការងារ។

## ខ. អ្នកប្រឹក្សា / អ្នកម៉ៅការឯករាជ្យ ៖

១. គ្រប់អ្នកប្រឹក្សាឯករាជ្យទាំងអស់ ត្រូវតែចុះហត្ថលេខាលើសេចក្តីប្រកាសអនុសញ្ញា ជាមួយគោលនយោបាយការពារកុមាររបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ។

២. អ្នកប្រឹក្សាណាមួយ ដែលត្រូវបានចាត់តាំងឲ្យបំពេញការងារនៅកន្លែងណាមួយ ឬ ស្ថិតនៅការិយាល័យ ជាដៃគូ ច្រើនជាង ៥ថ្ងៃ គឺតម្រូវឲ្យបញ្ជូនតារាងត្រួតពិនិត្យប្រវត្តិរូប។

## គ. នីតិវិធី ៖

១. វិញ្ញាបនកម្ម - មុនពេលស្នើសុំឲ្យមានការត្រួតពិនិត្យប្រវត្តិរូប អង្គការទស្សនៈពិភពលោកអន្តរជាតិ( WVI Corporate Security ) នឹងមានហ្វាលឯកសារដែលមានសំណុំបែបបទលាយលក្ខ័ជាអក្សរ ស្តីពីវិញ្ញាបនកម្ម ដើម្បីបញ្ជាក់ច្បាស់លាស់ចំពោះភ្នាក់ងាររាយការណ៍ពីឥណទានដែល WWI កំពុងប្រើប្រាស់ព័ត៌មានបែបនេះសម្រាប់គោលដំណងការងារតែប៉ុណ្ណោះ។

២. ការអនុញ្ញាតិ និងការចេញផ្សាយ-គ្រប់និយោជិត បុគ្គលិកស្ម័គ្រចិត្ត បុគ្គលិកសាកល្បង អ្នកប្រឹក្សាឯករាជ្យ និងសមាជិកក្រុមប្រឹក្សារបស់អង្គការទស្សនៈពិភពលោកអន្តរជាតិទាំងអស់ដែលមានការជាប់ពាក់ព័ន្ធ ជាមួយនិងការិយាល័យជាដៃគូអង្គការទស្សនៈពិភពលោកអន្តរជាតិ គឺត្រូវបានស្នើសុំឲ្យចុះហត្ថលេខាលើសំណុំបែបបទស្តីពីការអនុញ្ញាតិឲ្យត្រួតពិនិត្យប្រវត្តិរូប ហើយយកត្រឡប់ ទៅឲ្យ WVI Corporate Security វិញ។ ការខកខានមិនបានចុះហត្ថលេខាលើសំណុះបែបបទនេះ នឹងមិនត្រូវបានជ្រើសរើសសម្រាប់មុខដំណែងណាមួយឡើយ ឬក៏មានការបំបែកចេញ។

## ឃ. លទ្ធផលត្រួតពិនិត្យប្រវត្តិរូប ចំពោះបេក្ខជន និយោជិតបច្ចុប្បន្ន និង អ្នកម៉ៅការ/អ្នកប្រឹក្សាឯករាជ្យ ៖

អង្គការទស្សនៈពិភពលោកអន្តរជាតិ នឹងមិនរក្សាទុកសំណៅរបាយការណ៍ថតចំលងនោះទេ នៅពេល ដែលគេបានទទួលការត្រួតពិនិត្យប្រវត្តិរូប បញ្ជាក់ថាមានភាពច្បាស់លាស់ ។

ការត្រួតពិនិត្យនេះ នឹងត្រូវបានកត់ចំណាំនៅលើបែបបទអនុញ្ញាតិត្រួតពិនិត្យរបស់បេក្ខជន ហើយរក្សាទុកនៅក្នុងហ្វាលដាក់កុងត្រា ឬព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលិក។ នៅក្នុងករណី ដែលទទួលព័ត៌មានអវិជ្ជមានពីភ្នាក់ងាររាយការណ៍ពីអ្នកប្រើប្រាស់ (ភ្នាក់ងាររាយការណ៍ពីអ្នកប្រើប្រាស់) នោះអង្គការទស្សនៈពិភពលោកអន្តរជាតិនឹង:

១. ធ្វើការផ្តល់ដំណឹងពីភាពអវិជ្ជមាន ដោយផ្ទាល់មាត់ លាយលក្ខអក្សរ ឬ តាមប្រព័ន្ធអេឡិចត្រូនិច។

២. ជួបជាមួយបេក្ខជនផ្ទាល់ ដើម្បីពិភាក្សាពីរបាយការអវិជ្ជមាននេះ។

៣. ផ្តល់របាយការណ៍អវិជ្ជមាននេះទៅឲ្យបេក្ខជន ដោយផ្ទាល់មាត់ លាយលក្ខអក្សរ ឬ តាម ប្រព័ន្ធអេឡិចត្រូនិច។

៤. ផ្តល់ប្រឹក្សាដល់បេក្ខជនពីសិទ្ធិរបស់ពួកគេ ដោយផ្ទាល់មាត់ លាយលក្ខអក្សរ ឬ តាមប្រព័ន្ធអេឡិចត្រូនិច។

៥. ផ្តល់ប្រឹក្សាដល់បេក្ខជន អំពីភ្នាក់ងារដែលបានផ្តល់របាយការណ៍អវិជ្ជមាន ដោយផ្ទាល់មាត់ លាយលក្ខអក្សរ ឬ តាមប្រព័ន្ធអេឡិចត្រូនិច។

៦. មានសិទ្ធិក្នុងការចាត់វិធានការប្រឆាំង ដោយរួមបញ្ចូលទាំងពាក្យស្នើសុំតួនាទី ឬការបំបែកចេញ។ ប្រសិនបើសកម្មភាពប្រឆាំងត្រូវបានធ្វើឡើង នោះអង្គការទស្សនៈពិភពលោកអន្តរជាតិ នឹងធ្វើការផ្តល់ដំណឹង ដល់បេក្ខជនដោយផ្ទាល់មាត់ លាយលក្ខអក្សរ ឬ តាមប្រព័ន្ធអេឡិចត្រូនិច។

## ខ. សន្តិសុខ និងភាពសំងាត់ ៖

រាល់របាយការណ៍ ដែលបានបញ្ជាក់ពីព័ត៌មានសម្រាប់ពេលខាងមុខ ទាមទារឲ្យមានការរក្សាទុកជាសំងាត់ និងនៅកន្លែងដែលមានសុវត្ថិភាព និងប្រកបដោយសន្តិសុខ នៅក្នុងសន្តិសុខសាជីវកម្មរបស់ WVI។ ប្រធានការិយាល័យសន្តិសុខសាជីវកម្ម អ្នកសម្របសម្រួលលើការការពារកុមាររបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ នាយកការិយាល័យជាដៃគូ និងនាយកធនធានមនុស្ស នឹងជាបុគ្គលិកតែម្នាក់គត់ដែលត្រូវបានចាត់តាំង ឲ្យទទួលខុសត្រូវលើព័ត៌មានដែលទទួលបាន ដូចជាព័ត៌មានស្តីពីការត្រួតពិនិត្យប្រវត្តិរូបជាដើម។

## ៧. នីតិវិធីនៃការរាយការណ៍ ចំពោះការចោទប្រកាន់លើការប្រព្រឹត្តមិនត្រឹមត្រូវ

រាល់ការប្រព្រឹត្តមិនត្រឹមត្រូវ ជាមួយក្មេងៗ នោះនឹងមានឈានដល់ការស៊ើបអង្កេត និងរកដំណោះស្រាយភ្លាមៗ។ រាល់ការស៊ើបអង្កេត នឹងត្រូវបានធ្វើឡើងដោយនាយកធនធានមនុស្សនៃការិយាល័យជាដៃគូរ ប្រឹក្សាជាមួយអ្នកសម្របសម្រួលគាំពារកុមាររបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ។ អង្គការទស្សនៈពិភពលោករក្សាសិទ្ធិក្នុងការប្រើវិធានការអនុវត្តច្បាប់ ដូចដែលតម្រូវដោយច្បាប់។

ក. រាល់ការសង្ស័យ ឬការចោទប្រកាន់ ទៅលើការប្រព្រឹត្តមិនត្រឹមត្រូវ គឺត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់នាយកធនធានមនុស្សការិយាល័យជាដៃគូ របស់ការិយាល័យជាដៃគូ។ នរណាម្នាក់នៅក្នុងផ្នែកនេះ ដែលជួបប្រទះនូវស្ថានភាពបែបនេះ ហើយលេចឡើងជាបញ្ហាព្រួយបារម្ភ សម្រាប់ក្មេងដែលពាក់ព័ន្ធ ត្រូវរាយការណ៍ភ្លាមៗទៅកាន់នាយកការិយាល័យជាតិ ដែលធ្វើការទាក់ទងទៅនាយកធនធានមនុស្សនៃការិយាល័យជាដៃគូ។ ការស៊ើបអង្កេតផ្ទៃក្នុង នឹងត្រូវបានធ្វើឡើងដោយនាយកធនធានមនុស្សនៃការិយាល័យ ជាដៃគូ តំណាងមកពីផ្នែកធនធានមនុស្ស និងគណៈគ្រប់គ្រងជាន់ខ្ពស់ផ្នែកច្បាប់ (ឧ. នាយកការិយាល័យជាតិ ប្រធានគ្រប់គ្រងនិយោជិត)។

ខ. រាល់ការទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិច ចាំបាច់ត្រូវកំណត់ ចំនងជើងឲ្យបានច្បាស់ ដែលបង្ហាញពីភាពបន្ទាន់ ប៉ុន្តែមិនចាំបាច់បញ្ជាក់ពីស្ថានភាពជាក់ស្តែងនោះទេ។ ឧទាហរណ៍: ប្រើឃ្លាដូចជា បញ្ហាបន្ទាន់ ប្រសើរជាងប្រើឃ្លាថា មានការរំលោភបំពានលើកុមារ ពេលធ្វើការទំនាក់ទំនង។

គ. ការព្យាបាលដើមចោទ (សម្រាប់ជនរងជាអនិតិជន ដែលបានចោទប្រកាន់ និង/ឬ សម្រាប់បុគ្គលណា ដែលបានធ្វើសាក្សី ចំពោះការប្រព្រឹត្តមិនត្រឹមត្រូវនេះ)។ ដើមចោទនឹងត្រូវបានទទួលការព្យាបាលដោយការគោរព និងដោយយុត្តិធម៌។ ឯកសាររាយការណ៍ ដែលធ្វើឡើងដោយដើមចោទនឹងត្រូវបានរក្សានៅកន្លែង ដែលមានសុវត្ថិភាព និងសំងាត់។ ដើមចោទអាចៈ

១. ចូលរួមក្នុងការស៊ើបអង្កេតផ្ទៃក្នុង ទៅលើហេតុការណ៍ទាំងអស់ដែលខ្លួនបានដឹង។

២. នឹងត្រូវបានផ្តល់ឱកាសឲ្យបង្ហាញពីហេតុការណ៍ទាំងអស់ដែលខ្លួនបានដឹង

៣. នាយកធនធានមនុស្ស អង្គការទស្សនៈពិភពលោកអន្តរជាតិ នឹងធ្វើការសហការជាមួយការិយាល័យជាតិ ដើម្បីតាមដានជាមួយដើមចោទ និងផ្តល់សេវាកម្មប្រឹក្សា តាមភាពចាំបាច់។

ឃ. ការព្យាបាលជនជាប់ចោទ : ជនដែលត្រូវបានចោទប្រកាន់ នឹងត្រូវបានព្យាបាលដោយការគោរព និងយុត្តិធម៌។ ឯកសាររាយការណ៍ ដែលធ្វើឡើងដោយជនជាប់ចោទនឹងត្រូវបានរក្សាទុកជា

សំងាត់។ អង្គការទស្សនៈពិភពលោកអន្តរជាតិ នឹងធ្វើការជូនដំណឹងអំពីការចោទប្រកាន់ និងការស៊ើបអង្កេត។ ជនជាប់ចោទអាចៈ

១. នឹងត្រូវបានផ្តល់ឲ្យនូវឱកាស ក្នុងការឆ្លើយតបទៅនិងសំណៅឯកសារដែលបានសរសេរ។
២. នឹងត្រូវបានផ្តល់ឲ្យនូវឱកាស ឲ្យបង្ហាញ និងផ្តល់នូវព័ត៌មានដែលជាប់ទាក់ទិនដទៃផ្សេងទៀត និងសាក្សីផងដែរ។
៣. ទទួលបាននូវអនុស្សារណៈលាយលក្ខអក្សរ ស្តីពីការកំណត់ចុងក្រោយរបស់អង្គការទស្សនៈពិភព លោកអន្តរជាតិ នូវសេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេត ដែលនឹងបូកបញ្ចូល ប៉ុន្តែមិនត្រូវបានដាក់កំណត់លើការផ្តល់ដំណឹងចំពោះការចាត់វិធានការ ដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ ដែលឈានដល់ការព្យួរការងារ ឬ បំបែកចេញ។

ង. ការធានាអះអាង និងការជួលម្តងទៀត : ក្នុងករណីលុបពាក្យបណ្តឹង ដោយសារមានការបញ្ជាក់ពីភាពមិនប្រប្រក្រតីណាមួយ នោះអង្គការទស្សនៈពិភពលោកអន្តរជាតិ សូមរក្សាសិទ្ធិក្នុងការបញ្ចេញព័ត៌មាន ដូចជាការបញ្ចប់គ្រោះថ្នាក់សម្រាប់ការការពារកុមារចំពោះអង្គការមិនមែនរដ្ឋាភិបាលណាមួយ ដូចដែលអាចចាត់វិធានការបានតតាមផ្លូវច្បាប់ និងការអនុញ្ញាតិពីគយ) នៅក្នុងករណីដែលបុគ្គលិកអង្គការទស្សនៈពិភពលោកអន្តរជាតិ ត្រូវបានគេទាក់ទង សម្រាប់ធ្វើការធានាអះអាង នោះពួកគេត្រូវផ្តល់ដំណឹងទៅការិយាល័យការងារ របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ដើម្បីធ្វើឆ្លើយមកវិញ។ និយោជិត ដែលត្រូវបានបញ្ឈប់ពីការងារ ដោយសារការប្រព្រឹត្តមិនត្រឹមត្រូវ ជាក្មេងៗ គឺមិនសិទ្ធសម្រាប់ចូលមកបម្រើការងារម្តងទៀត នៅក្នុងអង្គការទស្សនៈពិភពលោកអន្តរជាតិនោះទេ។

## ៨. ការរក្សាការសំខាត់

ការជួយសម្របសម្រួល ក្នុងស៊ើបអង្កេត គឺទាមទារឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ក្នុងការរក្សាការសំងាត់ទៅដល់ភាគីជាប់ពាក់ព័ន្ធទាំងអស់។ ការចោទប្រកាន់ ឬអាកប្បកិរិយាមិនត្រឹមត្រូវណាមួយ នឹងត្រូវស៊ើបអង្កេត។ រាល់ពាក្យបណ្តឹង នឹងត្រូវបានយកចិត្តទុកដាក់យ៉ាងម៉ត់ចត់ និងមិនមានភាពលំអៀង ហើយរក្សាការសំងាត់យ៉ាងត្រឹមត្រូវ។ វាជារឿងមួយដ៏មានសារៈសំខាន់ ក្នុងការរក្សាការសម្ងាត់ ជាពិសេស នៅពេលដែលការស៊ើបអង្កេតបង្ហាញថា មិនមានបញ្ហាមិនសមស្របណាមួយកើតមាននោះទេ។ ការពិភាក្សាលំអិត ឬ ការចែករំលែកគំនិតនៃករណីណាមួយ ជាមួយអ្នកដែលមិនពាក់ព័ន្ធ នឹងមិនត្រូវបានអត់ឱនឲ្យនោះទេ និងការចាត់វិធានការផ្សេងៗ ឬឈានដល់ការបញ្ចប់ការងារតែម្តង។

អ្នកសម្របសម្រួលកម្មវិធីគាំពារកុមាររបស់ អង្គការទស្សនៈពិភពលោកអន្តរជាតិ អាចជាមនុស្សដែលកំណត់ ថាអ្វីដែលត្រូវទាក់ទងទៅការិយាល័យអង្គការទស្សនៈពិភពលោកផ្សេងទៀត (ការិយាល័យ ជាដៃគូ ការិយាល័យក្នុងតំបន់ការិយាល័យគាំទ្រ -ល-) ។ សូម្បីតែអ្នកគិតថា អ្នកគួរតែអាចទាក់ទងអំពីបញ្ហារំលោភបំពានលើកុមារ ក៏អ្នកត្រូវទទួលការអនុញ្ញាតិពីអ្នកសម្របសម្រួលកម្មវិធីគាំពារកុមារជាមុនដែរ។ អ្នកសម្របសម្រួល នឹងត្រូវទទួលខុសត្រូវលើការកំណត់បញ្ជីឈ្មោះបុគ្គលណា ដែលចាំបាច់ត្រូវដឹងចំពោះស្ថានការណ៍និមួយៗ ហើយនេះក៏បូករួមទាំងការទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយផងដែរ។

| | |
|---|---|
| **អនុម័តដោយ :** | បែល អ៊ីរិន អនុប្រធានស្តីទីផ្នែកធនធានមនុស្ស |
| **ប្រវត្តិឯកសារ :** | ការកែប្រែគោលនយោបាយលេខ ៥៩៥ ចុះថ្ងៃទី ១៧ សីហា ឆ្នាំ២០១១<br>ការកែប្រែគោលនយោបាយលេខ ៥៩៥ ចុះថ្ងៃទី ២៣ មករា ឆ្នាំ ២០១១ |



# កំណត់ចំណាំ

សូមប្រើទំព័រនេះដើម្បីសរសេរការកត់ចំណាំអ្វីផ្សេងៗដែលអ្នកចង់ចងចាំទុកនៅពេលដែលអ្នកត្រឡប់ទៅកាន់សហគមន៍របស់អ្នកវិញ។



# កំណត់ចំណាំ

សូមប្រើទំព័រនេះដើម្បីសរសេរការកត់ចំណាំអ្វីផ្សេងៗដែលអ្នកចង់ចងចាំទុកនៅពេលដែលអ្នកត្រឡប់ទៅកាន់សហគមន៍របស់អ្នកវិញ។

**អង្គការទស្សនៈពិភពលោកអន្តរជាតិ**

ការិយាល័យតំបន់អាស៊ីប៉ូពាំ
អាសយដ្ឋាន : ៨០៩ ផ្លូវតូចសុផានិមិត្ត ផ្លូវប្រាចាឧទិត
សំសិននុក ហាយក្វាង
ទីក្រុងបាងកក ១០៣១០ ប្រទេសថៃ
លេខទូរស័ព្ទ: +៦៦ ២ ០២២៩០០២
http://www.wvi.org/asiapacific

